អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប)

*“ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្ដីថ្លៃថ្នូរ”*



# របាយការណ៍ប្រចាំឆ្នាំ
# ២០១៨

ចេញផ្សាយនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៩




ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា

០៤២-០៩៤១-៤៨១ / ០៤២-៩៤១-៩១៨
kape@kapekh.org
www.kapekh.org
www.facebook.com/kapeaction
www.facebook.com/kapeaction
www.plus.google.com/+KAPECambodia
www.youtube.com/TheKapeCambodia
www.linkedin.com/company/kampuche an-action-for-primary-education


(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ១៩៩៩)

***សម្គាល់:*** *សូមមើលអំពីផលជះរបស់គម្រោងនីមួយៗ នៅលើគេហទំព័រអង្គការ ខេប។ លោកអ្នកអាចអានករណីសិក្សាបន្ថែមតាមរយៈតំណភ្ជាប់:*
*kapekh.org/en/what-we-do/4/?pro_id=20*

# សារប្រធានក្រុមប្រឹក្សាភិបាល



*ក្នុងនាមក្រុមប្រឹក្សាភិបាលអង្គការ ខេប ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងឯកភាពទៅលើរបាយការណ៍ប្រចាំឆ្នាំ២០១៨ ដែលចាប់ផ្តើមពីខែតុលា ឆ្នាំ២០១៧ ដល់ខែកញ្ញា ឆ្នាំ២០១៨។ របាយការណ៍នេះបានបង្ហាញទាំងដំណើរការកម្មវិធីជោគជ័យនៅក្នុងបរិយាកាសប្រតិបត្តិការដ៏លំបាក សមិទ្ធិផលថ្មីៗ និងការពង្រីកប្រភពផ្តល់មូលនិធិ។ ម្យ៉ាងវិញទៀត បរិយាកាសប្រតិបត្តិការកម្មវិធីមានការលំបាកនៅពេលបច្ចុប្បន្ននេះ។ ក្រុមប្រឹក្សាភិបាលសូមចូលរួមអបអរសាទរដល់បុគ្គលិកអង្គការ ខេប ទាំងអស់ដែលបានខិតខំពុះពារជួយកុមារកម្ពុជាដែលមានវិបត្តិឱ្យទទួលបានសេវាអប់រំមានគុណភាពខ្ពស់ រក្សាបាននូវស្តង់ដាអភិបាលកិច្ចល្អ មានតម្លាភាព និងមានប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលនិធិ។ ក្រុមប្រឹក្សាភិបាលសូមធ្វើការឆ្លុះបញ្ចាំងចំពោះជោគជ័យនេះទៅឆ្នាំបន្តបន្ទាប់ទៀត ដូចយើងបានដឹងហើយថាអង្គការ ខេប បានឈានមកដល់ខួបឆ្នាំទី២០របស់ខ្លួន៕*

**ប្រធានក្រុមប្រឹក្សាភិបាល**

**ហ៊ាន កុយ**

ខេបគឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ៧១.000នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ ដែលបង្រៀននៅជាង ១៦៥សាលាក្នុង១៤ខេត្ត-រាជធានី។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រតិដ្ឋថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រតិដ្ឋថ្មី
- តម្លាភាព
- ជឿជាក់

## មាតិកា


សារប្រធានក្រុមប្រឹក្សាភិបាល ........ 2
សារនាយកប្រតិបត្តិ ........ 3
សេចក្តីសង្ខេប ........ 4
ការឆ្លុះបញ្ចាំងទៅថ្ងៃអនាគត ........ 5
ព័ត៌មានសំខាន់ៗ និងព្រឹត្តិការណ៍អន្តរជាតិ ........ 6
ធីធីរអ្វ អ៊ីមផត អិចផត ឯ.ក ........ 9


## កម្មវិធី


គម្រោង សាលារៀនជំនាន់ថ្មី (NGS) ........ 10
គម្រោង សាលារៀនជំនាន់ថ្មី(NGS)-ស្វាយរៀង ........ 12
គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC) ........ 13
គម្រោង ស្បៀងអាហារសម្រាប់ការអប់រំ (FFE) ........ 14
កម្មវិធី អប់រំបញ្ចូលគ្នា (IEP) ........ 15
គម្រោង ងាយស្រួលរៀន (E2L) ........ 20
គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (QLE Expansion) ........ 22
គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH) ........ 23
គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ (SML) ........ 24
គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC III) ........ 25
គម្រោង លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER) ........ 26
គម្រោង គម្រោងសហសាលាកម្ពុជា (USC) ........ 27

ការបង្ហាញហិរញ្ញវត្ថុក្នុងឆ្នាំ២០១៨ ........ 28
ក្រុមអ្នកគ្រប់គ្រងនៅក្នុងឆ្នាំ២០១៨ ........ 29
រចនាសម្ព័ន្ធអង្គការ ខេប នៅក្នុងឆ្នាំ២០១៨ ........ 30

# សារនាយកប្រតិបត្តិ



ដោយមានសេចក្តីសោមនស្សដ៏រីករាយ អង្គការ ខេប សូមចែករំលែកនូវរបាយការណ៍ប្រចាំឆ្នាំថ្មីសម្រាប់ឆ្នាំសារពើពន្ធ ២០១៨ ជាមួយដៃគូទាំងអស់។ ឆ្នាំនេះគឺជាឆ្នាំដែលមានព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់អង្គការ ខេប បន្ទាប់ពីបំពេញការងារអស់រយៈពេលពីរទសវត្សរ៍របស់ខ្លួនក្នុងការផ្តល់សេវាលើកកម្ពស់ការអប់រំដល់កុមារកម្ពុជា។ ក្នុងន័យនេះ អង្គការ ខេប បានចាប់ផ្តើមជាអង្គការក្រៅរដ្ឋាភិបាលតូចមួយនៅក្នុងឆ្នាំ១៩៩៩ ហើយបានរីវឌ្ឍទៅជាអង្គការក្រៅរដ្ឋាភិបាលធំជាងគេបំផុតក្នុងវិស័យអប់រំនៅកម្ពុជា។នៅពេលយើងឈានចូលក្នុងឆ្នាំសារពើពន្ធថ្មី អង្គការ ខេប នឹងចាប់ផ្តើមកម្មវិធីនៅក្នុងទសវត្សរ៍ទី៣របស់ខ្លួន ដែលមានការអភិវឌ្ឍដ៏គួរឱ្យកត់សម្គាល់ រាប់បញ្ចូលទាំងតួនាទីផ្នែកបច្ចេកវិទ្យាខ្ពស់ និងការធ្វើឱ្យសាលារដ្ឋមានឯករាជ្យភាព។

អង្គការ ខេប បានចាប់ផ្តើមសរសេរកម្មវិធីនៅក្នុងទសវត្សរ៍ថ្មីមួយ ដែលមានតួនាទីពង្រឹងគម្រោងទាំង ១៨ ក្នុងការប្រតិបត្តិ និងមានចំណូលខ្ពស់ជាប្រវត្តិសាស្ត្រ។ គម្រោងថ្មីមួយចំនួនរបស់អង្គការ ខេប មានរយៈពេលខ្លី ប៉ុន្តែផ្តោតលើសកម្មភាពដែលនឹងរួមបញ្ចូលគ្នាដ៏សំខាន់ជាមួយគម្រោងដទៃទៀត។ ជាពិសេស សំដៅទៅលើការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ ដើម្បីគាំទ្រដល់គម្រោងរយៈពេលវែងដទៃៗទៀត។ ក្នុងន័យនេះ អង្គការ ខេប កំពុងអនុវត្តគំនិតផ្តួចផ្តើមផ្នែកលើបច្ចេកវិទ្យា ដើម្បីបង្កើតកម្មវិធីប្រឹក្សាយោបល់តាមអេឡិចត្រូនិចសម្រាប់កម្មវិធីយុវជន និងកម្មវិធីអានភាសាខ្មែរ ដែលនឹងជួយកម្មវិធីអំណានក្នុងការវាយតម្លៃលើអត្ថបទពិបាកៗឱ្យប្រសើរជាងមុន។ អង្គការ ខេប ក៏កំពុងធ្វើការអភិវឌ្ឍកម្មវិធីសិក្សាសរសេរកូដសម្រាប់អនុវិទ្យាល័យនៅកម្ពុជា ដែលជាគំនិតផ្តួចផ្តើមរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាផ្ទាល់។ គំនិតផ្តួចផ្តើមទាំងនេះបានធ្វើឱ្យអង្គការ ខេប ក្លាយទៅជាអ្នកច្នៃប្រតិដ្ឋឈានមុខគេនៅក្នុងវិស័យបច្ចេកវិទ្យាអប់រំ។

ការចំណាយថវិកានៅក្នុងឆ្នាំនេះ កម្មវិធីសាលារៀនជំនាន់ថ្មីនឹងបន្តរីកចម្រើនទៅជាចំណុចស្នូលមួយនៃកម្មវិធីទាំងអស់របស់អង្គការ។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បានពង្រីកការគាំទ្រដល់អង្គការ ខេប ដើម្បីបង្កើនកំណែទម្រង់ការអប់រំដ៏ធំនៅក្នុងវិស័យថ្មីៗ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ហិរញ្ញប្បទានបន្ថែមដល់អង្គការ ខេប ដើម្បីបង្កើតសាលារៀនជំនាន់ថ្មីនៅបឋមសិក្សា ក៏ដូចជាបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្គោលផងដែរ។ ទាំងនេះគឺជាការអភិវឌ្ឍដ៏ធំដែលផ្តល់អត្ថប្រយោជន៍ដល់គម្រោងដទៃទៀត ក៏ដូចជាផ្តល់នូវមាគ៌ាផ្លូវការមួយសម្រាប់អង្គការ ខេប អនុម័តលើការច្នៃប្រតិដ្ឋថ្មីៗជាផ្លូវការ ជាពិសេសវិស័យបច្ចេកវិទ្យា។ អង្គការ ខេប មានសេចក្តីសោមនស្សរីករាយដោយបានកត់សម្គាល់ឃើញថា **សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**បានលើកឡើងអំពីសាលារៀនជំនាន់ថ្មីក្នុងពេលថ្លែងសុន្ទរកថាបិទនៅក្នុងសមាជជាតិអប់រំ និងនៅរដ្ឋសភាស្តីពីកំណែទម្រង់សាលារៀនជំនាន់ថ្មីផងដែរ។ ទាំងនេះគឺជាព្រឹត្តិការណ៍សំខាន់ៗដែលបង្ហាញពីផលជះរបស់កម្មវិធីអង្គការ ខេប។

ទោះបីជាអង្គការ ខេប នៅបន្តទទួលបានមូលនិធិមួយចំនួនពីម្ចាស់ជំនួយទ្វេភាគី ដូចជា ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងសហភាពអឺរ៉ុប (EU) ក៏ដោយ ក៏អង្គការ ខេប បានបំពេញការងារជាយុទ្ធសាស្ត្រប្រកបដោយជោគជ័យក្នុងការទទួលមូលនិធិគាំទ្រពីម្ចាស់ជំនួយទ្វេភាគី រួមទាំងមូលនិធិឯកជន និងរដ្ឋាភិបាលកម្ពុជា។ ការណ៍នេះជួយលើកកម្ពស់កម្មវិធីឱ្យកាន់តែមាននិរន្តរភាពជាងមុន និងធ្វើឱ្យអង្គការ ខេប ផ្លាស់ប្តូរគោលនយោបាយនៅកម្ពុជាពីម្ចាស់ជំនួយទ្វេភាគី។ អង្គការ ខេប បានបន្តទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូដ៏យូរអង្វែង ដូចជា៖ អង្គការឆាលហ្វាន អង្គការ WeWorld អង្គការ Save the Children អង្គការមូលនិធិអាស៊ី និងអង្គការអប់រំពិភពលោក ខណៈពេលអង្គការ ខេប កំពុងមានដៃគូស្វាគមន៍ថ្មីៗ ដូចជា៖ មូលនិធិគ្រួសារ Franks មូលនិធិ Phoenix និង Kinchan Stiftung។

ជាថ្មីម្តងទៀត អង្គការ ខេប សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅដល់ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ចំពោះការគាំទ្រក្នុងអំឡុងពេលមួយឆ្នាំកន្លងមកនេះ ហើយយើងទន្ទឹងរង់ចាំសហការធ្វើការជាមួយគ្នា ដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំសម្រាប់កុមារ និងយុវជននៅប្រទេសកម្ពុជាក្នុងឆ្នាំខាងមុខនេះបន្តទៀត៕

ថ្ងៃព្រហស្បតិ៍ ១១រោច ខែបុស្ស ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
កំពង់ចាម ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៩

**នាយកប្រតិបត្តិ**

**សៅ វណ្ណា**

# សេចក្តីសង្ខេប

ក្នុងអំឡុងឆ្នាំ២០១៨ អង្គការ ខេប បានចុះបញ្ជីឡើងវិញនៅក្រសួងមហាផ្ទៃ ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីអនុលោមទៅតាមច្បាប់ថ្មីរបស់អង្គការក្រៅរដ្ឋាភិបាល។ ក្នុងអំឡុងពេលដំណើរការចុះបញ្ជីសារឡើងវិញ អង្គការ ខេប បានសម្រេចចិត្តផ្លាស់ប្តូរឈ្មោះទៅជា **អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា** ដើម្បីបង្ហាញឱ្យកាន់តែច្បាស់ថា ខេបមិនបានផ្តោតតែទៅលើការអប់រំបឋមសិក្សាទៀតនោះទេ ប៉ុន្តែ ខេបក៏មានកម្មវិធីអប់រំលើវិស័យការគាំពារ និងអភិវឌ្ឍន៍កុមារតូច ការអប់រំនៅមធ្យមសិក្សា និងការអប់រំនៅឧត្តមសិក្សាផងដែរ។ ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរឈ្មោះនេះនឹងមិនមានផលប៉ះពាល់ដល់អក្សរកាត់របស់អង្គការ ខេប នោះទេគឺរក្សាអក្សរកាត់ “KAPE” ឬហៅថា “**ខេប**” ដដែល។




ខេបរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុដែលមានទំហំទឹកប្រាក់ធំជាងមុន ដែលបានអនុវត្តគម្រោងទាំង១៨ ដែលចំនួននេះច្រើនជាងពីរដងនៅក្នុងឆ្នាំសារពើពន្ធ ២០១៧។ គម្រោងមួយចំនួននៃគម្រោងទាំងនេះគឺជាគម្រោងមានរយៈពេលយូរអង្វែង ដូចជា គម្រោង REACH (ពីឆ្នាំ២០១២ដល់បច្ចុប្បន្ន) និងគម្រោង Easy2Learn (ពីឆ្នាំ២០១៥ដល់បច្ចុប្បន្ន) ខណៈពេលគម្រោងផ្សេងៗទៀតមានទំហំតូចជាង និងមានរយៈពេលខ្លីដែលមានគោលបំណងជាក់លាក់ ដូចជា ការបង្កើតកម្មវិធីសុសវែរថ្មីៗ។ អង្គការ ខេប មានគម្រោងជាច្រើនដែលមានភាពចម្រុះគ្នាស្របតាមផែនការយុទ្ធសាស្រ្តរបស់ខ្លួន ហើយរួមទាំងកម្មវិធីអំណានថ្នាក់ដំបូង កម្មវិធីយុវជន បច្ចេកវិទ្យាអប់រំ និងភាពជាដៃគូឯកជននិងរដ្ឋ។ បច្ចុប្បន្ននេះ គម្រោងបានអនុវត្តនៅក្នុងចំនួន ១៤ខេត្ត និងបានផ្តល់ផលប្រយោជន៍ដល់កុមារ និងយុវជនជាង ៧០.០០០នាក់។

អង្គការ ខេប មានមោទនភាពចំពោះទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ហើយក៏ជាអង្គការតែមួយគត់ដែលទទួលបានហិរញ្ញប្បទានពីក្រសួង។ ក្នុងពេលបច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាគឺជាម្ចាស់ជំនួយដ៏ធំបំផុតរបស់អង្គការ ខេប ដែលបានផ្តល់ហិរញ្ញប្បទានចំនួន ១,៧លានដុល្លាអាមេរិក ប្រចាំឆ្នាំដល់អង្គការនេះក្នុងអំឡុងពេលឆ្នាំសារពើពន្ធ ២០១៨ ដើម្បីគាំទ្រដល់កំណែទម្រង់ការអប់រំតាមរយៈគម្រោងសាលារៀនជំនាន់ថ្មី។

| គម្រោងទាំង ១៨ ក្នុងឆ្នាំ២០១៨ | |
|---|---|
| BfC | គម្រោង សៀវភៅសម្រាប់កម្ពុជា |
| CTSP | គម្រោង អាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា |
| E2L | គម្រោង ងាយស្រួលរៀន |
| FFE | គម្រោង ស្បៀងអាហារសម្រាប់ការអប់រំ |
| GEI | គម្រោង អប់រំកុមារី |
| KRP | គម្រោង កម្មវិធីអំណានភាសាខ្មែរ |
| NGS/SR | គម្រោង សាលារៀនជំនាន់ថ្មី/ស្វាយរៀង |
| NGSI (មធ្យម) | គម្រោង សាលារៀនជំនាន់ថ្មី/កម្រិតអនុវិទ្យាល័យ |
| NGSI (បឋមសិក្សា) | គម្រោង សាលារៀនជំនាន់ថ្មី/កម្រិតបឋមសិក្សា |
| QLE | គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព |
| REACH II | គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ |
| SML* | គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ |
| STEM4Women* | គម្រោង ស្តែមសម្រាប់ស្រ្តី |
| TRAC III | គម្រោង វិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ ៣ |
| TIGER | គម្រោង លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀននិងរៀន |
| TVP | គម្រោង កម្មវិធីត្រីវិស័យ (ត្រីវិស័យ) |
| TNT | គម្រោង Track and Trace |
| USC | គម្រោង សហសាលានៅកម្ពុជា |
| * *គម្រោងដែលត្រូវបានបិទបញ្ចប់នៅក្នុងឆ្នាំ២០១៨* | |

ការប្រតិបត្តិកម្មវិធីគម្រោងទាំងអស់បានទទួលផលប្រយោជន៍ពីការច្នៃប្រតិដ្ឋចម្រុះ ដូចជា៖ កម្មវិធីផ្តល់ប្រឹក្សាថ្មីដែលបង្កើតឡើងដោយគម្រោងអប់រំកុមារី ការរចនាបទបណ្ណាល័យបឋមសិក្សាដែលបង្កើតឡើងដោយគម្រោង E2L ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ និងបច្ចេកវិទ្យា (ICT) ក្នុងការបង្រៀននិងរៀនដែលលើកកម្ពស់ដោយកម្មវិធីសាលារៀនជំនាន់ថ្មី និងការធ្វើអំណោយសៀវភៅរបស់គម្រោងសៀវភៅសម្រាប់កម្ពុជា។ គម្រោងជាច្រើនបានទទួលអត្ថប្រយោជន៍ និងភាពជោគជ័យពីគម្រោងដទៃៗទៀត។

អង្គការ ខេប ក៏បានបន្តប្រមូលផ្តុំកម្មវិធីសុសវែរថ្មីៗសម្រាប់អប់រំជាច្រើន ដែលត្រូវនឹងបរិបទប្រព័ន្ធសាលារៀននៅកម្ពុជា។ បច្ចុប្បន្ននេះ ឈ្មោះកម្មវិធីថ្មីដែលបានអភិវឌ្ឍ ឬបរិបទឡើងដោយអង្គការ ខេប រួមមាន៖ កម្មវិធី *Aan Khmer* (សម្រាប់អំណានថ្នាក់ទី១) កម្មវិធីសៀវភៅឆ្លាត/*SmartBooks* (កម្រិតអ្នកអានតាមអេឡិចត្រូនិចថ្នាក់ទី២ ដល់ថ្នាក់ទី៣) កម្មវិធី *Sorse Khmer* (សំណេរថ្នាក់ដំបូងសម្រាប់ភាសាខ្មែរ) *Literatu* (ការវាយតម្លៃតាមអេឡិចត្រូនិច) កម្មវិធី *Trey Visay* (កម្មវិធីប្រឹក្សាអាជីពតាមអេឡិចត្រូនិច) និងកម្មវិធីដទៃៗទៀត។ កម្មវិធីសុសវែទាំងនេះមានគោលដៅទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ហើយបច្ចុប្បន្នកំពុងត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងជាច្រើន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះធ្វើឱ្យអង្គការ ខេប ក្លាយជាអ្នកនាំមុខក្នុងការអភិវឌ្ឍ និងការអនុវត្តកម្មវិធីសុសវែរអប់រំ ដែលបានរៀបចំឡើងសម្រាប់ប្រព័ន្ធសាលារៀននៅកម្ពុជា។ ការប្រើប្រាស់សុសវែរនៅក្នុងវិស័យអប់រំគឺត្រូវនឹងផែនការយុទ្ធសាស្រ្តរបស់អង្គការ ខេប ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអប់រំដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ។

ស្ថានភាពហិរញ្ញវត្ថុទូទៅរបស់អង្គការ ខេប រក្សាលំនឹងបាននៅក្នុងឆ្នាំនេះទោះបីជាចំណូលប្រចាំឆ្នាំថយចុះបន្តិចគឺពី **៣,៦៥លាន**ដុល្លាអាមេរិកនៅក្នុងឆ្នាំសារពើពន្ធ ២០១៧ មក **៣,៥៥លាន**ដុល្លាអាមេរិកក្នុងឆ្នាំ២០១៨ ឬថយចុះចំនួន **២,៥%**ក៏ដោយ។ នៅចុងឆ្នាំនេះ

# សេចក្តីសង្ខេប





អង្គការ ខេប មានម្ចាស់ជំនួយ និងដៃគូចំនួន ២១ រួមទាំងម្ចាស់ជំនួយថ្មី ដូចជា៖ មូលនិធិ Kinchan Stiftung ដែលជាអ្នកឧបត្ថម្ភគាំទ្រហិរញ្ញប្បទានរយៈពេលវែងក្នុងការកែលម្អសេវាអប់រំនៅតាមជនបទ។ ម្យ៉ាងវិញទៀត យើងកត់សម្គាល់ឃើញថា បច្ចុប្បន្ននេះ ចំណូលរបស់អង្គការចំនួន ៤៩% ទទួលបានមកពីក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាគឺជាម្ចាស់ជំនួយធំបំផុតរបស់អង្គការ ខេប។ អត្រាប្រើប្រាស់ហិរញ្ញប្បទាននៅក្នុងឆ្នាំនេះស្ថិតនៅចំនួន ៩៩% ដោយយោងលើការចេញផ្សាយហិរញ្ញប្បទានដ៏ធំមួយរបស់ក្រសួងអប់រំយុវជននិងកីឡានៅចុងឆ្នាំសារពើពន្ធនេះ។ នាឆ្នាំកន្លងមក ប្រភពហិរញ្ញប្បទានរបស់អង្គការ ខេប ចំនួន ៦០% ត្រូវបានចំណាយទៅលើការគាំទ្រអ្នកទទួលផល រួមមាន៖ សេវាកម្មអប់រំ សម្ភារសិក្សា និងបរិក្ខាសាលារៀន ថវិកាអភិវឌ្ឍន៍សាលារៀន និងការសិក្សាស្រាវជ្រាវនៅឆ្នាំ២០១៨។



កុមារនៅសាលាបឋមសិក្សាជនបទបាន ប្រើប្រាស់ សេវា M-Learning (ថេបប្លេត) នៅក្នុងបណ្ណាល័យសតវត្សរ៍ទី២១។

បើទោះជាឆ្នាំសារពើពន្ធ ២០១៧ បានបិទបញ្ចប់ដោយជោគជ័យ និងមានការរីកចម្រើនក៏ដោយ ក៏អង្គការ ខេប បានដឹងអំពីភាពមិនច្បាស់លាស់ជាច្រើនដែលនឹងកើតឡើងនៅឆ្នាំ២០១៩ខាងមុខនេះ រួមមានការបាត់បង់ឯកសិទ្ធិពាណិជ្ជកម្មកម្ពុជាទៅទីផ្សារសហភាពអឺរ៉ុប និងអាមេរិក ដែលអាចប៉ះពាល់ដល់ស្ថិរភាពសេដ្ឋកិច្ច និងចំណូលពន្ធរបស់រដ្ឋាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការ ខេប នៅជឿជាក់ថាហិរញ្ញវត្ថុចម្រុះ និងការកាត់បន្ថយជំនួយទ្វេភាគីនឹងធ្វើឱ្យជួបនឹងភាពស្រពិចស្រពិលដែលអាចកើតមានក្នុងឆ្នាំខាងមុខនេះ។

## ការឆ្លុះបញ្ចាំង និងឆ្ពោះទៅមុខ...!

ខណៈពេលដែលវដ្តគម្រោងមួយចំនួនធំនឹងត្រូវបិទបញ្ចប់នៅឆ្នាំ២០១៨ អង្គការ ខេប បានបន្តការវិនិយោគដ៏ច្រើននៅក្នុងការអភិវឌ្ឍកម្មវិធីដែលឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ ៥ឆ្នាំរបស់ខ្លួន។ ដូចយើងបានកត់សម្គាល់ពីខាងលើ អង្គការ ខេប បានផ្តោតការខិតខំប្រឹងប្រែងយកចិត្តទុកដាក់លើបញ្ហាយុវជន អក្ខរកម្មថ្នាក់ដំបូង បច្ចេកវិទ្យានៅក្នុងវិស័យអប់រំ ហើយសំខាន់បំផុតគឺការអភិវឌ្ឍសាលាធម្មនុញ្ញ។ សរុបមក គម្រោងរៀបចំស្នើឡើងទាំង១៦ ត្រូវបានដាក់ជូនម្ចាស់ជំនួយត្រួតពិនិត្យផ្ទៀងផ្ទាត់ និងអនុម័ត។ ក្នុងនោះ គម្រោងចំនួន ៨៧% ទទួលបានជោគជ័យខណៈគម្រោងចំនួន២(១៣%)ទៀតត្រូវបានបដិសេធដោយម្ចាស់ជំនួយ។ ក្នុងចំណោមគម្រោងអនុម័តទាំងបួនក្នុងនេះគឺពង្រីកបន្តខណៈគម្រោងថ្មីៗនៅរង់ចាំចម្លើយតប។ ជាលទ្ធផល កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្មវិធីក្នុងអំឡុងឆ្នាំ២០១៨នេះ អង្គការ ខេប រំពឹងថានឹងបានប្រតិបត្តិការគម្រោងចំនួន ១៨ នៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ទៀត។

## សេចក្តីសង្ខេបការអភិវឌ្ឍកម្មវិធីថ្មីៗក្នុងឆ្នាំ ២០១៧

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លទ្ធផល | រយៈពេល |
|---|---|---|---|---|
| ១. គម្រោងសាលារៀនជំនាន់ថ្មី/កម្រិតអនុវិទ្យាល័យ (ពង្រីកទី៣) | មូលនិធិ Franks Family<br>អង្គការអប់រំពិភពលោក | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ២. គម្រោងសាលារៀនជំនាន់ថ្មី/កម្រិតបឋមសិក្សា | មូលនិធិ Franks Family | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ៣. មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្គោលសាលារៀនជំនាន់ថ្មី | អង្គការឆាលហ្វាន<br>មូលនិធិ Franks Family | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ៤. គម្រោងសាលារៀនជំនាន់ថ្មី/ស្វាយរៀង (បន្ត) | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៣ឆ្នាំ |
| ៥. គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH III) | អង្គការ Ciai | អង្គការវីវើល | ជោគជ័យ | ២ឆ្នាំកន្លះ |
| ៦. គម្រោងងាយស្រួលរៀន (បន្ត) | -- | អង្គការឆាលហ្វាន | ជោគជ័យ | ១ឆ្នាំ |
| ៧. គម្រោង Track & Trace | អង្គការអប់រំពិភពលោក | ធនាគារពិភពលោក | ជោគជ័យ | ១ឆ្នាំ |
| ៨. គម្រោងសៀវភៅសម្រាប់កម្ពុជា (បន្ត) | -- | អង្គការមូលនិធិអាស៊ី | ជោគជ័យ | ១ឆ្នាំ |
| ៩. គម្រោងផ្តល់សិទ្ធិអំណាចយុវជនតាមរយៈការអប់រំ | -- | អង្គការមូលនិធិអូកទ្រី | ជោគជ័យ | ១ឆ្នាំ |
| ១០. គម្រោងអប់រំកុមារី | -- | អង្គការ Lotus Outreach | ជោគជ័យ | ៣ឆ្នាំ |
| ១១. គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី | -- | ក្រុមហ៊ុន Gap, Inc. | ជោគជ័យ | ២ឆ្នាំ |
| ១២. គម្រោងសហសាលានៅកម្ពុជា | សមាគមមិត្តគ្រួសារយើង | មូលនិធិ Kinchan Stiftung | ជោគជ័យ | ១ឆ្នាំ |
| ១៣. គម្រោងអំណានភាសាខ្មែរ | -- | អង្គការឆាលហ្វាន | ជោគជ័យ | ១ឆ្នាំ |
| ១៤. កម្មវិធីត្រីវិស័យ (បន្ត) | អង្គការ InSTEED | DAI-USAID | ជោគជ័យ | ៦ខែ |
| ១៥. គម្រោង All Children Reading | Chemonics | ទីភ្នាក់ងារ USAID | មិនជោគជ័យ | ៣ឆ្នាំ |
| ១៦. គម្រោងអប់រំកុមារ (បន្ត) | អង្គការ Aide et Action | មូលនិធិ Qatar | មិនជោគជ័យ | ៣ឆ្នាំ |

## ព្រះរាជទស្សនកិច្ចរបស់អ្នកអង្គម្ចាស់ ប៊ីទ្រីស ចក្រភពអង់គ្លេសនៅសាលារៀនជំនាន់ថ្មី

ព័ត៌មានដ៏រីករាយអំពីកំណែទម្រង់ការអប់រំនៅប្រទេសកម្ពុជា ដែលដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា បានធ្វើឱ្យមានការចាប់អារម្មណ៍ពីអន្តរជាតិតាមរយៈសាលារៀនជំនាន់ថ្មី។ ដំណើរទស្សនកិច្ចក្រៅផ្លូវការរបស់អ្នកអង្គម្ចាស់ចក្រភពអង់គ្លេស ប៊ីទ្រីស នៃក្រុងយ៉ក បានធ្វើឡើងនៅប្រទេសកម្ពុជាពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែតុលាឆ្នាំ២០១៨។ អ្នកអង្គម្ចាស់គឺជាចៅស្រីរបស់ព្រះមហាក្សត្រយានី អេលីហ្សាបែតទី២។ អមព្រះរាជដំណើរដោយលោក Simon Franks នាយកមូលនិធិគ្រួសារ Franks (FFF) ដែលបច្ចុប្បន្នជាដៃគូរបស់ក្រសួងអប់រំ យុវជន និងកីឡា មកពីចក្រភពអង់គ្លេស និងលោកស្រី Bathille Missika តំណាងមកពីអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) មានការិយាល័យនៅក្នុងទីក្រុងប៉ារីស អ្នកអង្គម្ចាស់បានព្រះរាជ្យទស្សនាសាលារៀនជំនាន់ថ្មីចំនួន២ រួមមាន៖ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ក្នុងក្រុងកំពង់ចាម និងវិទ្យាល័យ ព្រះស៊ីសុវត្ថិ នៅរាជធានីភ្នំពេញ។ ព្រះរាជដំណើរទស្សនកិច្ចនេះមានបំណងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងចំពោះកំណែទម្រង់សាលារៀនជំនាន់ថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា និងជួយបង្កើតបណ្តាញអន្តរជាតិមួយដែលនឹងនាំឱ្យកំណែទម្រង់នេះឆ្លើយតបទៅនឹងប្រទេសដទៃទៀតក្នុងតំបន់ ដូចជា៖ ប្រទេសឡាវ និងមីយ៉ាន់ម៉ា។ ដំណើរទស្សនកិច្ចនេះត្រូវបានដឹកនាំដោយអង្គការ ខេប តាំងពីពេលក្រសួងអប់រំកំណត់ឱ្យអនុវត្តកំណែទម្រង់សាលារៀនជំនាន់ថ្មី និងទទួលហិរញ្ញប្បទានពីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ។ ដំណើរទស្សនកិច្ចរបស់អ្នកអង្គម្ចាស់គឺជាកិត្តិយសដ៏ធំធេងសម្រាប់អង្គការ ខេប ហើយបានជួយយ៉ាងច្រើនក្នុងការជំរុញជំហរ និងឥទ្ធិពលរបស់ខ្លួនដើម្បីលើកកម្ពស់កំណែទម្រង់ការអប់រំរបស់ក្រសួងអប់រំយុវជននិងកីឡា។


សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានដឹកនាំធ្វើបទបង្ហាញអំពីបណ្ណាល័យសាលារៀនជំនាន់ថ្មីថ្វាយជូនដល់អ្នកអង្គម្ចាស់ជ្រាប។


អ្នកអង្គម្ចាស់បានយាងជួបសំណេះសំណាលជាមួយសិស្សនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ។

## ពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យនៅក្នុងប្រទេសថៃ

ពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយសាកលវិ. រ៉ាចាម៉ង់ខ្លា: លោកបណ្ឌិត ណារ៉ុង (ឆ្វេង) សាកលវិទ្យាធិការរងនៃសាកលវិ. រ៉ាចាម៉ង់ខ្លា និងលោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប ចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីអាហារូបករណ៍សម្រាប់យុវជនកម្ពុជា។ ➔





🡐 ប្រតិភូមហាវិទ្យាល័យបច្ចេកវិទ្យា ឃីងម៉ង់គត់ បានមកធ្វើទស្សនកិច្ចនៅខេត្តកំពង់ចាម: លោកស្រីបណ្ឌិត ឧម៉ា ស៊ីប៊ូនរួង (កណ្តាល) នាយករងផ្នែកទំនាក់ទំនងអន្តរជាតិ បានមកទស្សនកិច្ចនៅវិទ្យាល័យ ព្រះសីហនុ ក្រុងកំពង់ចាម ដើម្បីបង្ហាញទិសអំពីកម្មវិធីអប់រំនៅមហាវិទ្យាល័យវិស្វកម្ម និងបច្ចេកវិទ្យា ឃីងម៉ង់គត់ ដល់សិស្សកម្ពុជា។

ជាកិច្ចប្រឹងប្រែងតស៊ូមតិដើម្បីបង្កើតឱកាសសិក្សាសម្រាប់និស្សិតកម្ពុជាបានទៅសិក្សានៅគ្រឹះស្ថានដែលមានគុណភាពខ្ពស់ អង្គការ ខេប បានរៀបចំទទួលដំណើរទស្សនកិច្ចដ៏ខ្ពង់ខ្ពស់របស់ប្រតិភូគ្រឹះស្ថានឧត្តមសិក្សាពីរមកពីប្រទេសថៃ។ នៅក្នុងខែមេសានេះ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យ រ៉ាចាម៉ង់ខ្លា/ស៊ូរិន្ទ បានមកធ្វើទស្សនកិច្ចនៅអង្គការ ខេប ក្នុងខេត្តកំពង់ចាម ដើម្បីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជា ដែលត្រូវជ្រើសរើសសម្រិតសម្រាំងដោយអង្គការ ខេប។ និស្សិតទាំងនេះក៏នឹងទទួលបានការស្នាក់នៅដោយឥតគិតថ្លៃផងដែរ។ នៅខែ កក្កដាឆ្នាំ២០១៨នេះ អង្គការ ខេប ក៏បានទទួលដំណើរទស្សនកិច្ចពីសាកលវិទ្យាធិការរងមហាវិទ្យាល័យវិស្វកម្ម និងបច្ចេកវិទ្យាឃីងម៉ង់គត់ ក្នុងទីក្រុងបាងកកផងដែរ។ បន្ទាប់ពីដំណើរទស្សនកិច្ចដែលអង្គការ ខេប គាំទ្រ និងជាពិសេសសាលារៀនជំនាន់ថ្មី សាលាឃីងម៉ង់គត់ក៏បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយអង្គការ ខេប ដោយផ្តល់អាហារូបករណ៍ដល់និស្សិតចំនួន១០នាក់ដែលបញ្ចប់ថ្នាក់ទី១២ ហើយត្រូវបានអង្គការ ខេប ជ្រើសរើសសម្រិតសម្រាំងបំផុត។ សាកលវិទ្យាល័យទាំងពីរនេះគឺជាគ្រឹះស្ថានឧត្តមសិក្សាដ៏មានកិត្យានុភាពខ្ពស់នៅប្រទេសថៃ ដែលនឹងក្លាយជាដៃគូដ៏សំខាន់ ខណៈដែលអង្គការ ខេប បន្តរកប្រភពថវិកាបន្ថែមទៀតដើម្បីជួយគាំទ្រផ្នែកអាហារ សៀវភៅសិក្សា និងថ្លៃធ្វើដំណើររបស់និស្សិតក្នុងពេលសិក្សា។ សម្ព័ន្ធភាពនេះបានធ្វើឱ្យអង្គការ ខេប ក្លាយទៅជាដៃគូគួរឱ្យទុកចិត្ត ហើយអាចប្រមូលធនធានពីពហុប្រភពដើម្បីជួយយុវជនកម្ពុជាឱ្យសម្រេចក្តីសុបិន្តរបស់ពួកគេបាន។

# ព័ត៌មាន និងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ

*“ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន ”*

## គណៈប្រតិភូអង្គការ ខេប ធ្វើទស្សនកិច្ចនៅគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសថៃ ដើម្បីចរចារកការគាំទ្រអាហារូបករណ៍សម្រាប់យុវជនកម្ពុជា



*បណ្តាញសាកលវិទ្យាល័យ: ក្រុមទីប្រឹក្សាអង្គការ ខេប បានចរចារកសម្បទានអាហារូបករណ៍ជាមួយសាលាបច្ចេកវិទ្យា យឺងម៉ង់គត់ នៅទីក្រុងបាងកក។*

ដោយទទួលបានជំនួយមួយចំនួនតូចមួយពីមូលនិធិគ្រួសារត្រូកូលហ្វេង ក្រុមការងារ និងទីប្រឹក្សារបស់អង្គការ ខេប បានធ្វើទស្សនកិច្ចនៅគ្រឹះស្ថានឧត្តមសិក្សាដើម្បីកសាងបណ្តាញដៃគូជាមួយសាកលវិទ្យាល័យនៅក្នុងប្រទេសថៃ។ ក្នុងអំឡុងពេលទស្សនកិច្ចនេះ អង្គការ ខេប បានធ្វើទស្សនកិច្ចនៅសាលាបច្ចេកវិទ្យា យឺងម៉ង់គត់ (មហាវិទ្យាល័យវិស្វកម្ម) សាកលវិទ្យាល័យ រ៉ាចាម៉ង់ខ្លា សាកលវិទ្យាល័យ ខងគេន (មហាវិទ្យាល័យអប់រំ) និងសាលាបូរ៉ាំ រ៉ាចាផាត់ (មហាវិទ្យាល័យអប់រំ)។ កិច្ចពិភាក្សានេះមានភាពស្និទ្ធស្នាល និងរួសរាយរាក់ទាក់ និងយ៉ាងហោចណាស់បាននាំឱ្យមានការប្តេជ្ញាចិត្តជាក់លាក់ពីគ្រឹះស្ថានចំនួនពីរដើម្បីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាលើចំនួនថ្លៃសិក្សាអាហារូបករណ៍ និងការស្នាក់នៅជាក់លាក់សំរាប់និស្សិតកម្ពុជា ព្រមទាំងកិច្ចព្រមព្រៀងពីអង្គការ ខេប ដើម្បីសម្របសម្រួលការផ្តល់សេវានៅកម្ពុជា ដោយប្រើប្រាស់ការិយាល័យរបស់អង្គការជាមួយក្រសួងអប់រំយុវជននិងកីឡា។ អង្គការ ខេប ក៏បានយល់ព្រមផ្តល់កន្លែងខ្លះដល់និស្សិតហាត់ការថៃ ដែលស្វែងរកបទពិសោធន៍ការងារមានលក្ខណៈជាអន្តរជាតិ។ ដំណើរទស្សនកិច្ចជាបន្តបន្ទាប់មកកាន់ប្រទេសកម្ពុជាពីសំណាក់អ្នកតំណាងគ្រឹះស្ថានសិក្សាទាំងនេះបាននាំឱ្យមានពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាផ្លូវការ។

## សន្និសីទ SEAMEO INNOTECH ស្តីពី "ការបង្កើតវិធីសាស្ត្រគាំទ្រការអប់រំបញ្ចូលគ្នា"

នៅក្នុងខែមីនា ឆ្នាំ២០១៨ លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប លោក ឆន ឆៃយុទ្ធ អ្នកសម្របសម្រួលផ្នែកបច្ចេកវិទ្យាអប់រំអង្គការ ខេប និងលោក ឈុំ កុម្ភៈ នាយកសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប បានចូលរួមសន្និសីទរយៈពេលបីថ្ងៃនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដើម្បីពិភាក្សាអំពីវិធីសាស្ត្រច្នៃប្រតិដ្ឋថ្មីៗសម្រាប់លើកកម្ពស់កម្មវិធីអប់រំបញ្ចូលគ្នានៅក្នុងតំបន់។ សន្និសីទនេះត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលសម្រាប់ការបង្កើតថ្មីផ្នែកអប់រំ និងបច្ចេកវិទ្យាប្រចាំតំបន់របស់អង្គការអប់រំរដ្ឋមន្ត្រីអាស៊ីអាគ្នេយ៍ (SEAMEO)។ សន្និសីទនេះផ្តោតទៅលើវិស័យសំខាន់ៗចំនួនបីរបស់កម្មវិធីអប់រំបញ្ចូលគ្នា រួមមាន៖ (i) ភាពជាអ្នកដឹកនាំ (ii) វប្បធម៌សិក្សាចម្រុះ និង (iii) ការបញ្ចូលគោលនយោបាយ និងការអនុវត្តសម្រាប់ការអប់រំបញ្ចូលគ្នា។ អង្គការ ខេប បានខិតខំធ្វើសមាហរណកម្មលើឧត្តមនានុវត្តទៅក្នុងកម្មវិធីអប់រំបញ្ចូលគ្នា ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីប្រមូលកុមារក្រៅសាលារៀន។




*តំណាងអង្គការ ខេប ចូលរួមសន្និសីទប្រចាំតំបន់ ស្តីពី **“SEAMEO-Innotech** ក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។*

## កិច្ចប្រជុំកំពូល YSEALI



*លោក ផាន់ ប៊ុនណាត (ឈរនៅចំហៀងខាងស្តាំ) នៅក្នុងកិច្ចប្រជុំកំពូល YSEALI។*

លោក ផាន់ ប៊ុនណាត ប្រធានប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មីបានចូលរួមក្នុងកិច្ចប្រជុំកំពូលអន្តរជាតិនៅទីក្រុងម៉ានីលនៅ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលរៀបចំដោយក្រសួងការបរទេសសហរដ្ឋអាមេរិក។ គំនិតផ្តួចផ្តើមកម្មវិធីភាពជាមេដឹកនាំវ័យក្មេងនៅអាស៊ីអាគ្នេយ៍នេះ គឺជាកម្មវិធីមួយផ្តួចផ្តើមឡើងដោយអតីតប្រធានាធិបតីសហរដ្ឋអាមេរិក លោក បារ៉ាក់ អូបាម៉ា ដើម្បីជំរុញ និងរៀបចំក្រុមអ្នកផ្លាស់ប្តូរវ័យក្មេងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ កិច្ចប្រជុំកំពូលនេះបង្កើតជំនាញភាពជាអ្នកដឹកនាំក្នុងចំណោមអ្នកចូលរួមក្នុងកម្មវិធីនេះ និងផ្តល់វេទិកាមួយសម្រាប់ការផ្លាស់ប្តូរគំនិត និងបទពិសោធន៍រវាងប្រទេស និងប្រទេស។ អង្គការ ខេប មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកម្មវិធី YSEALI បានជួយគាំទ្រដល់សកម្មភាពផ្តល់សិទ្ធិអំណាចយុវជនក្នុងគម្រោងនានា ដូចជា៖ សាលារៀនជំនាន់ថ្មី និងគម្រោងអង្គការផ្សេងៗទៀត ធានាឱ្យមានការទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយស្ថានទូតសហរដ្ឋអាមេរិក។

## ដំណើរទស្សនកិច្ចប្រតិភូក្រសួងអប់រំ និងកីឡាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

មានការចាប់អារម្មណ៍យ៉ាងខ្លាំងពីក្រសួងអប់រំ និងកីឡារបស់សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវលើការកែទម្រង់សាលារៀនជំនាន់ថ្មី។ នៅខែកុម្ភៈ ឆ្នាំ២០១៨ ប្រតិភូរបស់ក្រសួងអប់រំប្រទេសឡាវបានធ្វើទស្សនកិច្ចនៅសាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រះស៊ីសុវត្ថិ និងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដើម្បីស្វែងយល់អំពីសមិទ្ធិផលកំណែទម្រង់ទាំងនេះ។ ដំណើរទស្សនកិច្ចនេះត្រូវបានឧបត្ថម្ភដោយមូលនិធិគ្រួសារ Franks ដែលជាដៃគូដ៏សំខាន់មួយរបស់អង្គការ ខេប បានផ្តល់ការគាំទ្រដ៏ធំធេងសម្រាប់កិច្ចខិតខំប្រឹងប្រែងតស៊ូមតិទាក់ទងនឹងកំណែទម្រង់ថ្មីរបស់សាលារៀនជំនាន់ថ្មី។ តំណាងក្រសួងអប់រំ និងកីឡាប្រទេសឡាវក៏បានពិសាអាហារពេលល្ងាចជាមួយឯកឧត្តម អ៊ឹម កុច រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលខុសត្រូវចំពោះកំណែទម្រង់សាលារៀនជំនាន់ថ្មី។ ការពិភាក្សារវាងសមភាគីកម្ពុជា និងឡាវប្រកដដោយផ្លែផ្កា ហើយនឹងពង្រីកកំណែទម្រង់ទាំងនេះទៅប្រទេសឡាវ ដែលរំពឹងថានឹងចាប់ផ្តើមនៅឆ្នាំ២០១៩។

## កម្មវិធីរាត្រីជួបឪពុកម្តាយ



*សិស្សវិទ្យាល័យ ព្រែកអញ្ចាញ ធ្វើការបង្ហាញ អំពីគម្រោងផលិតម៉ាស៊ីនព្រីនធ័រ ស្រ៊ីឌី (3D Printer)*

មកដល់បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បានគាំទ្រកំណែទម្រង់សាលារៀនជំនាន់ថ្មីអស់រយៈពេលបីឆ្នាំហើយ។ ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៨ សាលារៀនជំនាន់ថ្មីទាំងអស់បានរៀបចំកម្មវិធីរាត្រីជួបឪពុកម្តាយ។ ជារៀងរាល់ឆ្នាំ ការតាំងពិព័រណ៍ស្នាដៃសិស្សទទួលបានភាពល្អប្រសើរឡើងជាងមុន។ ឪពុកម្តាយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងអំពីអ្វីដែលកូនៗរបស់ពួកគាត់កំពុងរៀន។ កម្មវិធីនេះត្រូវបានរៀបចំឡើងនៅពេលល្ងាច ដើម្បីឱ្យឪពុកម្តាយដែលធ្វើការនៅពេលថ្ងៃអាចមកទស្សនាសាលារៀនកូនគាត់បានដោយមិនចាំបាច់ឈប់សំរាកពីការងារ។ សាលារៀននីមួយៗបានធ្វើការងារដ៏អស្ចារ្យក្នុងការរៀបចំកម្មវិធីនេះ ក៏ដូចជាជួយសិស្សឱ្យរៀបចំគម្រោងពួកគាត់ រួមមាន៖ ការពិព័រណ៍វិទ្យាសាស្ត្រ សៀវភៅនិពន្ធ ខ្សែភាពយន្ត និងហ្គេមអេឡិចត្រូនិច ដែលពួកគាត់បានបង្កើត និងផលិតអ្វីៗជាច្រើនទៀត។ ក្នុងកម្មវិធីនេះ សិស្សបានលក់ផលិតផលពួកគាត់មួយចំនួន ដូចជា៖ ទៀនដែលពួកគាត់បានធ្វើនៅក្នុងថ្នាក់គីមីវិទ្យា ឬអាហារបម្រុងទុក ដែលពួកគាត់បានសិក្សាពីរបៀបធ្វើនៅក្នុងថ្នាក់ជីវវិទ្យា។ កម្មវិធីនេះបានជួយបញ្ចូលគ្នានូវ '**សហគ្រិនភាព**' ដែលសិក្សាពេលជាមួយគ្នាក្នុងការជួយដល់ក្លឹបផ្សេងៗដើម្បីរកប្រាក់ខ្លះសម្រាប់សកម្មភាពនាពេលអនាគត។ ជាសរុបមានជាង២៣១គម្រោងត្រូវបានបង្កើតឡើងដោយសិស្សនៅប្រាំកន្លែង (រួមទាំងបឋមសិក្សាមួយចំនួន)។ ព័ត៌មានបន្ថែមអំពីព្រឹត្តិការណ៍ទាំងនេះ អាចរកបាននៅលើគេហទំព័រអង្គការ ខេប និងតំណភ្ជាប់ខាងក្រោម៖ https://youtu.be/Q41GBfq3qq8។

## គំនិតថ្មីៗដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ




*ការបង្កើតបរិបទនៃការប្រើប្រាស់កម្មវិធីសុសវ៉ែរ អំណាន និងសរសេរ ឱ្យមាននៅក្នុងបណ្ណាល័យសាលាគម្រោង TRAC III : បច្ចុប្បន្នកម្មវិធីសុសវ៉ែរអំណាន និងសរសេរជាច្រើនត្រូវបានបង្កើតឡើងដោយអង្គការ ខេប និងដំឡើងនៅក្នុងបណ្ណាល័យសាលាគាំទ្រដោយអង្គការ ខេប ទូទាំងប្រទេស។ និមិត្តសញ្ញាកម្មវិធីទាំងនេះបង្ហាញនៅខាងស្តាំ។ ពីឆ្វេងទៅស្តាំ រួមមាន Sorse Khmer (កម្មវិធីសរសេរខ្មែរ)។ Ann Khmer (កម្មវិធីអានខ្មែរសម្រាប់ថ្នាក់ទី១) និង Smartbooks (កម្មវិធីសៀវភៅឆ្លាតសម្រាប់ថ្នាក់ទី២*

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គការ ខេប បានបង្កើតកម្មវិធីសុសវ៉ែរផ្នែកអប់រំថ្មីៗជាច្រើនដែលត្រូវនឹងបរិបទសិក្សានៅកម្ពុជា។ កម្មវិធីទាំងនេះ រួមមាន៖ អានខ្មែរសម្រាប់ថ្នាក់ទី១ សៀវភៅឆ្លាត (រចនាឡើងសំរាប់ថ្នាក់ទី២ និងទី៣) និងសរសេរខ្មែរដែលគាំទ្រដល់កុមារតូចៗក្នុងការសរសេរអក្សរខ្មែរ។ បច្ចុប្បន្ន កម្មវិធីទាំងនេះអាចរកបាននៅលើ PlayStore ហើយកំពុងដាក់បញ្ចូលទៅក្នុងគម្រោងជាច្រើនដែលគាំទ្រដោយម្ចាស់ជំនួយ និងអង្គការដៃគូផ្សេងៗ ដូចជា៖ អង្គការឆាលហ្វាន អង្គការ WeWorld មូលនិធិ Phoenix និងដៃគូដទៃៗទៀត។



*សិស្សវិទ្យាល័យ ព្រែកអញ្ចាញ ប្រើប្រាស់កម្មវិធី X-Reading ដើម្បីពង្រឹងជំនាញអំណានរបស់ខ្លួន។*

នៅក្នុងឆ្នាំ២០១៨ អង្គការ ខេប បានបង្កើតនូវរបកគំហើញថ្មីបន្ថែមទៀតក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើនការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ។ ក្នុងករណីសិក្សាភាសាអង់គ្លេស បច្ចុប្បន្ននេះ សាលារៀនជំនាន់ថ្មីកំពុងសាកល្បងនូវអ្វីដែលគេស្គាល់ថា អំណានសេរី ″**Extensive Reading**”។ ក្នុងពេលថ្មីៗនេះ មានការសិក្សាមួយបង្ហាញថា នៅពេលដែលសិស្សអានភាសាអង់គ្លេសបានជាង ៥០០.០០០ពាក្យក្នុងមួយឆ្នាំ ពិន្ទុភាសាអង់គ្លេសពួកគាត់មានការកើនឡើងយ៉ាងខ្លាំង។ កម្មវិធីថ្មីនេះអនុញ្ញាតឱ្យសិស្សអានសៀវភៅជាភាសាអង់គ្លេសអេឡិចត្រូនិចតាមអ៊ិនធឺណែត និងធ្វើតេស្តអេឡិចត្រូនិចផ្សារភ្ជាប់ទៅនឹងសៀវភៅនីមួយៗដោយប្រើប្រាស់កម្មវិធីសុសវ៉ែរដែលគេស្គាល់ថា **X-Reading**។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងនៅក្នុងប្រទេសជប៉ុន ហើយឥឡូវនេះត្រូវបានណែនាំនៅសាលារៀនដែលគាំទ្រដោយអង្គការ ខេប។ សិស្សទាំងអស់នៅក្នុងថ្នាក់ត្រូវបានចុះឈ្មោះក្នុងប្រព័ន្ធ ដូច្នេះ ពិន្ទុធ្វើតេស្តសិស្ស សៀវភៅដែលសិស្សអាន និងចំនួនពាក្យអានសរុបត្រូវបានដាក់បញ្ចូលឱ្យគ្រូដោយស្វ័យប្រវត្តិ។ បច្ចុប្បន្ននេះ មានសិស្សជាង ៣០០នាក់កំពុងចូលរួមក្នុងកម្មវិធីសាកល្បងនេះនៅសាលារៀនជំនាន់ថ្មីចំនួន ៥ កន្លែងគឺនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តស្វាយរៀង។

ជាមួយគ្នានេះដែរ អង្គការ ខេប បានធ្វើការជាមួយអង្គការដៃគូ **InSTEDD** ដើម្បីអភិវឌ្ឍន៍ការសរសេរកូដកម្មវិធីសិក្សាធ្វើឱ្យសិស្សអនុវិទ្យាល័យបង្កើតកូដកម្មវិធីមនុស្សយន្តបាន។ មនុស្សយន្តចំនួនពីរត្រូវបានចែកចាយទៅរាល់សាលារៀនជំនាន់ថ្មីសម្រាប់ជួយសម្រួលដល់សមត្ថភាពសិស្សស្វែងយល់ថា តើកូដកុំព្យូទ័រដែលពួកគាត់សរសេរទាក់ទងនឹងម៉ាស៊ីនខាងក្រៅយ៉ាងដូចម្តេច? ការបំពាក់បរិក្ខារសាលារៀនដោយអាចបង្រៀនសរសេរកូដបាននាំឱ្យការអប់រំនៅកម្ពុជាមានស្តង់ដាខ្ពស់ បើប្រៀបធៀបនឹងសាលារៀនដទៃទៀតនៅក្នុងតំបន់។ https://www.khmertimeskh.com/50550978/bringing-ict-knowledge-into-the-classroom/?fbclid=IwAR2gnQf8UAkuqugXxL8JmxR0JI1q-EQOj5e4873RgafSaDmI5SxRc-Iuzhw

កម្មវិធីមួយផ្សេងទៀតដែលអង្គការ ខេប បានចាប់ផ្តើមក្នុងឆ្នាំ២០១៨ សំដៅលើការបន្តកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្មវិធីដែលអាចកំណត់នូវ "**សមត្ថភាពអាន**" អត្ថបទភាសាខ្មែរ។ រូបមន្តអំណានត្រូវបានគេប្រើជាទូទៅនៅក្នុងភាសាអង់គ្លេស និងភាសាបស្ចឹមប្រទេសដើម្បីបង្ហាញពីអត្ថបទពិបាក ដូច្នេះ គ្រូអាចផ្គូផ្គងសម្ភារអំណានបានយ៉ាងត្រឹមត្រូវជាមួយកម្រិតសិស្ស។ កម្មវិធីសុសវ៉ែរនេះមានតម្លៃធំធេងដល់អ្នកអប់រំកម្ពុជា ដែលកំពុងអភិវឌ្ឍសៀវភៅសិក្សា និងសៀវភៅបណ្ណាល័យសម្រាប់បឋម និងមធ្យមសិក្សា។ កម្មវិធីសុសវ៉ែរនេះកំពុងត្រូវបានអភិវឌ្ឍន៍ឡើងតាមរយៈជំនួយពីអង្គការឆាលហ្វានកម្ពុជា ហើយនឹងរួចរាល់នៅឆ្នាំ២០១៩។

ជាចុងក្រោយ អង្គការ ខេប និងអង្គការដៃគូ **InSTEDD** អាចបញ្ចប់ការបង្កើតកម្មវិធីប្រឹក្សាអេឡិចត្រូនិចដែលហៅថាត្រីវិស័យ (**Trey Visay**) នឹងជួយដល់សាលាមធ្យមសិក្សាដើម្បីផ្តល់សេវាប្រឹក្សាអាជីពដល់សិស្ស ជាពិសេស ពេលពួកគាត់បញ្ចប់ការសិក្សា។ អំឡុងឆ្នាំនេះ សុសវ៉ែរត្រូវបានបង្ហាញដល់ក្រសួងអប់រំ យុវជន និងកីឡា ហើយនឹងអនុម័តប្រើប្រាស់ទូទៅនៅតាមសាលារដ្ឋទាំងអស់។ នេះគឺជារបកគំហើញដ៏សំខាន់មួយដើម្បីកែលម្អគុណភាពអប់រំនៅកម្រិតមធ្យមសិក្សា។



*ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីអប់រំ យុវជន និងកីឡា និងតំណាងអង្គការ ខេប លោកស្រី **ហ៊ឹម ម៉ារី** នៅខាងឆ្វេងឯកឧត្តម បានបំពេញព័ត៌មានលម្អិតសម្រាប់ការអនុម័តកម្មវិធី **Trey Visay** នៅក្នុងសាលារដ្ឋ។*

# ធីធីអូ អ៊ីមផត អិចផត ឯ.ក

*"សម្ភារៈជំនួយការសិក្សាដែលមានប្រសិទ្ធភាព និងតម្លៃសមរម្យ"*

## សេចក្តីសង្ខេប

### អំពីយើង

ធីធីអូជាក្រុមហ៊ុនក្នុងស្រុក ផលិតនិងចែកចាយសម្ភារបង្រៀន និងរៀនទាំងក្នុងនិងក្រៅថ្នាក់។

### ផលិតផល

- ល្បែងសិក្សាគណិតវិទ្យា ១៣
- ល្បែងសិក្សាភាសា ៣២
- ល្បែងសិក្សាវិទ្យាសាស្ត្រ ២
- ទម្រង់វាយតម្លៃអំណាន ៣ កម្រិត

### ទទួលស្គាល់

ផលិតផលទទួលស្គាល់ និងបានប្រកាសអនុញ្ញាតបោះពុម្ពផ្សាយ ដោយក្រសួងអប់រំ យុវជននិងកីឡា។



សម្ភារៈជំនួយបង្រៀន និងរៀននៅក្នុងបណ្ណាល័យ







ការពិពណ៌សៀវភៅថ្នាក់ជាតិនៅក្នុងឆ្នាំ ២០១៨នេះ។

ធនធានអប់រំបានបន្តតួនាទីល្អ និងជាគំរូក្នុងការប្រើប្រាស់គោលការណ៍វិស័យឯកជនដើម្បីឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព។



សកម្មភាពតម្រង់ទិសគ្រូបង្រៀន



ផែនការអាជីវកម្មរបស់ធនធានអប់រំត្រូវបាន
អភិវឌ្ឍឡើងជាក្រុម។

ព័ត៌មានលម្អិតបន្ថែមនៅលើគេហទំព័រធនធានអប់រំ: **www.tts-kape.org**
និងចុច **"Like"** និងចុច **"Share"** បណ្តាញសង្គម Facebook របស់យើង: www.facebook.com/ttskape។

# គម្រោង សាលារៀនជំនាន់ថ្មី (NGS)

*“ ជាសាលាជម្មនុញ្ញដំបូងបំផុតនៅក្នុងប្រទេសកម្ពុជា ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិគ្រួសារត្រកូលហ្វ្រែង (FFF) |
| **អ្នកទទួលផលផ្ទាល់** | សិស្សមធ្យម ២.៣១២នាក់<br>សិស្សបឋម ១.៣៧០នាក់<br>សិស្សសរុប ៣.៦៨២នាក់ |
| **ថវិកាទទួលបានក្នុងឆ្នាំ២០១៨** | ១,៧ លានដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ៤៦២ ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | ៤ (ភ្នំពេញ កំពង់ចាម កំពង់ស្ពឺ កណ្តាល) |
| **ចំនួនស្រុកគ្របដណ្តប់** | ៦ |
| **មធ្យមសិក្សាគោលដៅ** | ៥ |
| **បឋមសិក្សាគោលដៅ** | ៣ |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ តុលា ២០១៥ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | បើកចំហរ (មិនកំណត់) |

## បច្ចុប្បន្នភាពគម្រោង

នៅក្នុងឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើឱ្យអង្គការ ខេប ពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីទៅវិទ្យាល័យមួយទៀតមានឈ្មោះថា វិទ្យាល័យ ពាមជីកង ក្នុងខេត្តកំពង់ចាម និងសាលាបឋមសិក្សាពីរទៀត ដែលកើនចំនួនសាលារៀនជំនាន់ថ្មីដល់ចំនួន ៨សាលា គាំទ្រហិរញ្ញប្បទានដោយរដ្ឋាភិបាល។ សាលារៀនទាំង ៨ បានចាប់ផ្តើមដំណើរការក្នុងឆ្នាំនេះ ដែលគម្រោងបានវិនិយោគលើបរិក្ខាធំៗចំនួន ៦៨មុខ រួមមាន៖ បន្ទប់រៀនទំនើប បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យជាដើម។ល។ គ្រូបង្រៀនថ្មីជាង ១០០នាក់ ត្រូវបានជ្រើសរើសចូលបម្រើការងារក្នុងកម្មវិធី ហើយទទួលបានការតម្រង់ទិសស្តីពីគោលនយោបាយគម្រោង និងផ្តល់វគ្គបណ្តុះបណ្តាល និងបញ្ចូលក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជំនាញគ្រូបង្រៀន ដើម្បីធានាឱ្យមានការតាមដានរំលឹកជាបន្តក្នុងពេលសិក្ខាសាលា។

អង្គការ ខេប បានបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មី ដែលជាមគ្គុទេសជាក់ស្តែងចំពោះវិធីសាស្រ្តរក្សា និងអនុវត្តកម្មវិធីសាលាជំនាន់ថ្មី។ ឯកសារនេះកំណត់និយមន័យសាលាជំនាន់ថ្មីក្នុងលក្ខខណ្ឌប្រតិបត្តិ ហើយអាចឱ្យម្ចាស់ជំនួយដទៃទៀតធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតទីតាំងសាលារៀនជំនាន់ថ្មីបន្ថែមនៅក្នុងក្របខ័ណ្ឌស្តង់ដា។ អង្គការ ខេប ទទួលយកសេចក្តីណែនាំប្រតិបត្តិដែលក្រសួងអប់រំយុវជននិងកីឡាបានអនុម័តនៅក្នុងឆ្នាំ២០១៩។

## ព្រឹត្តការណ៍សំខាន់ៗ

- សិស្សមកពីវិទ្យាល័យ ព្រះស៊ីសុវត្ថិ និងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ សាលាទាំងពីរនេះទទួលបានលទ្ធផលលើសពីមធ្យមភាគថ្នាក់ជាតិ ដែលវិទ្យាល័យ ព្រះស៊ីសុវត្ថិ មានអត្រាសិស្សប្រឡងជាប់ ៨៩% ចំណែកវិទ្យាល័យ ហ៊ុន សែន កំពង់ចាម មានអត្រាសិស្សប្រឡងជាប់ ៧៥%។
- គោលការណ៍ណែនាំប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មីបានបំពេញដោយជោគជ័យ។
- សាលារៀនជំនាន់ថ្មីទទួលបានមេដាយមាស ប្រាក់ និងមេដាយសំរឹទ្ធចំនួន ១២៨ នៅក្នុងឆ្នាំ២០១៨នេះ។
- សេចក្តីណែនាំស្តីពីការបង្ហាញកម្មវិធីសិក្សាសរសេរកូដកុំព្យូទ័រនៅទីតាំងសាលារៀនជំនាន់ថ្មី។
- អង្គការ ខេប បានកែសម្រួលក្របខណ្ឌម៉ាទ្រីកសាលារៀនជំនាន់ថ្មី ដើម្បីទទួលបានលទ្ធផលល្អប្រសើរ។

## សន្និទានភាពនៃកម្មវិធី

សាលារៀនជំនាន់ថ្មីជាកម្មវិធីកំណែទម្រង់ថ្មី ដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ២០១៥ ដើម្បីបង្កើតឲ្យមានសាលារៀនរដ្ឋ ″ស្វយ័ត″ មានសិទ្ធិច្នៃប្រតិដ្ឋបង្កើតថ្មី និងលើកកម្ពស់គុណភាពអប់រំ។ សាលារៀនជំនាន់ថ្មីមានបុព្វសិទ្ធិទទួលបានមូលនិធិវិនិយោគខ្ពស់អាស្រ័យលើស្តង់ដាអភិបាលកិច្ច និងវិជ្ជាជីវៈខ្ពស់។ គន្លងអភិវឌ្ឍន៍ថ្មីនេះព្យាយាមជំរុញគ្រឹះស្ថានសិក្សាសាធារណៈឱ្យឈានខ្ពស់មួយកម្រិតទៀត ដើម្បីសម្រេចបាននូវស្តង់ដាអប់រំអតិបរមា ជាពិសេសចំពោះមុខវិជ្ជាស្ទែម(**STEM**)។ ស្ថិតក្រោមគោលនយោបាយថ្មីដែលកំណត់និយមន័យសាលារៀនជំនាន់ថ្មី ក្រសួងបានធ្វើការប្តេជ្ញាចិត្តខ្លាំងដើម្បីធ្វើការវិនិយោគប្រកដដោយប្រសិទ្ធភាពខ្ពស់ដល់សាលារៀនបែបនេះក្រោមលក្ខខណ្ឌដែលសាលាត្រូវធានាឱ្យបាននូវស្តង់ដាអភិបាលកិច្ចល្អ។ ជាមួយតម្រូវការប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាពអប់រំយ៉ាងតឹងរ៉ឹងផ្សារភ្ជាប់នឹងការវិនិយោគបន្ត គោលនយោបាយថ្មីបានលើកទឹកចិត្តដល់សាលាឱ្យប្រកាន់ខ្ជាប់នូវបទដ្ឋានអប់រំខ្ពស់។ សាលារៀនជំនាន់ថ្មីអនុវត្តតាមគំរូពីប្រទេសផ្សេងៗ ដែលសាលារៀនរដ្ឋមួយចំនួនទទួលបានស្វ័យភាពពេញលេញពីរដ្ឋក្នុងការច្នៃប្រតិដ្ឋកម្មវិធីអប់រំ។ ចំណុចនេះគឺសំដៅពិសេសទៅលើចលនា ″**សាលារៀនជម្មនុញ្ញ**″ ឬ **Charter School** នៅសហរដ្ឋអាមេរិក និងប្រទេសដទៃទៀត។ ក្រសួងមានគោលបំណងបង្កើតសាលារៀនជំនាន់ថ្មីយ៉ាងតិចចំនួន៥០សាលាក្នុងរយៈពេល១០ឆ្នាំទៀត។

## សកម្មភាពសំខាន់ៗ

- ការបង្កើតសេចក្តីណែនាំគោលការណ៍ប្រតិបត្តិសាលារៀនជំនាន់ថ្មីដោយជោគជ័យ នឹងអនុម័តប្រើប្រាស់ និងផ្សព្វផ្សាយនៅក្នុងឆ្នាំ២០១៩។
- ការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីទៅអនុវិទ្យាល័យផ្សេងមួយទៀត និងសាលាបឋមសិក្សាចំនួនពីរ ដែលសរុបមានចំនួនដល់ ៨សាលាត្រូវឧបត្ថម្ភគាំទ្រដោយក្រសួង។
- ការទទួលស្គាល់គុណភាពអប់រំសាលារៀនជំនាន់ថ្មីពីរ (វិទ្យាល័យ ព្រះស៊ីសុវត្ថិ និងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម)។
- ការបំពេញបរិក្ខាថ្មីទាំង ៦៨ រួមមាន៖ ថ្នាក់រៀនសាលារៀនជំនាន់ថ្មី បណ្ណាល័យសតវត្សរ៍ទី២១ បន្ទប់សង្គ្រោះបឋម មជ្ឈមណ្ឌលយុវជន និងសាលប្រជុំ។







## ការពង្រីកប្រព័ន្ធសាលារៀនជំនាន់ថ្មីនៅបឋមសិក្សា

នៅក្នុងឆ្នាំ២០១៧ នាយកដ្ឋានបឋមសិក្សាបានចាប់ផ្តើមធ្វើការជាមួយអង្គការ ខេប ដើម្បីជួយពង្រីកកំណែទម្រង់សាលារៀនជំនាន់ថ្មីផ្នែកបឋមសិក្សា។ ក្នុងឆ្នាំ២០១៨ ថវិកាសាលារៀនចំនួន ៣០០.០០០ដុល្លាអាមេរិក ត្រូវបានផ្តល់ឱ្យអង្គការ ខេប តាមរយៈនាយកដ្ឋានដើម្បីបង្កើតសាលារៀនជំនាន់ថ្មី២ គឺសាលាបឋមសិក្សា អគ្គមហេសី ក្នុងខេត្តកំពង់ស្ពឺ និងសាលាបឋមសិក្សា អង្គរបាន ក្នុងខេត្តកំពង់ចាម។ កម្មវិធីនេះបានដាក់ដំណើរក្នុងសាលាទាំងពីរក្នុងឆ្នាំសិក្សា ២០១៨-២០១៩ ដូចគ្នា។

# គម្រោង សាលារៀនជំនាន់ថ្មី (NGSI)

*" ជាសាលាជម្នេញនាំមុខគេបំផុតនៅក្នុងប្រទេសកម្ពុជា "*

## រូបភាពសកម្មភាព



**← មជ្ឈមណ្ឌលយុវជន:** មជ្ឈមណ្ឌលយុវជនថ្មីផ្ដល់សេវាដល់វិទ្យាល័យ ហ៊ុន សែន កំពង់ចាម សម្រាប់ប្រឹក្សាយោបល់ និងជួបជុំក្រុមប្រឹក្សាកុមារ។ មជ្ឈមណ្ឌលគ្រោងបង្កើតគ្រប់សាលារៀនជំនាន់ថ្មីទាំងអស់។



**← ការច្នៃប្រតិដ្ឋថ្មីក្នុងការបង្រៀនភាសាអង់គ្លេស:** គ្រូនៅវិទ្យាល័យព្រែកអញ្ចាញ បានចុះឈ្មោះសិស្សប្រព័ន្ធអេឡិចត្រូនិចដែលមានឈ្មោះថា X -reading ។ បច្ចុប្បន្ន សាលារៀនជំនាន់ថ្មីបានណែនាំអំពីការពង្រីកអំណានភាសាអង់គ្លេសតាមបច្ចេកទេសសិក្សាថ្មីដល់សាលារៀនទាំងអស់។

**បណ្ណាល័យសតវត្សរ៍ទី២១:** *អង្គការ ខេប បានបន្តបង្កើតបណ្ណាល័យដែលមានបរិក្ខាដ៏ទំនើបៗ ដូចជា បណ្ណាល័យសាលាព្រែកលៀប។ ➔*



## លក្ខណៈកម្មវិធី

## សាលារៀនជំនាន់ថ្មី....

### សេវាផ្ដល់សិទ្ធិអំណាចយុវជន

គោលការណ៍ផ្ដល់សិទ្ធិអំណាចដល់យុវជន ដែលប្រកាសដោយគោលនយោបាយជាតិអភិវឌ្ឍន៍យុវជនដើរតួនាទីសំខាន់ក្នុងគំរូសាលារៀនជំនាន់ថ្មី។ គោលការណ៍ផ្ដល់សិទ្ធិដល់យុវជនបានស្តែងឱ្យឃើញតាមរយៈជម្រើសសិស្សសម្រាប់មុខវិជ្ជាបន្ថែម ដែលសិស្សប្រាថ្នារៀនសូត្រ សមាជិកក្លឹបដោយស្ម័គ្រចិត្ត ហើយផ្ដល់អំណាចដល់ក្រុមប្រឹក្សាយុវជន ដែលជួយនាយកសាលាក្នុងការគ្រប់គ្រងសាលារៀន។ សេវាប្រឹក្សាអាជីពសម្រាប់យុវជន ដើម្បីធានាថា ការសម្រេចចិត្តរបស់យុវជនអំពីផែនការអាជីពទៅអនាគតគឺជាការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងដោយឆ្លាតវៃ។

### សេវាពិសេសសម្រាប់សិស្ស

សាលារៀនជំនាន់ថ្មីផ្ដល់សេវាថ្មីៗដល់សិស្ស ដែលសេវាទាំងនេះពុំមាននៅក្នុងសាលារៀនរដ្ឋទូទៅទេ រួមមាន៖ *បណ្ណាល័យអេឡិចត្រូនិចសតវត្សរ៍ទី២១ សេវាប្រឹក្សា ក្លឹបមុខវិជ្ជា ការអប់រំបំណិនជីវិត ការវាយតម្លៃតាមអេឡិចត្រូនិច ការសិក្សាតាមកម្មវិធីសុសវែរ សិស្សដែលដឹកនាំដោយក្រុមប្រឹក្សាយុវជន* ។



**↑ ការបង្កើតបន្ទប់សង្គ្រោះបឋម:** *ហិរញ្ញប្បទានក្រសួងអប់រំត្រូវបានប្រើប្រាស់សម្រាប់បង្កើតបន្ទប់សង្គ្រោះបឋមពីរ គឺមួយនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ និងមួយទៀតនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដើម្បីផ្ដល់សេវាសុខភាពដល់សិស្សក្នុងម៉ោងសិក្សា។ បន្ទប់សង្គ្រោះនេះមានបុគ្គលិកជាគិលានុបដ្ឋាយិកាធ្វើការពេញម៉ោង ឆ្លើយតបនឹងតម្រូវការជំនួយសង្គ្រោះជំងឺស្រាលៗ ដូចជា៖ ឈឺក្បាល វិលមុខ និងឈឺពោះ។*



**↑ សិស្សមកពីវិទ្យាល័យ ព្រះស៊ីសុវត្ថិ បង្ហាញមេដាយ៖** *សិស្សសាលារៀនជំនាន់ថ្មីជាច្រើននាក់បានចូលរួម និងតំណាងប្រទេសកម្ពុជានៅក្នុងព្រឹត្តិការណ៍អន្តរជាតិជាច្រើន។ មកដល់បច្ចុប្បន្ននេះ ពួកគាត់បានឈ្នះមេដាយមាស មេដាយប្រាក់ និងមេដាយសំរឹទ្ធចំនួន១២៨ពីប្រទេសសិង្ហបុរី ឥណ្ឌូនេស៊ី និងហ្វីលីពីន។ ព្រឹត្តិការណ៍ខ្លះក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះជាកម្មវិធីអូឡាំព្យាត ព្រឹត្តិការណ៍ដទៃទៀតជាកម្មវិធីពិព័រណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលសិស្សត្រូវធ្វើបទបង្ហាញអំពីគម្រោង និងការស្រាវជ្រាវរបស់ខ្លួន ដែលជាការងារមួយផ្នែកនៃការសិក្សាជាប្រចាំរបស់ពួកគាត់នៅសាលា។ សមត្ថភាពសិស្សសាលារៀនជំនាន់ថ្មីដែលទទួលបាននូវរង្វាន់លើកទឹកចិត្តច្រើននេះគឺជាម៉ែត្រវាស់សំខាន់មួយអំពីផលជះរបស់កម្មវិធីលើការសិក្សារបស់សិស្ស និងជាសក្ខីភាព សមត្ថភាពបង្កើតបរិស្ថានសិក្សាដែលលើកកម្ពស់ការគិតពិចារណាស៊ីជម្រៅ និងការច្នៃប្រតិដ្ឋថ្មី។*

# គម្រោង សាលារៀនជំនាន់ថ្មី (NGS) - ស្វាយរៀង

*“ ជាសាលាធម្មនុញ្ញដំបូងនៅក្នុងប្រទេសកម្ពុជា ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការឆាលហ្វានកម្ពុជា |
| **អ្នកទទួលផលផ្ទាល់** | សិស្សចំនួន ៧២១នាក់ |
| **ថវិកាទទួលបានក្នុងឆ្នាំ២០១៨** | ១៤៣.៩០០ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ២០០ ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | ស្វាយរៀង |
| **ចំនួនស្រុកគ្របដណ្តប់** | ស្វាយជ្រំ |
| **មធ្យមសិក្សាគោលដៅ** | ១(អនុវិទ្យាល័យ គោកព្រីង) |
| **បឋមសិក្សាគោលដៅ** | ១ (ស្វាយព្រហូត) |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ តុលា ២០១៦ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣០ មិថុនា ២០១៨ |

## សនិទានភាពនៃកម្មវិធី

កម្មវិធីសាលារៀនជំនាន់ថ្មីក្នុងខេត្តស្វាយរៀង ក៏ដូចគ្នាទៅនឹងកម្មវិធីឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលនៅកន្លែងដទៃទៀតផងដែរ។ ក្នុងន័យនេះ ការវិនិយោគសំខាន់ត្រូវផ្សារភ្ជាប់ទៅនឹងលក្ខខណ្ឌអនុវត្តល្អ និងអភិបាលកិច្ចល្អ។ NGS ស្វាយរៀងខុសពីកម្មវិធីគ្រប់គ្រងដោយរដ្ឋាភិបាល ដែលសាលារៀនទាំងនេះជ្រើសរើសវិនិយោគស្ថិតនៅទីតាំងក្នុងតំបន់ជនបទ។ គម្រោងសាកល្បងនេះគឺស្វែងរកគំនិតអំពីកម្មវិធីសាលារៀនជំនាន់ថ្មីអាចដាក់ដំណើរការនៅតំបន់ជនបទ ដែលផ្ទុយពីតំបន់ប្រជុំជន និងពាក់កណ្តាលប្រជុំជនដោយសារមានសិស្សកម្រិតមធ្យម និងក្រីក្ររស់នៅលាយគ្នា។ ការដាក់កម្មវិធីសាលារៀនជំនាន់ថ្មីនៅតំបន់ជនបទនេះពិតជាមានបញ្ហាប្រឈមច្រើន រួមមាន៖ ការពិបាកជ្រើសរើសគ្រូមានសមត្ថភាពខ្ពស់ លទ្ធភាពឪពុកម្តាយចូលរួមបដិភាគប្រតិបត្តិការកម្មវិធី ពិបាកបំពាក់អ៊ីនធឺណែត ភ្លើងអគ្គិសនី និងបញ្ហាដទៃៗទៀត។ លទ្ធផលសាកល្បងនេះមិនអាចសរុបកំណត់បាននៅឡើយ ប៉ុន្តែសាលាទាំងនេះគួរផ្តល់ការណែនាំដែលមានប្រយោជន៍ដល់ក្រសួងក្នុងការធ្វើយុទ្ធសាស្ត្រពង្រីកកម្មវិធីកំណែទម្រង់សាលារៀនជំនាន់ថ្មី។

## សកម្មភាពសំខាន់ៗ

គម្រោងសាលារៀនជំនាន់ថ្មី-ខេត្តស្វាយរៀងបានដំណើរការដល់ឆ្នាំទី ៣ និងបញ្ចប់ប្រតិបត្តិការក្នុងឆ្នាំ២០១៨នេះ។ ការវាយតម្លៃពីខាងក្រៅមួយបានរកឃើញថា ខណៈដែលអនុវិទ្យាល័យ គោកព្រីង និងបឋមសិក្សាស្វាយព្រហូត បានរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីមានការវិនិយោគមក សាលានេះនៅតែមិនទាន់ត្រៀមខ្លួនទទួលការវាយតម្លៃស្តីពីការទទួលស្គាល់គុណភាពអប់រំ ដែលនឹងនាំឱ្យមានការទទួលស្គាល់ជាផ្លូវការថាជាសាលាជំនាន់ថ្មី និងការគាំទ្រពីរដ្ឋាភិបាលដោយស្វ័យប្រវត្តិនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ជាការគួរឱ្យកត់សម្គាល់ ការវាយតម្លៃរកឃើញថា ទីតាំងសាលារៀនជំនាន់ថ្មីក្នុងខេត្តស្វាយរៀងបានខិតដល់ចំណុចដែលអាចទទួលស្គាល់គុណភាពអប់រំ និងអនុសាសន៍បន្ថែមវិនិយោគមួយឆ្នាំបន្ថែមទៀត ដោយសារនឹងមានដំណើរទស្សនកិច្ចសិក្សាជាផ្លូវការសម្រាប់ខែមិថុនា ឆ្នាំ២០១៩ ខាងមុខនេះ។

- ការបង្កើតក្រុមប្រឹក្សាភិបាល NGS ថ្នាក់ខេត្ត តាមគោលនយោបាយថ្មីរបស់សាលារៀនជំនាន់ថ្មីដើម្បីធានាឱ្យមានអភិបាលកិច្ចសាលាល្អ។
- បង្កើនបរិយាកាសសិក្សានៅសាលារៀនតាមរយៈការវិនិយោគលើការជួសជុលសាលារៀន ដែលប្រើប្រាស់ការរចនាម៉ូដថ្មីៗ និងទំនើប។
- សម្របសម្រួលការអភិវឌ្ឍវប្បធម៌អប់រំថ្មីដែលផ្តល់នូវរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់អភិវឌ្ឍគ្រូបង្រៀន បង្កើនម៉ោងបង្រៀន (៤០ម៉ោងក្នុងមួយសប្តាហ៍នៅកម្រិតអនុវិទ្យាល័យ និង ៣៤ម៉ោងក្នុងមួយសប្តាហ៍នៅកម្រិតបឋមសិក្សា) និងការប្រើប្រាស់បរិក្ខាសាលារៀនថ្មី (ឧ.បន្ទប់វិទ្យាសាស្ត្រ...។ល។)
- ជួយគ្រូបង្រៀនក្នុងការបង្កើនឋានៈខ្លួនដោយផ្តល់នូវអាហារូបករណ៍ទៅសិក្សាដើម្បីទទួលបានកម្រិតគុណភាព និងវិញ្ញាបនបត្រ។
- រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលថ្មីធានានូវកម្រិតខ្ពស់នៃអភិបាលកិច្ចសាលារៀនល្អ ដែលលើកកម្ពស់ការកែលម្អការវាស់វែងគុណភាព និងប្រសិទ្ធភាពអប់រំ។
- បរិស្ថានសិក្សាបានបំពេញតាមស្តង់ដាខ្ពស់សម្រាប់កុមារមេត្រី។
- វិធីសាស្ត្រសិក្សាថ្មីប្រើប្រាស់បច្ចេកវិទ្យាមានប្រសិទ្ធិភាព ដើម្បីបង្កើតការអប់រំមូលដ្ឋានក្នុងសតវត្សរ៍ទី២១ ក៏ដូចជាបង្កើនប្រសិទ្ធភាពសិក្សា។
- គ្រូបង្រៀនបង្ហាញពីកម្រិតសមត្ថភាពខ្ពស់ និងវិជ្ជាជីវៈដែលជាលទ្ធផលរចនាសម្ព័ន្ធលើកទឹកចិត្តថ្មី ដែលគេប្រើក្នុងវិស័យឯកជនជាទូទៅ។
- អនុវត្តការកែលម្អសំខាន់ៗដោយប្រើគោលការណ៍ទំនើបបំផុតក្នុងការរចនាសាលារៀន។



***ការពិព័រណ៌វិទ្យាសាស្ត្រ:*** *សិស្សពិព័រណ៌គម្រោងឆ្លុះបញ្ចាំងអំពីការសិក្សាស្រាវជ្រាវដែលពួកគាត់បង្កើតនៅក្នុងថ្នាក់វិទ្យាសាស្ត្រ។*



***ការអប់រំផ្នែកវិទ្យាសាស្ត្រ:*** *សិស្សសាលាគោកព្រីងសិក្សាអំពីមេរៀនថ្មពិល ស៊ីវគ្វីអគ្គិសនីនៅក្នុងថ្នាក់ ដែលសម្បូរទៅដោយគ្រឿងបរិក្ខា សម្ភារៈ និងរៀបចំដោយគ្រូដែលប្រើគោលការណ៍រៀនបែបសហការ។ ➔*



*← **ការបង្រៀន ICT:** បរិក្ខាកុំព្យូទ័រទំនើបៗនៅវិទ្យាល័យ គោកព្រីង បានសម្រួលឱ្យសិស្សបានរៀនកុំព្យូទ័រទៀងទាត់យ៉ាងតិច ២ម៉ោងក្នុង១សប្តាហ៍។ អភិបាលកិច្ចល្អរឹងមាំនៅសាលាបានធានាឱ្យបន្ទប់កុំព្យូទ័រ នេះបើកដំណើរការប្រចាំថ្ងៃ និងរក្សាថែទាំបានល្អ។*

# គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC)

*“ បង្កើនការលូតលាស់ជីវិតកុមារតាមរយៈសៀវភៅសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការមូលនិធិអាស៊ី |
| **អ្នកទទួលផលផ្ទាល់** | ៨៨.៥៩៧ ដុល្លាអាមេរិក |
| **ថវិកាបដិភាគទទួលបានឆ្នាំ២០១៨** | ២៨៣.៧២២,៣០ ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ៣,២០ ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | ៦ ខេត្ត |
| **ចំនួនស្រុកគ្របដណ្តប់** | ២៥ ស្រុក |
| **វិទ្យាស្ថានរដ្ឋាភិបាល និងសាកលវិទ្យាល័យគោលដៅ** | ២ |
| **អង្គការមិនមែនរដ្ឋាភិបាលគោលដៅ** | ២ អង្គការ |
| **អនុវិទ្យាល័យគោលដៅ** | ៧៥ សាលា |
| **បឋមសិក្សាគោលដៅ** | ៩ សាលា |
| **វិទ្យាស្ថានដទៃទៀត** | ១៣ វិទ្យាស្ថាន |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ មេសា ២០១៤ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣១ ធ្នូ ២០២២ |

## បច្ចុប្បន្នភាពគម្រោង

ក្នុងកំឡុងឆ្នាំ២០១៨ អង្គការ ខេប ទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជួយដល់កម្មវិធីសៀវភៅសម្រាប់កម្ពុជាពីការផ្តល់ជំនួយដោយរាជរដ្ឋាភិបាល។ កម្មវិធីបានបញ្ចប់ឆ្នាំទី៤របស់ខ្លួនក្នុងឆ្នាំ២០១៨នេះ ថវិកាដំណើរការទាំងអស់ត្រូវបានចំណាយដោយអង្គការមូលនិធិអាស៊ី។ យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងថ្មីជាមួយក្រសួងអប់រំ យុវជន និងកីឡា នឹងអនុញ្ញាតឱ្យគម្រោងចំណាយ ៣០% នៃថវិការបស់ក្រសួងក្នុងឆ្នាំ២០១៩នេះ ជាផ្នែកមួយនៃថវិកាចំណាយផ្សេងៗរបស់កម្មវិធីសាលារៀនជំនាន់ថ្មីដែលក្រសួងបានផ្តល់ដល់អង្គការ ខេប។ នៅឆ្នាំ២០២២ ក្រសួងនឹងគ្របដណ្តប់លើការចំណាយប្រតិបត្តិការរបស់គម្រោង ចំនួន ៨០% ខណៈដែល ២០% ទៀតនឹងត្រូវបានទទួលរ៉ាប់រងដោយអង្គការមូលនិធិអាស៊ី។ កិច្ចព្រមព្រៀងនេះគឺជារបកគំហើញដ៏សំខាន់មួយសម្រាប់គម្រោង BfC ដែលនឹងធានាបាននូវនិរន្តរភាពយូរអង្វែងនៃកម្មវិធីសៀវភៅ។

## ផលជះរបស់គម្រោង

**បង្កើតវប្បធម៌រៀន៖** BfC បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់បណ្ណារក្សដើម្បីធ្វើឱ្យងាយស្រួលសម្រាប់សិស្សានុសិស្ស ដើម្បីស្វែងរកសៀវភៅដែលពួកគេចាប់អារម្មណ៍អានបំផុត។ បណ្ណារក្សក៏ត្រូវបានទទួលការបណ្តុះបណ្តាលឱ្យរៀបចំក្រុមអានសម្រាប់កុមារតូចៗ និងសម្រួលដល់ការចូលប្រើសៀវភៅអេឡិចត្រូនិចដោយប្រើឧបករណ៍សិក្សាចល័តដែលផ្គត់ផ្គង់ដល់បណ្ណាល័យដោយកម្មវិធីផ្សេងទៀតរបស់អង្គការ ខេប។

**ការពង្រីកបណ្ណាល័យ៖** គម្រោង BfC បានផ្តល់នូវសៀវភៅអានជាច្រើនសម្រាប់សាលាដែលមានបណ្ណាល័យនាពេលប៉ុន្មានឆ្នាំមកនេះ។ ចាប់តាំងពីបានបង្កើតមក គម្រោងបានចែកចាយសៀវភៅ និងសម្ភារអានចំនួន ៥៨.៩៩៣ក្បាល/ឈុត ទៅដល់សាលារៀន និងបណ្ណាល័យសាធារណៈចំនួន ៣៨២។

**ការសម្លឹងមើលឆ្ពោះទៅខាងមុខ៖** នៅក្នុងឆ្នាំសិក្សា២០១៩ខាងមុខនេះ BfC ស្វែងរកការផ្លាស់ប្តូរជាយុទ្ធសាស្ត្រដើម្បីបានទៅដល់ខេត្តមួយចំនួនបន្ថែមទៀត។ គោលបំណងកម្មវិធីគឺដើម្បីឈានទៅដល់ខេត្តចំនួន៥ក្នុង១ឆ្នាំយ៉ាងតិច។ ក្នុងន័យនេះ សាលារៀនជំនាន់ថ្មីនឹងបន្តអាទិភាពជាចម្បងនៃកម្មវិធីតាមសំណើរបស់ក្រសួងអប់រំ។ លើសពីនេះទៀត BfC នឹងបន្តរៀបចំព្រឹត្តិការណ៍ប្រកួតការប្រកបពាក្យនៅតាមសាលារៀនបន្ថែមទៀត (យ៉ាងតិចពី ១៥ ទៅ ២០សាលាក្នុងមួយឆ្នាំ)។ ព្រឹត្តិការណ៍នេះនឹងលើកទឹកចិត្តសិស្សឱ្យរៀនភាសាអង់គ្លេសកាន់តែប្រសើរឡើង។ អនុស្សារណៈថ្មីនេះផ្តល់អាទិភាពដល់សាលាមធ្យមសិក្សាដែលគ្របដណ្តប់លើខេត្តក្រុងទាំង២៥ ក្នុងរយៈពេលប្រាំឆ្នាំ។

**ការត្រួតពិនិត្យបន្ថែម:** គម្រោងក៏នឹងបង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីបង្កើនការប្រើប្រាស់សៀវភៅអង់គ្លេសតាមរយៈការត្រួតពិនិត្យបន្ថែមទៀតពីសាលារៀន។ កម្មវិធីនេះកំពុងប្រើកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា៖ **Telegram** និង **Facebook** ដើម្បីចែករំលែកព័ត៌មាន ផ្តល់ភស្តុតាងរូបថតសកម្មភាពអាន និងរក្សាទំនាក់ទំនងញឹកញាប់ និងជាប្រចាំជាមួយសាលារៀន។

## គោលបំណង

អនុស្សារណៈថ្មីជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិអាស៊ីបានផ្តល់អាទិភាពដល់សាលាមធ្យមសិក្សា។ ក្រោមកិច្ចព្រមព្រៀងថ្មីនេះ BfC នឹងកំណត់ទិសដៅប្រាំខេត្តជារៀងរាល់ឆ្នាំដោយមានបំណងគ្របដណ្តប់ខេត្តក្រុងទាំង ២៥ ក្នុងរយៈពេលប្រាំឆ្នាំ។ គម្រោងនេះលើកកម្ពស់ការអានភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ប៉ុន្តែសៀវភៅមួយចំនួនអាចនៅតែមានសម្រាប់សាលាបឋមសិក្សា។

## សកម្មភាពសំខាន់ៗ

- គម្រោងសៀវភៅសម្រាប់កម្ពុជាបានចែកចាយសៀវភៅចំនួន ១៦.៤៨៣ក្បាល ក្នុងឆ្នាំសិក្សា ២០១៧-២០១៨។
- ការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំពីការប្រើប្រាស់សៀវភៅតាមរយៈប្រព័ន្ធតេឡេក្រាម និងបណ្តាញសង្គម។
- អ្នកគ្រប់គ្រងកម្មវិធីបានចងក្រងរបាយការណ៍លទ្ធផលវាយតម្លៃដោយភ្ជាប់ជាមួយអនុសាសន៍ជាក់ស្តែងចំពោះការគ្រប់គ្រងដើម្បីបង្កើនការប្រើប្រាស់សៀវភៅ។
- ក្រុមការងាររបស់អង្គការ ខេប ក៏បានលើកទឹកចិត្តដល់សាលារៀនគោលដៅដើម្បីលើកកម្ពស់សកម្មភាពអាន និងការប្រកួតការប្រកបពាក្យជាភាសាអង់គ្លេស តាមរយៈការផ្សព្វផ្សាយដល់មាតាបិតា និងគ្រូបង្រៀន ក៏ដូចជាការណែនាំបណ្ណាល័យប្រកបដោយការគិតគូរ។

## កម្មវិធីប្រកួតប្រកបពាក្យភាសាអង់គ្លេស

*គម្រោងបានធ្វើការប្រកួតការប្រកបពាក្យចំពោះសាលាជាង ៧នៅឆ្នាំនេះ។ គោលបំណងព្រឹត្តិការណ៍នេះដើម្បីលើកទឹកចិត្តសិស្សឱ្យរៀនភាសាអង់គ្លេសកាន់តែខ្លាំង និងកាន់តែប្រសើរឡើង។ សិស្សមានបំណងចង់ឱ្យមានព្រឹត្តិការណ៍នេះជាទៀងទាត់យ៉ាងហោចណាស់១លើកក្នុងមួយឆ្នាំ។* →





*គម្រោងស្វែងរកដើម្បីកំណត់ចំពោះសៀវភៅដែលមានគុណភាពខ្ពស់ ដែលអាចជំរុញការចាប់អារម្មណ៍ក្នុងការអាន និងស្រាវជ្រាវក្នុងចំណោមសិស្សានុសិស្សទាំងឡាយ។ នៅក្នុងរូបភាពនេះ សិស្សានុសិស្សត្រូវបានលើកទឹកចិត្តឱ្យអានសៀវភៅរួមគ្នាដើម្បីឱ្យពួកគេអាចបកស្រាយអត្ថន័យពាក្យដែលពួកគេជួបបានយ៉ាងងាយក្នុងម៉ោងចូលបណ្ណាល័យ។*

# គម្រោង ស្បៀងអាហារសម្រាប់ការអប់រំ (FFE)

*“ការលើកកម្ពស់បរិស្ថានសិក្សាដើម្បីការលូតលាស់កុមារ ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងកសិកម្មសហរដ្ឋអាមេរិក (USDA) អង្គការស្បៀងអាហារពិភពលោក អង្គការអប់រំពិភពលោក |
| **អ្នកទទួលផលផ្ទាល់** | គ្រូបង្រៀនថ្នាក់ទី១-៣ នៅក្នុង ៥០៣ សាលា |
| **ថវិកាបដិភាគទទួលបានឆ្នាំ២០១៨** | ១៧៥.៦១២ ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផលម្នាក់** | គ្មាន |
| **ខេត្តគ្របដណ្តប់** | ២ ខេត្ត (កំពង់ធំ និងសៀមរាប) |
| **ចំនួនស្រុកគ្របដណ្តប់** | ១៨ ស្រុក (៧ កំពង់ធំ ១១ សៀមរាប) |
| **បឋមសិក្សាគោលដៅ** | ៥០៣ សាលា (២០៥ សាលាក្នុងខេត្តកំពង់ធំ និង ២៩៨ សាលាក្នុងខេត្តសៀមរាប) |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ វិច្ឆិកា ឆ្នាំ២០១៦ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣១ តុលា ២០១៩ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង FFE បានប្រតិបត្តិការរយៈពេល២ឆ្នាំកន្លងផុតទៅហើយ ឥឡូវនេះនឹងចាប់ផ្តើមអនុវត្តឆ្នាំចុងក្រោយឆ្នាំ២០១៩នេះ។ គម្រោងបានប្រតិបត្តិការរួមគ្នាដោយអង្គការអប់រំពិភពលោក (WE) និងអង្គការ ខេប ផ្តោតលើការពង្រឹងអំណានថ្នាក់ដំបូង ដោយបញ្ចូលក្នុងសាលាដែលអនុវត្តកម្មវិធីស្បៀងអាហារពេលព្រឹកដែលគាំទ្រដោយក្រសួងកសិកម្មសហរដ្ឋអាមេរិក (USDA)។ អំឡុងឆ្នាំទីពីរនេះ គម្រោងបានពង្រីកបន្ថែមនូវចំនួនសាលាយ៉ាងច្រើនពីចំនួនសាលា២៧៥ក្នុងឆ្នាំទី១ ដល់៥០៣សាលាក្នុងពេលបច្ចុប្បន្ន។ ដោយសារការបណ្តុះបណ្តាលគ្រូបង្រៀនគឺជាធាតុដ៏សំខាន់របស់គម្រោង FFE គម្រោងបានព្យាយាមតម្រឹមសកម្មភាពបណ្តុះបណ្តាលរបស់ខ្លួនឱ្យត្រូវជាមួយនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (TPAP)។ ក្រេឌីតនិងវិញ្ញាបនបត្រនឹងត្រូវផ្តល់ឱ្យនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាល និងរៀបចំធ្វើតេស្តអំណានថ្នាក់ដំបូង (EGRA) ដែលបានរៀបចំដោយនាយកដ្ឋានបឋមសិក្សា។ ចាប់តាំងចាប់ផ្តើមក្រុមការងារគម្រោងបានបង្កើតសៀវភៅបណ្តុះបណ្តាល៥ម៉ូឌុលស្តីពីការបង្រៀនអំណាន ហើយបានយកទៅបណ្តុះបណ្តាលគ្រូចំនួន ២.៥៧៥នាក់នៅថ្នាក់ទី១ ដល់ទី៣។ ក្រុមការងារក៏បានផ្តល់ការបណ្តុះបណ្តាលដូចគ្នានេះដល់នាយកសាលាចំនួន ៧១៤នាក់ក្នុងចំណោមសាលាទាំងអស់ក្នុងគម្រោង ដូច្នេះ ពួកគាត់អាចផ្តល់នូវលក្ខខណ្ឌអភិបាលកិច្ចល្អ ដើម្បីជួយគាំទ្រដល់គរុកោសល្យថ្មី។ ការវាយតម្លៃអំណានថ្នាក់ដំបូង (EGRA) បានរៀបចំធ្វើចំនួន៧០សាលារៀន ដែលមានកិច្ចសហការរវាងសាលាគរុកោសល្យ និងវិក្រិតការខេត្ត និងមន្ទីរអប់រំ យុវជន និងកីឡា ទាំងក្នុងខេត្តកំពង់ធំ និងសៀមរាប។ ការវាយតម្លៃនេះធ្វើឡើងដើម្បីប្រៀបធៀបជាមួយលទ្ធផលតេស្តដែលបានធ្វើរួចកាលពីឆ្នាំមុន។

បន្ថែមលើសកម្មភាពកសាងសមត្ថភាព គម្រោង FFE ក៏បានផ្តល់នូវកញ្ចប់ធនធានអំណាន និងសម្ភារអានសំខាន់ៗដល់សាលារៀនចំនួន ៥០៣សាលាផងដែរ។ សម្រាប់សាលារៀនកម្រិតអភិវឌ្ឍដែលមានចំនួន ៣១សាលាបន្ថែមទៀត គម្រោងក៏បានផ្តល់ជូននូវសៀវភៅស្តង់ដាអំណាន ដែលបានអនុម័តថ្មីៗដោយក្រសួងអប់ រំយុវជន និងកីឡា (និងបានអភិវឌ្ឍដោយអង្គការ ខេប និងអង្គការអប់រំពិភពលោក) ក៏ដូចជាល្បែងសិក្សាពង្រឹងអំណាន (៣ហិបក្នុងមួយសាលា) ដែលរួមបញ្ចូលទាំងល្បែងសិក្សាទាក់ទាញជាច្រើនដែលជាប់ទាក់ទងនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជននិងកីឡា។ នៅឆ្នាំទី២ គម្រោងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយគម្រោងកុមាររៀនកុមារចេះ (ACRC) ដែលបានជំនួយពីពលរដ្ឋអាមេរិក (USAID) ផងដែរ។ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានស្រាវជ្រាវត្រីកោណដែលគ្រប់គ្រងដោយគម្រោង ACRC។ គម្រោង FFE បានផ្តល់នូវកញ្ចប់អំណានថ្នាក់ទី១ ដល់សាលាចំនួន ៧៣៥កញ្ចប់ដែលបង្កើតឡើងដោយអង្គការវិទ្យាស្ថានស្រាវជ្រាវត្រីកោណ(RTI) និងបានធ្វើការរួមគ្នាជាមួយគ្រូបង្គោលដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារសហរដ្ឋអាមេរិច (USAID) ដើម្បីធានានូវការអនុវត្តត្រឹមត្រូវ។

## សកម្មភាពសំខាន់ៗ

១. ការបណ្តុះបណ្តាលនាយកសាលា
២. ការធ្វើតេស្តវាយតម្លៃអំណានថ្នាក់ដំបូង (ថ្នាក់ទី២)
៣. ការអភិវឌ្ឍសៀវភៅបណ្តុះបណ្តាលគ្រូ និងការរៀបចំសិក្ខាសាលានៅទូទាំង ៥០៣ សាលាបឋមសិក្សា
៤. ការខិតខំលើកកម្ពស់អំណានថ្នាក់ដំបូងតាមរយៈការចែករំលែកសម្ភារសិក្សា និងល្បែងអំណាន។

## គោលបំណង

គោលបំណងគម្រោងស្បៀងអាហារសម្រាប់ការអប់រំ (FFE) គឺដើម្បីបង្កើនលទ្ធផលសិក្សាលើអំណានភាសារខ្មែរនៅថ្នាក់ដំបូង (ថ្នាក់ទី១ ដល់ទី៣)។ ដើម្បីសម្រេចគោលដៅនេះ គម្រោងកំពុងធ្វើការដើម្បីបង្កើនសមត្ថភាពរបស់អ្នកគ្រប់គ្រងសាលារៀន (នាយក និងនាយករង) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពអំណានថ្នាក់ដំបូងនៅសាលារៀនរបស់ពួកគាត់។ ជាពិសេសគម្រោងនេះសំដៅទៅការបង្កើតជំនាញ និងចំណេះដឹងរបស់គ្រូ និងបណ្ណារក្សក្នុងការប្រើប្រាស់វិធីសាស្ត្រគរុកោសល្យអំណានថ្នាក់ដំបូង (EGRA) ប្រកបដោយប្រសិទ្ធភាព។ ដើម្បីពង្រឹងអំណាន មានន័យថា ត្រូវប្រើប្រាស់សម្ភារសិក្សាថ្មីៗដែលបង្កើតឡើងដើម្បីពង្រឹងបំណិនអំណានកុមារឱ្យមានប្រសិទ្ធភាព។ FFE ក៏ស្វែងរកការគាំទ្រពីសាលាកម្រិតអភិវឌ្ឍន៍ផងដែរ ដើម្បីលើកកម្ពស់សកម្មភាពអំណានសម្រាប់កុមារនិងមាតាបិតា និងលើកកម្ពស់មនសិកាមាតាបិតា និងសហគមន៍ក្នុងការចូលរួមលើកកម្ពស់អំណានកុមារ។

## រូបភាពសកម្មភាព

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀន។





## ផលជះរបស់គម្រោង

ការរៀបចំតេស្តនៅថ្នាក់ទី២ នៅពេលថ្មីៗនេះត្រូវបានគេចាត់ទុកថាមានរបៀបរៀបរយជាប្រពន្ធ័ល្អជាង បើប្រៀបធៀបជាមួយនឹងឆ្នាំទី១ ទោះបីជាលទ្ធផលមិនទាន់អាចទទួលយកបានតាមគោលដៅ តែគម្រោងសង្ឃឹមថា នឹងមានការរីកចម្រើនជាងតេស្តមូលដ្ឋាន។

ក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ គម្រោងក៏បានបង្កើតនូវឯកសារបំប៉ន៤ម៉ូឌុលដែលផ្តោតទៅលើអំណានថ្នាក់ដំបូះ

**ម៉ូឌុលទី ១**: ការរៀនភាសា និងដំណើរការការអាន
**ម៉ូឌុលទី ២**: ការអភិវឌ្ឍន៍អំណានអាជីព
**ម៉ូឌុលទី ៣**: ការអភិវឌ្ឍភាសា - វិធីសាស្ត្រគ្រប់គ្រង (មានពីរវគ្គ)
**ម៉ូឌុលទី ៤**: ការវាយតម្លៃ និងការវិភាគការអនុវត្តការរៀនភាសា។

សៀវភៅទាំងនេះមានភាពងាយស្រួលប្រើ និងមានល្បែងទាក់ទាញជាច្រើនដើម្បីពង្រឹងការអនុវត្តគ្រូ។ គ្រូត្រូវបានលើកទឹកចិត្តក្នុងការកត់ត្រាការផ្លាស់ប្តូរការអនុវត្តការបង្រៀនរបស់ពួកគាត់ជាមួយរូបថត និងវីដេអូដែលពួកគេអាចចែករំលែកតាមរយៈបណ្តាញទំនាក់ទំនងសង្គម និងហ្វេសប៊ុក។ ទិន្នន័យដែលប្រមូលបានតាមរយៈការត្រួតពិនិត្យបានរកឃើញពីការផ្លាស់ប្តូរយ៉ាងសំខាន់ៗក្នុងការអនុវត្តរបស់គ្រូ។ លើសពីនេះទៀត នាយកសាលាចំនួន៤៨៤ នៃសាលារៀនចំនួន ៥០៣ បានប្រើប្រាស់ Kobo ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យដើម្បីជំរុញដល់គ្រូក្នុងការប្រើប្រាស់វិធីសាស្ត្រ FFE ដែលបានពីការពិភាក្សានៅក្នុងសិក្ខាសាលាបណ្តុះបណ្តាល។

# កម្មវិធីអប់រំបញ្ចូលគ្នា (IEP)

*"កម្មវិធីអប់រំបញ្ចូលគ្នា: លើកកម្ពស់សិទ្ធិអប់រំរវាងក្រុមជនជាតិ "*

**កម្មវិធីអប់រំបញ្ចូលគ្នា** ឬហៅកាត់ថា **IEP** មាន៤គម្រោងក្នុងឆ្នាំនេះ រួមមាន៖ គម្រោងអប់រំកុមារី គម្រោង STEM4Women កម្មវិធីអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច (ACCESS) និងគម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា។ កម្មវិធីនេះបង្កើតឡើងក្នុងគោលបំណងដើម្បីផ្តល់ឱកាសសិក្សា ជាពិសេស កុមារីជនជាតិខ្មែរ-ឥស្លាម ឬយុវជនងាយរងគ្រោះរាប់បញ្ចូលទាំងការប្រឹក្សាអាជីព និងការចូលទៅបម្រើការងារប្រកបដោយភាពជឿជាក់។

| | **គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា CTSP** | **គម្រោងអប់រំកុមារី (GEI)** | **គម្រោង STEM4Women** | **គម្រោង ACCESS** |
|---|---|---|---|---|
| **ម្ចាស់ជំនួយ** | អង្គការមូលនិធិអាស៊ី | អង្គការមូលនិធិអូកទ្រី | អង្គការមូលនិធិអូកទ្រី<br>អង្គការស្រី 100 អង្គការ CoH | ស្ថានទូតសហរដ្ឋអាមេរិក |
| **អ្នកទទួលផលផ្ទាល់** | សិស្សចំនួន ៣០នាក់ | សិស្សចំនួន ១.៥៥១នាក់ | សិស្សចំនួន ១១នាក់ | សិស្សចំនួន ៤០នាក់ |
| **ថវិកាទទួលបានក្នុងឆ្នាំ២០១៨** | ៤០.០១០ ដុល្លាអាមេរិក | ៨៦.៩៧៥ ដុល្លាអាមេរិក | ១៦.៤០០ ដុល្លាអាមេរិក | ១៨.៧៩០ ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ១.៣៣០ ដុល្លាអាមេរិក/១នាក់ | ៥៦ ដុល្លាអាមេរិក/១នាក់ | ១.៥០០ ដុល្លាអាមេរិក/១នាក់ | ៤៦៩,៧៥ ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងព្រៃវែង | កំពង់ចាម និងត្បូងឃ្មុំ | កំពង់ចាម សៀមរាប បន្ទាយមានជ័យ បាត់ដំបង និងកំពង់ធំ | ត្បូងឃ្មុំ |
| **ស្រុកគ្របដណ្តប់** | ១១ ស្រុក | ៩ ស្រុក | ៥ ស្រុក | ក្រូចឆ្មារ |
| **មធ្យមសិក្សាគោលដៅ** | គ្មាន | ១១ សាលា | គ្មាន | វិទ្យាល័យ ប៉ើសពីរ |
| **សាលាបណ្តុះបណ្តាលវិជ្ជាជីវៈគោលដៅ** | សាខាសាកលវិទ្យាល័យ វេស្ទើន ក្រុងកំពង់ចាម | វិទ្យាស្ថានគរុកោសល្យខេត្ត អង្គការប៉ាស៊ីហ្វិលនុយមេរិកកម្ពុជា, សាកលវិទ្យាល័យ រ៉ាចាម៉ង់ខ្លា, សាលា Ubon, មហាវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងបាងកក | អង្គការប៉ាស៊ីហ្វិលនុយមេរិកកម្ពុជា, សាកលវិទ្យាល័យ រ៉ាចាម៉ង់ខ្លា, សាកលវិទ្យាល័យ បុរីរាំ និងមហាវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈអ៊ុប៊ុន | គ្មាន |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ តុលា ២០១៦ | ០១ សីហា ២០០០ | ០១ កញ្ញា ២០១៧ | ៣០ វិច្ឆិកា ២០១៧ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣០ កញ្ញា ២០២០ | ៣១ ធ្នូ ២០១៨ | ៣០ កញ្ញា ២០១៩ | ៣០ កញ្ញា ២០១៩ |




















*អន្តរាគមន៍កម្មវិធីអប់រំបញ្ចូលគ្នាជួយយុវជនងាយរងគ្រោះដើម្បីទទួលបានឱកាសសម្រាប់ការសិក្សាបន្ទាប់ពីមធ្យមសិក្សា។ ឱកាសអប់រំទាំងនេះផ្តល់ឱ្យពួកគាត់នូវជំនាញតម្រូវការរីកចម្រើនក្នុងសតវត្សរ៍ទី២១។ កម្មវិធីអប់រំបញ្ចូលគ្នាផ្តល់ការគាំទ្រទាំងយុវជន និងយុវតី ប៉ុន្តែផ្តល់អាទិភាពខ្ពស់ដល់ស្ត្រីវ័យក្មេងដែលងាយរងគ្រោះ។ រូបភាពខាងលើផ្តល់នូវគំរូភាពសកម្មភាពមួយចំនួនដែលកម្មវិធីអប់រំបញ្ចូលគ្នាបានគាំទ្រ។*

***ពីឆ្វេងទៅស្តាំ៖*** *និស្សិតអាហារូបករណ៍គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា បានចូលរួមក្នុងព្រឹត្តិការណ៍ **One Asia Foundation**, ទស្សនកិច្ចសិក្សារ CTSP, ពិធីប្រគល់ពានរង្វាន់ស្តីពីការប្រកួតសរសេរអត្ថបទ។ សិស្សគម្រោង ACCESS ចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ។ សិស្សគម្រោងអប់រំកុមារីទទួលសម្ភារអាហារូបករណ៍ និងក្មេងប្រុសពីនាក់ផ្តល់ចំណាប់អារម្មណ៍ពីការសិក្សា។ សិស្សគម្រោង ACCESS អ៊ីស្លាមរៀនភាសាអង់គ្លេស ភ្ញៀវទស្សនកិច្ចអ៊ីស្លាម និងក្មេងស្រីទទួលបានការប្រឹក្សាអាជីពដើម្បីជ្រើសរើសជំនាញ។*

# គម្រោង អាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា (CTSP)

*“ការអប់រំក្មេងស្រីម្នាក់គឺការអប់រំគ្រួសារទាំងមូល”*

## បច្ចុប្បន្នភាពគម្រោង

គម្រោង CTSP បានប្រតិបត្តិការអស់រយៈពេល ៨ឆ្នាំមកហើយ ដែលមានពីរជំនាន់ជាស្ត្រីវ័យក្មេងបានបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ ក្នុងអំឡុងពេលជំនាន់ទី៣កំពុងសិក្សាជិតចប់។ គម្រោង CTSP មានគោលដៅពង្រឹងសិទ្ធិអំណាចក្មេងស្រីងាយរងគ្រោះ ដែលទទួលការអប់រំក្នុងប្រព័ន្ធជិតចប់ ហើយមានសក្ដានុពលពេញលេញចូលរៀននៅកម្រិតឧត្តមសិក្សាបាន។ គម្រោងនេះក៏មានបំណងបង្កើនការចូលរួមសកម្មភាពអភិវឌ្ឍន៍អាជីពដែលនឹងធានាថា ពួកគេចូលទៅបម្រើការងារប្រកបដោយសេចក្ដីជឿទុកចិត្ត។

បច្ចុប្បន្ននេះ និស្សិតស្រី ៣០នាក់ កំពុងសិក្សានៅសាខាសាកលវិទ្យាល័យ វេស្ទើន ឆ្នាំទី៣។ ពួកគាត់រៀនជំនាញផ្សេងៗគ្នា ដូចជា៖ គណនេយ្យ ធនាគារនិងហិរញ្ញវត្ថុ គ្រប់គ្រង រដ្ឋបាលសាធារណៈ និងអក្សរសាស្ត្រអង់គ្លេស។ សាខាសាកលវិទ្យាល័យ វេស្ទើន មានទីតាំងនៅទីរួមខេត្តកំពង់ចាម ក៏ជាទីតាំងការិយាល័យកណ្ដាលរបស់អង្គការ ខេប ផងដែរ។ គម្រោងក៏បានចូលរួមក្នុងការពង្រឹងសកម្មភាពអភិវឌ្ឍន៍អាជីពដើម្បីឱ្យនិស្សិតកសាងខ្លួនជាមនុស្សពេញវ័យ មានភាពជាអ្នកដឹកនាំ ចំណេះដឹងភាសាអង់គ្លេស សមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានវិទ្យា ដែលទាំងអស់នេះជាជំនាញស្នូលសម្រាប់សតវត្សរ៍ទី២១។

អង្គការ ខេប បានជួលផ្ទះធំមួយសម្រាប់និស្សិត ៣០នាក់ រស់នៅជាមួយគ្នាជាសហគមន៍រួម ដែលអាចលើកតម្កើងវប្បធម៌ចែករំលែក ការឱ្យតម្លៃ ការគោរព និងការទទួលខុសត្រូវ។

## សកម្មភាពសំខាន់ៗ

- ថ្នាក់ភាសាអង់គ្លេស
- ថ្នាក់បណ្ដុះបណ្ដាលកុំព្យូទ័រ
- ថ្នាក់ហាត់វែគណនេយ្យ
- ការប្រជុំប្រចាំខែ
- ការផលិតព្រឹត្តិប័ត្រ
- ក្លឹបសិក្សា
- បណ្ដាញអតីតនិស្សិតអាហារូបករណ៍
- ការជួបជុំអាណាព្យាបាលនិស្សិតប្រចាំឆ្នាំ
- កម្មវិធីដំណើរទស្សនកិច្ចសិក្សា
- វគ្គបណ្ដុះបណ្ដាលជំនាញទន់
- កម្មវិធីចុះសិក្សានៅតាមសហគមន៍

## លទ្ធផលកម្មវិធី

អំឡុងឆ្នាំសិក្សា ២០១៧-២០១៨ និស្សិតអាហារូបករណ៍កម្រិតឧត្តមសិក្សាបានសម្រេចគោលដៅចម្បងៗជាច្រើនដូចខាងក្រោម៖

- ពិន្ទុនិស្សិតចំនួន ៦៥% ជាប់ចំណាត់ថ្នាក់លំដាប់ ១-១០ ហើយគ្មាននិស្សិតណាម្នាក់ប្រឡងធ្លាក់មុខវិជ្ជាណាមួយឡើយ។
- និស្សិតចំនួន ១០០% ដែលទទួលបានអាហារូបករណ៍អាចប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា រួមមាន៖ កម្មវិធី **Ms Word, Excel, PowerPoint, Advance Excel** និងភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង។
- និស្សិត ២២នាក់បានទទួលជ័យលាភីពីការប្រកួតផ្សេងៗ រួមមាន៖ **Book Review Competition** និង **Asian Community**។
- ឪពុកម្ដាយ និងអាណាព្យាបាលចំនួន ៥០នាក់បានចូលរួមប្រជុំប្រចាំឆ្នាំ
- និស្សិតចំនួន ១៥នាក់ បានទៅទស្សនកិច្ចសិក្សានៅទីក្រុងភ្នំពេញ ដើម្បីរៀនសូត្រពីកន្លែងធ្វើការ និងក្រុមហ៊ុនឯកជនផ្សេងៗ។
- និស្សិតអាហារូបករណ៍ចំនួន ៨៥% មានភាពជឿជាក់ក្នុងការធ្វើបទបង្ហាញ ក៏ដូចជាការនិយាយជាសាធារណៈ។



សេង ថានីជានិស្សិតឆ្នាំទី៣ ជំនាញផ្នែករដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យវេស្ទើន។ នាងជាកូនស្រីច្បងនៅក្នុងគ្រួសារមួយដែលមានបងប្អូន៤នាក់។ ឪពុកម្ដាយរបស់នាងគឺជាកសិករ ដែលដាំបន្លែផ្លែឈើដើម្បីចិញ្ចឹមជីវិត។ ពួកគាត់មិនមានផ្ទះ ឬដីផ្ទាល់ខ្លួនសម្រាប់រស់នៅទេ ប៉ុន្តែរស់នៅជាមួយសាច់ញាតិ។

ចេញពីគ្រួសារមួយមានការលំបាកខាងសេដ្ឋកិច្ចធ្វើឱ្យនាងពិតជាចង់ទទួលបានជោគជ័យនៅសាកលវិទ្យាល័យ។ នាងជានិស្សិតដែលមានចរិតលក្ខណៈរឹងមាំ និងមានអាកប្បកិរិយាល្អនៅក្នុងថ្នាក់រៀន។

*"ខ្ញុំចង់ក្លាយជាអ្នកគ្រប់គ្រងធនធានមនុស្ស និងរដ្ឋបាលនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ឬក្រុមហ៊ុន។ ខ្ញុំនឹងខំធ្វើការដើម្បីទទួលបាន GPA ល្អពី១ឆ្នាំទៅ១ឆ្នាំដើម្បីជួយដល់ការងារសក្ដានុពលនាពេលអនាគត។ នាងខ្ញុំព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីឱ្យក្ដីសុបិន្តខ្ញុំក្លាយជាការពិត"*។



ជ្រន កាត់ថា មានអាយុ២១ឆ្នាំជានិស្សិតឆ្នើមផ្នែកអក្សរសាស្ត្រអង់គ្លេស។ នាងទទួលបានប័ណ្ណសរសើរជាច្រើនពីការសិក្សាក្នុងការប្រកួតជាច្រើន រួមមាន៖ ការប្រកួតជជែកដេញដោលជាភាសាអង់គ្លេស ការប្រកួតសរសេរអត្ថបទស្ដីពីអាស៊ាន និងការងារជាប្រធានក្លឹបអង់គ្លេសនៅ **American Corner** ដែលជាកម្មវិធីពិសេសមួយគាំទ្រដោយមូលនិធិអាស៊ី។

នៅពេលអនាគត កាត់ថាចង់ធ្វើការនៅវិទ្យាស្ថានភាសាអង់គ្លេស ឬកន្លែងអប់រំក្នុងសហគមន៍នាង។ នាងចង់លើកទឹកចិត្តដល់សិស្សនៅក្នុងភូមិនាងឱ្យចូលរៀនភាសាអង់គ្លេស ព្រោះមានតម្រូវការខ្លាំងលើជំនាញនេះក្នុងប្រទេសកម្ពុជា។



កញ្ញា សៀក សុវណ្ណ អាយុ១៨ឆ្នាំគឺជានិស្សិតរៀនជំនាញគណនេយ្យនៅឆ្នាំទី៣ នៅសាកលវិទ្យាល័យ វេស្ទើន។ នាងគឺជានិស្សិតម្នាក់ក្នុងចំណោមនិស្សិតអាហារូបករណ៍ CTSP វ័យក្មេងដែលទទួលបានមូលនិធិពីអង្គការ ខេប។ នាងជាយុវតីវ័យឆ្លាតម្នាក់ មានទំនុកចិត្ត និងរួសរាយរាក់ទាក់ទាំងនៅសាកលវិទ្យាល័យ និងអន្តេវាសិកដ្ឋាន។ ដោយសារនាងខិតខំសិក្សា សុវណ្ណបានដើរតួនាទីកាន់តែសំខាន់ក្នុងចំណោមមិត្តរួមថ្នាក់។ នាងបានបង្ហាញជំនាញភាពជាអ្នកដឹកនាំជាច្រើន និងអាចកាន់គម្រោងស្រាវជ្រាវបាន។ បច្ចុប្បន្ន សុវណ្ណគឺជាប្រធានក្លឹបស្ថិតិ ហើយបានជួយនិស្សិតអាហារូបករណ៍របស់អង្គការ ខេប ជាច្រើននាក់ទៀតដើម្បីសិក្សាមុខវិជ្ជាដ៏លំបាកនេះ។

សុវណ្ណបានជាប់លេខ១ក្នុងថ្នាក់ អំឡុងពេលឆ្នាំទី១នៅសាកលវិទ្យាល័យ (ក្នុងចំណោមនិស្សិតចំនួន ៤៧នាក់)។ នាងក៏ទទួលបានពានរង្វាន់សំណេរមួយពីការប្រកួតតែងនិពន្ធជាភាសាអង់គ្លេសស្ដីពីអាស៊ាន និងថាតើប្រទេសកម្ពុជាអាចលើកកម្ពស់ឋានៈខ្លួនយ៉ាងដូចម្ដេចក្នុងចំណោមបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀត។ ដោយសារជារង្វាន់សាច់ប្រាក់ ការប្រកួតនេះមានការប្រកួតប្រជែងខ្លាំង។

# គម្រោង អប់រំកុមារី (GEI)

“ ការអប់រំជួយឱ្យឆ្លងផុតពីគ្រោះអវិជ្ជា ”

## បច្ចុប្បន្នភាពគម្រោង

GEI គឺជាគម្រោងដែលបានដំណើរការយូរជាងគេបំផុតរបស់អង្គការ ខេប។ គម្រោងនេះបានបង្កើតឡើងដំបូងតាំងពីឆ្នាំ២០០០មក ហើយទទួលបានជំនួយហិរញ្ញប្បទានផ្សេងៗ។ ជំនួយចុងក្រោយនេះទទួលបានពីអង្គការមូលនិធិអូកទ្រី អូស្ត្រាលី និងប្រតិបត្តិការដោយអង្គការ ខេប នៅក្នុងខេត្តពីរគឺ កំពង់ចាម និងត្បូងឃ្មុំ។ ការកសាងកម្មវិធីដំបូងរយៈពេល១៨ឆ្នាំ GEI មានបំណងផ្តល់ជំនាញ ព័ត៌មាន និងជំនួយដល់យុវជនតាមរយៈការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច និងសង្គម។ គម្រោងបានកំពុងវិវឌ្ឍក្នុងមាគ៌ាមួយដែលបន្តបនឹងតម្រូវការផ្លាស់ប្តូររបស់យុវជន និងសង្គមកម្ពុជា ជាពិសេស ពេលចូលសតវត្សរ៍ទី២១នេះ។

## ផលជះរបស់គម្រោង

- ត្រីវិស័យដែលជាកម្មវិធីប្រឹក្សាយោបល់នៅលើទូរស័ព្ទដៃស្មាតហ្វូន បានបង្កើតឡើងរួចរាល់ដោយបុគ្គលិកគម្រោងអប់រំកុមារី និងសហការជាមួយអង្គការ **InSTEDD** ដែលជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញឯកទេសផ្នែកបច្ចេកវិទ្យា។
- អង្គការ ខេប បានចុះអនុស្សារណៈយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្ទេរកម្មវិធីត្រីវិស័យដាក់ឱ្យប្រើប្រាស់ទូទៅតាមសាលាចំណេះទូទៅកម្រិតវិទ្យាល័យដែលមានឧបករណ៍បច្ចេកវិទ្យា។
- សិស្សអាហារូបករណ៍ចំនួន ២៥០នាក់ បានប្រើប្រាស់កម្មវិធីត្រីវិស័យក្នុងការធ្វើផែនការអាជីពរបស់ពួកគាត់ និង ៩៥% បានបង្ហាញថាពួកគាត់មានគោលដៅកាន់តែច្បាស់។
- គម្រោង GEI បានបង្ហាញថា សិស្សអាហារូបករណ៍កម្រិតឧត្តមសិក្សាចំនួន ៨នាក់ ដែលសិក្សានៅប្រទេសថៃ បានបញ្ចប់ការសិក្សា និងត្រឡប់មកកាន់ប្រទេសកម្ពុជា និងមានការងារធ្វើទាំងអស់គ្នា ទទួលបានប្រាក់បៀវត្សចាប់ពី ២៥០ ដល់ ៤៥០ដុល្លាអាមេរិក។
- អង្គការ ខេប បន្តពង្រីកសហប្រតិបត្តិការជាមួយអង្គការប៉ាសីរ៉ែលនុយមេរិកកម្ពុជា ស្ថិតក្នុងទីក្រុងភ្នំពេញ ដើម្បីផ្តល់ការស្នាក់នៅ និងថ្លៃបង់ការសិក្សាដល់សិស្សក្នុងគម្រោងដោយឥតបង់ថ្លៃ។
- ៧៥%នៃសិស្សអាហារូបករណ៍សរុប ២៥០នាក់ បានបញ្ចប់ការសិក្សាកម្រិតអនុ/វិទ្យាល័យក្នុងឆ្នាំនេះ។

## សកម្មភាពសំខាន់ៗ

- ផ្តល់កញ្ចប់អាហារូបករណ៍ដល់សិស្សចំនួន ៣១១នាក់ នៅថ្នាក់អនុវិទ្យាល័យ វិទ្យាល័យ និងកម្រិតឧត្តមសិក្សា។
- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីប្រឹក្សាអាជីពដល់អ្នកប្រឹក្សាអាជីព ១០នាក់នៅតាមសាលារៀនគោលដៅ។
- សិស្សចំនួន ១.១២៨នាក់ បានទទួលការប្រឹក្សាពីអាជីពពីអ្នកប្រឹក្សាគ្រូបង្រៀនចំនួន ១០កន្លែង។
- ផ្តល់ការបណ្តុះបណ្តាលស្តីពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាកុមារចំនួន ៣០នាក់។
- សិស្សវិទ្យាល័យចំនួន ៩០នាក់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញភាពជាអ្នកដឹកនាំ និងការជជែកវែកញែក។
- ជ្រើសរើសអ្នកប្រឹក្សាចំនួន ១៥០នាក់ នៅតាមវិទ្យាល័យគោលដៅចំនួន ១០ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រឹក្សាអាជីព។
- ផ្តល់ការគាំទ្របំណិនមូលដ្ឋានដល់គ្រួសារងាយរងគ្រោះចំនួន ៥០។
- គាំទ្រក្រុមប្រឹក្សាឃុំ និងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារលើកការតស៊ូមតិសម្រាប់យុវជន និងការប្រឹក្សាអាជីពទូទៅនៅសាលាទាំង១០ ដែលគាំទ្រដោយគម្រោងអប់រំកុមារី។
- អភិវឌ្ឍខ្លឹមសារ និងកម្មវិធីប្រឹក្សាអាជីព (App) ដែលមានឈ្មោះថា ត្រីវិស័យ។
- រៀបចំបើកសម្ពោធកម្មវិធីត្រីវិស័យ ដែលមានអ្នកចូលរួមជាង ៦០០នាក់មកពីវិទ្យាល័យគោលដៅចំនួន៣ក្នុងខេត្តត្បូងឃ្មុំ។



កញ្ញា លឿន សុខម៉េង អាយុ ២៣ឆ្នាំជាគ្រូបង្រៀននៅសាលាបឋមសិក្សា មេព្រីង ដែលមានចម្ងាយប្រមាណជា ៣០គីឡូម៉ែត្រពីផ្ទះនាង។ សុខម៉េងបានទទួលអាហារូបករណ៍ពីគម្រោង GEI ទៅសិក្សានៅសាលាគរុកោសល្យខេត្តរយៈពេល ២ឆ្នាំ ដើម្បីទទួលបានវិញ្ញាបនបត្រគ្រូបង្រៀន។ សុខម៉េងមកពីគ្រួសារដែលលំបាក។ ឪពុកនាងបានបោះបង់ចោលក្រុមគ្រួសារពេលនាងនៅក្មេង ហើយនាងរស់នៅជាមួយម្តាយ និងជីដូន។ នៅគ្រាមួយ នាងបានបោះបង់ការសិក្សាដើម្បីទៅរកលុយឱ្យគ្រួសារមុនពេលចុះឈ្មោះចូលរៀនឡើងវិញ។ ជាលទ្ធផលដោយការគាំទ្រពីអង្គការមូលនិធិអូកទ្រី ឥឡូវនេះ សុខម៉េងមានការងារគួរឱ្យគោរពដែលបំពេញក្តីសុបិន្តរបស់នាង។ ទីបំផុតនាងចង់បន្តការសិក្សារបស់នាងដើម្បីឱ្យនាងអាចក្លាយជាគ្រូបង្រៀនគីមីវិទ្យានៅវិទ្យាល័យមួយ។ ប៉ុន្តែពេលនេះ នាងមានក្តីរំភើបរីករាយដែលមានឱកាសធ្វើជាគ្រូបង្រៀន អាចផ្តល់ប្រាក់ចំណូលបន្ថែមដល់ជីដូនកុំឱ្យធ្វើការទៀត។ សុខម៉េងបញ្ចប់ថា "ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអូកទ្រីដែលបានគាំទ្រដល់យុវជនក្រីក្រ។ ដូច្នេះ ជីវិតពួកយើងបានល្អប្រសើរតាមរយៈការអប់រំ។



កញ្ញា ចាន់រី បានរៀនថ្នាក់ទី១២ នៅវិទ្យាល័យ មហាលាភ ក្នុងខេត្តកំពង់ចាម។ ឪពុកម្តាយនាងរកប្រាក់បានត្រឹមតែ១ដុល្លារអាមេរិកក្នុងមួយថ្ងៃ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ និងការអប់រំរបស់កូនៗ។ ចាន់រីជាកូនស្រីច្បងក្នុងចំណោម៣នាក់។ ចាន់រីនិយាយថា "*ខ្ញុំសប្បាយរីករាយនៅពេលមិត្តរួមថ្នាក់ នាយកសាលា និងបុគ្គលិកអង្គការ ខេប មកលេងផ្ទះខ្ញុំ។ ខ្ញុំត្រូវបានលើកទឹកចិត្តឱ្យត្រឡប់ទៅសាលារៀនវិញដើម្បីរៀនបញ្ចប់ថ្នាក់ទី១២*"។ ចាន់រីបានទទួលអាហារូបករណ៍ពីអង្គការ ខេប អស់រយៈពេល ៦ឆ្នាំ តាមរយៈអង្គការមូលនិធិអូកទ្រី ដើម្បីបញ្ចប់ការសិក្សា។ នាងនឹងចូលរៀននៅសាកលវិទ្យាល័យនៅឆ្នាំក្រោយ ប្រសិនបើនាងប្រឡងបាក់ឌុបជាប់។ ចាន់រីបន្តថា "*ចំពោះកម្មវិធីអាហារូបករណ៍នេះ ខ្ញុំបានដឹងពីការកំណត់គោលដៅ ការទំនាក់ទំនង ការដោះស្រាយបញ្ហា និងការចូលរួមក្នុងសកម្មភាពក្រុមនិស្សិត។ ខ្ញុំចូលរួមកិច្ចប្រជុំប្រចាំខែជាមួយ LSMCs និងសិស្សអាហារូបករណ៍ដទៃទៀតដើម្បីចែករំលែកនូវកង្វល់ដែលខ្ញុំមាន។ ខ្ញុំត្រូវបានលើកទឹកចិត្តពីនាយកសាលាឱ្យខំរៀនដើម្បីរំដោះខ្លួនពីភាពក្រីក្រ។ ក្រៅពីការសិក្សា ខ្ញុំជួយត្បាញក្រម៉ាម្តាយខ្ញុំដើម្បីលក់នៅផ្សារ។ នៅពេលអនាគត ខ្ញុំចង់ក្លាយជាមេធាវីព្រោះខ្ញុំនឹងប្រើចំណេះដឹង និងជំនាញខ្ញុំទៅជួយ និងការពារប្រជាជនក្នុងសហគមន៍ដើម្បីតស៊ូប្រយុទ្ធរកយុត្តិធម៌។ ខ្ញុំនឹងដាក់ពាក្យស្នើសុំអាហារូបករណ៍រៀនច្បាប់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាល។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងក្លាយជាសិស្សដែលត្រូវបានជ្រើសរើស*"។

## សមិទ្ធិផលយូរអង្វែង

សមិទ្ធិផលមួយដ៏យូរអង្វែងរបស់គម្រោងអប់រំកុមារី គឺជាលទ្ធភាពធ្វើការជាមួយអង្គការ InSTEDD ដែលជាស្ថាប័នជំនាញខាងបច្ចេកវិទ្យា ដើម្បីបង្កើតកម្មវិធីដាក់ក្នុងទូរស័ព្ទដៃដែលចង្អុលបង្ហាញក្នុងការជួយសិស្សនៅកម្ពុជាទទួលបានសេវាព័ត៌មានស្តីពីផែនការអាជីព។ បច្ចុប្បន្ន សាលារៀនរដ្ឋជាច្រើនមិនមានទីប្រឹក្សាអាជីព ដើម្បីជួយសិស្សធ្វើផែនការអាជីពនាពេលអនាគត។ ដូច្នេះ មានគម្លាតយ៉ាងធំសម្រាប់សេវាផែនការអាជីពនៅតាមសាលារៀន។ កម្មវិធីថ្មីនេះហៅថា **ត្រីវិស័យ** ផ្តល់នូវសំណួរគន្លឹះៗដល់សិស្សដើម្បីឆ្លើយ និងឈានដល់នាំពួកគាត់កំណត់បានជាប់សមស្របមួយ និងធនធានអប់រំ ដែលជាតម្រូវការក្នុងការស្វែងរកស្ថាប័នទាំងនោះដែលពួកគេអាចសិក្សាស្វែងយល់មុខរបរជាច្រើន។ សម្រាប់កម្មវិធីត្រីវិស័យ អង្គការ ខេប ជាអ្នកបង្កើតខ្លឹមសារ ចំណែកអង្គការ InSTEDD ជាអ្នកបង្កើត Software។ កម្មវិធីនេះត្រូវបានទទួលស្គាល់ពីរដ្ឋាភិបាលជាផ្លូវការ និងយល់ព្រមឱ្យប្រើប្រាស់នៅតាមសាលារៀនរដ្ឋដែលមានថេបប្លេតអាចប្រើប្រាស់បាន។



***ពិធីទទួលស្វាគមន៍ផ្លូវការ:*** *ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (រូបកណ្តាលឆ្វេង) ឈរជាមួយក្រុមមន្ត្រីគម្រោង GEI ក្នុងពិធីទទួលស្វាគមន៍ជាផ្លូវការនៅរាជធានីភ្នំពេញ។*

# គម្រោង STEM4WOMEN ( ស្ទែម/STEM )

*“ ការអប់រំជួយចម្លងជីវិតស្ត្រីកម្ពុជា ”*

## បច្ចុប្បន្នភាពគម្រោង

គម្រោង STEM4WOMEN ខិតខំផ្តល់សិទ្ធិអំណាចដល់យុវតីងាយរងគ្រោះ ដើម្បីចូលរួមក្នុងចលនាជាសកលដែលលើកកម្ពស់ការចូលរួមរបស់ស្ត្រីកាន់តែច្រើនឡើងក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា **(STEM)**។ ក្នុងអំឡុងឆ្នាំនេះ អង្គការ CoH អាចទទួលបានជោគជ័យក្នុងការតស៊ូមតិសម្រាប់គម្រោងនៅប្រទេសអូស្ត្រាលី ដែលជាជំនួយឥតសំណងតូចមួយពី Navitas។ គម្រោង STEM4Women បានជួយឱ្យស្ត្រីវ័យក្មេង ១១នាក់ទៅសិក្សាថ្នាក់ឧត្តមសិក្សារយៈពេល ២ឆ្នាំនៅប្រទេសថៃ ដើម្បីទទួលបានសញ្ញាបត្រ STEM។ និស្សិតទាំងអស់ត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ខ្លួននៅឆ្នាំ២០១៩។ បេក្ខជនបានចុះឈ្មោះចូលរៀននៅតាមបណ្តាគ្រឹះស្ថាននានាក្នុងប្រទេសថៃ និងប្រទេសកម្ពុជា រួមមាន៖ សាកលវិទ្យាល័យ Rajamangla University of Technology Isan, Surin (RMUTI), Ubon Rachthani Vocational College, Buriram College of Agriculture & Technlogogy (BCAT), និងអង្គការប៉ាស៊ីហ្វិលនុយមេរិកកម្ពុជា (PNC)។ ខេបមានលទ្ធភាពចរចាលក្ខខណ្ឌចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានទាំងនេះដោយមិនមានការបង់ថ្លៃសិក្សា និងមានកន្លែងសម្រាប់ស្នាក់នៅក្នុងករណីជាច្រើន។ ភាគច្រើននិស្សិតទាំងអស់នេះមកពីគ្រួសារដែលងាយរងគ្រោះ ហើយមានឱកាសតិចតួចក្នុងការបន្តការសិក្សារបស់ពួកគេ។

## គោលបំណង

គម្រោង **STEM4WOMEN** មានបំណងផ្តល់សិទ្ធិអំណាចដល់យុវតីនៅកម្ពុជាដែលងាយរងគ្រោះទទួលបានការសិក្សាមុខជំនាញស្ទែម ដែលបច្ចុប្បន្ននេះជំនាញនេះ បុរសជាអ្នកសិក្សា។

## រូបភាពសកម្មភាព

គម្រោង STEM4WOMEN បានប្រើប្រាស់បណ្តាញទូលំទូលាយដែលអភិវឌ្ឍន៍ឡើងដោយអង្គការ ខេប ប្រើប្រាស់ធនធានមានកំណត់នៅក្នុងការគាំទ្របង្កើនឱកាសអប់រំ និងសេដ្ឋកិច្ចសម្រាប់ស្ត្រី រួមមាន៖ ការប្រឹក្សាយោបល់អាជីព និងទំនុកចិត្តទទួលបានការងារ។ បណ្តាញទាំងនេះរួមបញ្ចូលទាំងរដ្ឋាភិបាលប្រទេសថៃផ្តល់ការសិក្សា និងស្នាក់នៅដោយឥតគិតថ្លៃ និងក៏ដូចជាការបញ្ចុះតម្លៃសិក្សាពីគ្រឹះស្ថានសិក្សានៅប្រទេសកម្ពុជា។

## តារាងស្តីពីមុខជំនាញរវាងយុវតីនិងយុវតី ដែលទទួលបានអាហារូបករណ៍ពីគម្រោង

| មុខជំនាញ | បច្ចេកវិទ្យា IT | កុំព្យូទ័រពាណិជ្ជកម្ម | កុំព្យូទ័រវិស្វកម្ម | គីមីអាហារ និងដំណើរការអាហារ | វិទ្យាសាស្ត្រគ្រូកម្ម | សរុប |
|---|---|---|---|---|---|---|
| ចំនួនសិស្ស | ៥នាក់ | ២នាក់ | ១នាក់ | ២នាក់ | ១នាក់ | ១១នាក់ |
| ស្ថាប័នអប់រំ | PNC | សាកលវិទ្យាល័យ RMUTI | សាកលវិ. Ubon Rachthani | សាកលវិ. Ubon និងសាលា BCAT | សាលា BCAT | |
| ទីកន្លែង | ភ្នំពេញ កម្ពុជា | សុរិន្ទ ថៃ | អ៊ុប៊ុន ថៃ | ថៃ | BCAT ថៃ | |

កញ្ញាម៉ន សុធិមានអាយុ១៨ឆ្នាំ រស់នៅជាមួយម្តាយដែលអត់ការងារធ្វើ ដោយសារគាត់វះកាត់។ ឪពុករបស់សុធិបានស្លាប់នៅក្នុងឧប្បត្តិហេតុកសិកម្មនៅពេលដែលនាងមានអាយុ១២ឆ្នាំ។ ម្តាយរបស់នាងបានខ្ចីប្រាក់ ៧០០ដុល្លាអាមេរិកនៅក្នុងភូមិដើម្បីបង់ថ្លៃធ្វើបុណ្យសពឪពុកនាង។ ជាលទ្ធផល ហិរញ្ញវត្ថុគ្រួសារនាងស្ថិតក្នុងស្ថានភាពមិនទៀងទាត់។ ជានិច្ចកាល សុធិជាសិស្សឆ្លាតតាំងពីរៀននៅបឋមសិក្សាមកម្លេះ។នាងទទួលបានវិញ្ញាបនបត្រឆ្នើមប្រចាំឆ្នាំនៅវិទ្យាល័យ។ នាងតែងតែរៀនថ្នាក់បន្ថែមលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យាដោយមិនគិតថ្លៃ។ សុធិបាននិយាយថា "*នាងខ្ញុំបានគិតថានឹងបោះបង់ការសិក្សា ប្រសិនបើខ្ញុំត្រូវបង់ថ្លៃសិក្សាទាំងអស់។ សំណាងល្អ ខ្ញុំត្រូវបានគេជូនដំណឹងអំពីយុទ្ធនាការអង្គការ ខេប ដើម្បីជ្រើសរើសសិស្សអាហារូបករណ៍ពេញលេញទៅសិក្សានៅប្រទេសថៃ។ នាងខ្ញុំជឿថាអាចធ្វើបានល្អលើការប្រឡងពីព្រោះខ្ញុំពូកែគណិតវិទ្យា ហើយអាចនិយាយភាសាអង់គ្លេសបានតិចតួច។ ទីបំផុត ខ្ញុំបានធ្វើតេស្ត និងសំភាសន៍អាហារូបករណ៍ជាប់។ ខ្ញុំពិតជាសប្បាយរីករាយ និងសូមអរគុណដល់អង្គការ ខេប ដែលផ្តល់ក្តីសង្ឃឹមថ្មីដល់ខ្ញុំ ខ្ញុំអាចធ្វើអ្វីមួយក្នុងជីវិតបាន។ ខ្ញុំបានចំណាយពេលប្រាំខែដើម្បីសិក្សាភាសាថៃ និងភាសាអង់គ្លេសក៏ដូចជាជំនាញ ICT ដែលចាំបាច់ដើម្បីត្រៀមខ្លួនទៅសិក្សានៅគ្រឹះស្ថានឧត្តមនៅក្នុងប្រទេសថៃ*"។ អង្គការ ខេប បានរៀបចំវគ្គបណ្តុះបណ្តាលពិសេសទាំងនេះនៅក្នុងក្រុងកំពង់ចាមនៅការិយាល័យកណ្តាលរបស់ខ្លួន។ សុធិនឹងសិក្សាផ្នែកបច្ចេកវិទ្យាគណនេយ្យ ដូច្នេះ នាងអាចធ្វើការជាអ្នកគ្រប់គ្រងក្នុងវិស័យរដ្ឋាភិបាលនៅពេលនាងបញ្ចប់ការសិក្សាពីប្រទេសថៃ។



### តម្រូវការ STEM សម្រាប់ស្ត្រី

ក្នុងចំណោមយុវជនកម្ពុជាដែលមានអាយុពី ១៥ ទៅ ២៩ឆ្នាំ មានចំនួន ៤.៣៨៩.០០០នាក់ ដែលបច្ចុប្បន្ន មានប្រហែល ៥% បានចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ដែលក្នុងចំនួនឯកសិទ្ធិតិចតួចនេះ មានតែយុវតី ៣៩% ប៉ុណ្ណោះ។ ការសិក្សា STEM នៅគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកម្ពុជា ភាពខុសគ្នានេះស្ត្រីបានកើនឡើងដល់ ១៤% និងបុរស ៨៦%។ ភាពខុសគ្នានេះគឺជាផ្នែកមួយដ៏ធំបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បើប្រៀបធៀបទៅនឹងស្ត្រី ៥២% នៅប្រទេសថៃ និង ៤៨% នៅប្រទេសម៉ាឡេស៊ី។ គំនិតផ្តួចផ្តើមនេះនឹងលើកកម្ពស់កាលនុវត្តភាពសម្រាប់ស្ត្រីក្នុងវិស័យទាំងនេះធ្វើឱ្យគ្រឹះស្ថានឧត្តមសិក្សាកាន់តែមានលក្ខណៈទូលំទូលាយ និងនាំឱ្យមាន "ការផ្លាស់ប្តូរ" តាមរយៈការលើកកម្ពស់គំរូតួនាទីសំខាន់ៗសម្រាប់អ្នកជំនាញស្ត្រី STEM នៅក្នុងសង្គមកម្ពុជា។ ខណៈពេលដែលចំនួនយុវតីនៃចំនួនស្ត្រីដែលគម្រោង STEM4Women បានឧបត្ថម្ភគាំទ្រគឺមានតិចតួច ប្រហែលជា ១៥នាក់ ជារឿងសំខាន់ដែលចាំថា តើយុវតីប៉ុន្មាននាក់នឹងទទួលរងផលប៉ះពាល់ជាវិជ្ជមានលើគំរូតួនាទីជាអ្នកវិទ្យាសាស្ត្រ វិស្វករ និងអ្នកបច្ចេកវិទ្យា។ ឧ. អ្នកវិទ្យាសាស្ត្រស្រីម្នាក់អាចមានឥទ្ធិពលលើយុវតី ៥០ ឬ ១០០ នាក់ក្នុងជីវិតរស់នៅរបស់គាត់ គឺចំនួន ២០នាក់។ ម្យ៉ាងវិញទៀត អង្គការ ខេប បានបង្កើតបណ្តាញអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាពីមុនៗមក ដើម្បីផ្តល់ជាកន្លែងដែលនិស្សិតបានបញ្ចប់ការសិក្សាជោគជ័យអាចជួយគាំទ្រដល់កម្មវិធីអង្គការ ខេប នាពេលអនាគតបាន ដែលស្របគ្នានឹងគំនិតរួមចំណែកក្នុងចំណោមស្ត្រី។



# កម្មវិធីអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច (ACCESS)

*“ ផ្តល់ជំនាញភាសាអង់គ្លេស និងចំណេះដឹងពីវប្បធម៌សហរដ្ឋអាមេរិកតាមរយៈបរិស្ថានសិក្សារីករាយ ”*

## បច្ចុប្បន្នភាពគម្រោង

គម្រោង Access គឺគម្រោងថ្មីមួយដែលអង្គការ ខេប បានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០១៨។ គម្រោងនេះគឺជាកម្មវិធីអាហារូបករណ៍ជាសាកល ដែលគាំទ្រដោយក្រសួងការបរទេសសហរដ្ឋអាមេរិកដែលផ្តល់នូវជំនាញភាសាអង់គ្លេសថ្នាក់មូលដ្ឋានលើសិស្សពូកែ ជួបការលំបាកខាងសេដ្ឋកិច្ចដែលមានអាយុចាប់ពី ១៣ឆ្នាំដល់ ២០ឆ្នាំ។ គម្រោងនេះផ្តល់ជូននូវការសិក្សាក្រៅម៉ោងរដ្ឋ និងថ្នាក់ភាសាអង់គ្លេស។ សិស្សដែលបានចូលរួមក្នុងកម្មវិធី Access ទទួលបាននូវការសិក្សាអំពីវប្បធម៌ និងតម្លៃប្រជាធិបតេយ្យរបស់សហរដ្ឋអាមេរិកតាមរយៈសកម្មភាពលើកកម្ពស់ការអប់រំផ្សេងៗ។ ចាប់តាំងពីឆ្នាំ២០០៤មក មាននិស្សិតជាង ១១៥.០០០នាក់មកពីប្រទេសជាង៨៥ បានចូលរួមក្នុងកម្មវិធី ACCESS នេះ។

អង្គការ ខេប បានទទួលបានថវិកាដើម្បីដំណើរការកម្មវិធី ACCESS រយៈពេល ២ឆ្នាំ ចាប់ពីឆ្នាំ ២០១៧-២០១៩ ដែលមានសិស្សទទួលផលចំនួន ៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ប៉ើសពីរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ តំបន់នេះគឺជាគោលដៅសំខាន់កម្មវិធីព្រោះមានប្រជាជនជនជាតិឥស្លាមច្រើនដែលជាក្មេងស្រី និងមិនមានឱកាសសិក្សាច្បាស់លាស់។ សិស្សដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីនេះ បានរៀនជំនាញភាសាអង់គ្លេសដ៏រឹងមាំ ដែលជួយពួកគេទៅរកការងារល្អប្រសើរ ឱកាសសិក្សាកាន់តែច្រើន និងសមត្ថភាពក្នុងការចូលរួមនិងការប្រកួតប្រជែងកម្មវិធីផ្លាស់ប្តូរសម្រាប់សិស្សនិស្សិតនាពេលអនាគតដែលអាចឱ្យពួកគេសិក្សាក្រៅម៉ោង ឬពេញម៉ោងនៅសហរដ្ឋអាមេរិកបាន។

សិស្សទាំងអស់ចំនួន ៤០នាក់ បានសិក្សាអំពីប្រវត្តិសាស្រ្តរបស់ស្រ្តីនៅពេលស្រ្តីភាគច្រើនក្នុងពិភពលោកមិនមានសិទ្ធិបោះឆ្នោត ឬទទួលបានឱកាសសិក្សា។ ហេតុនេះបាននាំឱ្យមានវិសមភាពយេនឌ័រនៅទូទាំងប្រទេសជាច្រើន។ សិស្សត្រូវបានលើកទឹកចិត្តឱ្យរៀនសូត្រពីបទពិសោធន៍ប្រវត្តិសាស្រ្តទាំងនេះ និងអនុវត្តមេរៀនដែលបានរៀនពីប្រទេសកម្ពុជា។ សិស្សក៏សិក្សាអំពីប្រព័ន្ធអប់រំរបស់សហរដ្ឋអាមេរិកផងដែរ ដែលទាក់ទងទៅនឹងបរិស្ថានសាលារៀន និងភាពខុសគ្នារវាងការអប់រំរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា។

## គោលបំណង

លើកកម្ពស់ចំណេះដឹងសិស្សអំពីវប្បធម៌សហរដ្ឋអាមេរិក ជំនាញភាសាអង់គ្លេស និងជំនាញគិតពិចារណាស៊ីជម្រៅតាមរយៈបច្ចេកទេសបង្រៀនប្រកបដោយភាពច្នៃប្រតិដ្ឋ។

## សកម្មភាពសំខាន់ៗ

- ដំណើរការថ្នាក់រៀនចាប់ពីខែមករា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩
- បង្រៀនភាសាអង់គ្លេសចំនួន ៨ម៉ោងក្នុង១សប្តាហ៍
- បង្រៀន ICT ចំនួន ២ម៉ោងក្នុង១សប្តាហ៍
- បន្ថែមវគ្គបំប៉ននៅខេត្តកំពង់ចាម និងរាជធានីភ្នំពេញ
- គម្រោងសេវាកម្មសហគមន៍
- សកម្មភាពអភិវឌ្ឍន៍ខ្លួន សិស្សម្នាក់ទទួលការបង្រៀនជាង ៦០០ម៉ោង
- ផ្តល់សម្ភារអាហារូបករណ៍ ដូចជា៖ កង់ កាតាប និងសៀវភៅអង់គ្លេស
- កម្មវិធីបំណិនជីវិតការដាំបន្លែលើទឹក។







*↑ ការប្រើបច្ចេកទេសថ្មីក្នុងកសិកម្ម: ក្មេងស្រីអ៊ីស្លាមរៀនអំពីសួនជលវប្បកម្មនៅសាលារៀនពួកគេ។*



*← យឿន យី ជាសិស្សថ្នាក់ទី១០ នៅវិ.ប៉ើសពីរ បានធ្វើការពិសោធន៍បន្លែ។*

មានសិស្ស ACCESS ជាច្រើននាក់ចូលរួមសកម្មភាពជលវប្បកម្មដើម្បីស្វែងយល់ពីបច្ចេកទេសថ្មីអាចលើកកម្ពស់បំណិនមូលដ្ឋានបាន។ សិស្សថ្នាក់ទី១០ ម្នាក់ឈ្មោះ យឿន យី បាននិយាយថា *"ខ្ញុំពិតជាមានអារម្មណ៍រំភើបសប្បាយរីករាយខ្លាំងណាស់ ដោយបានឃើញបន្លែស្ពៃក្តោបដុះលូតលាស់ និងមានពណ៌ល្អ។ ជារៀយៗ ខ្ញុំមកពិនិត្យមើលបន្លែនៅក្នុងអំឡុងម៉ោងចេញលេង។ វាមិនមែនជាការងារដ៏គ្រោះថ្នាក់នោះទេ តែខ្ញុំចង់ច្បាស់ថា មានទឹករត់សព្វគ្រប់គ្រាន់ និងសារធាតុចិញ្ចឹមបន្លែដែលបានដាក់បញ្ចូលទឹកក្នុងរយៈពេលលូតលាស់១៥ថ្ងៃ។ ប្រហែល១សប្តាហ៍ ក្រុមរបស់ខ្ញុំនឹងប្រមូលផលស្ពៃហិរនេះយកទៅធ្វើម្ហូបអាហារបរិភោគសាមគ្គី។ យើងក៏បានលក់បន្លែមួយចំនួនដើម្បីយកទៅទិញគ្រាប់ពូជថ្មីមកដាំបន្តទៀត ”*។

## សកម្មភាពជលវប្បកម្មតាមបច្ចេកទេសថ្មី

ជលវប្បកម្មគឺជាវិធីសាស្រ្តទំនើបនៃការដាំបន្លែលើទឹកដោយមិនចាំបាច់ប្រើដី។ ប្រជាជនកម្ពុជាជាច្រើនបានចាប់អារម្មណ៍ប្រើប្រាស់ជលវប្បកម្មដើម្បីដាំបន្លែតាមវិធីសាស្រ្តមួយដែលមិនប្រើថ្នាំសម្លាប់សត្វល្អិត។ នៅក្នុងទីក្រុង ប្រជាជនដឹងអំពីការដាំបន្លែបែបជលវប្បកម្ម ហើយពួកគាត់អាចសាកល្បង ឬបរិភោគផលិតផលក្នុងស្រុកជំនួសផលិតផលដែលមិនដឹងប្រភពច្បាស់លាស់ ដែលអាចផ្តល់ផលអាក្រក់ដល់សុខភាពពួកគាត់។

អង្គការ ខេប បានធ្វើការបង្រៀនណែនាំសកម្មភាពជលវប្បកម្មដល់សិស្សគម្រោង ACCESS ដែលសិក្សានៅវិទ្យាល័យ ប៉ើសពីរ ផ្តល់នូវចំណេះដឹង និងជំនាញថ្មីអំពីការដាំបន្លែលើទឹកមិនប្រើដី។ ដូច្នេះពួកគាត់អាចយកជំនាញពិសេសទាំងនេះទៅប្រើប្រាស់នៅផ្ទះពួកគាត់ដើម្បីដាំបន្លែ ប្រសិនបើពួកគាត់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីបើកអាជីវកម្មខ្នាតតូចនៅថ្ងៃអនាគត។

# គម្រោង ងាយស្រួលរៀន (E2L)

*"ការរៀបចំគម្រោងដោយប្រើសកម្មភាពចម្រុះដើម្បីធានានូវផលជះរយៈពេលយូរក្នុងការអប់រំ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការឆាលហ្វានកម្ពុជា |
| អ្នកទទួលផលផ្ទាល់ | សិស្ស ៩.៥៣៨ នាក់ (ស្រី ៤.៧៤៩នាក់) |
| ថវិកាបានទទួល ឆ្នាំ២០១៨ | ២៣៦.៣០០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផល | ២៥ ដុល្លាអាមេរិក/១នាក់ |
| ខេត្តគ្របដណ្តប់ | ស្វាយរៀង |
| ស្រុកគ្របដណ្តប់ | ២ ស្រុក (ស្វាយជ្រំ និងរមាសហែក) |
| បឋមសិក្សាគោលដៅ | ២៨ សាលា |
| មធ្យមសិក្សាគោលដៅ | ២ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៩ |

## បច្ចុប្បន្នភាពគម្រោង

ដំបូងឡើង គម្រោងងាយស្រួលរៀនបានចាប់ផ្តើមជាកម្មវិធីសាកល្បងមួយនៅឆ្នាំ ២០១៥ ហើយបានទទួលបទពិសោធន៍ល្អៗ ដែលជាផ្នែកបន្ថែមជាច្រើនជាមួយនឹងការកែប្រែការរចនារបស់គម្រោងដើម្បីអនុវត្តគម្រោងមួយជាបន្តទៀត។ ការពង្រីកបន្ថែមថ្មីក៏ត្រូវបានព្រមព្រៀងគាំទ្រកម្មវិធីសម្រាប់ឆ្នាំសិក្សា ២០១៨-២០១៩ ផងដែរ។ ថ្មីៗនេះគម្រោងនេះបានពង្រីកទៅក្នុងវិស័យអនុវិទ្យាល័យ ដើម្បីឱ្យកុមារទាំងនោះដែលបានបញ្ចប់ថ្នាក់ទី៦ បន្តទទួលបាននូវសេវាអប់រំដែលមានគុណភាពខ្ពស់។ គម្រោងនេះបានបន្តទទួលការកោតសរសើរ និងគាំទ្រជាគម្រោងមួយក្នុងចំណោមគម្រោងដ៏ល្អបំផុតរបស់អង្គការ ខេប។ គម្រោង E2L គឺជាកូនកាត់កម្មវិធីដែលរួមបញ្ចូលគ្នានូវគំនិតសរសេរកម្មវិធីដ៏ល្អបំផុតមួយចំនួនដែលបង្កើតឡើងដោយអង្គការ ខេប អស់ជាច្រើនឆ្នាំមកបង្កើតជាគម្រោង។ ដោយសារម្ចាស់ជំនួយទ្វេភាគីជាច្រើនបានផ្លាស់ប្តូរពីការរៀបចំគម្រោងដែលមានរចនាសម្ព័ន្ធច្បាស់លាស់ដោយអង្គការ ខេប មានមោទនភាពណាស់ដែលមានគម្រោង E2L ជាគំរូដ៏ល្អបំផុតមួយនៃកម្មវិធី "រួមបញ្ចូលគ្នា" របស់អង្គការ ខេប។ ដោយសារតែអង្គការ ខេប ដើរតួនាទីជាទំនាក់ទំនងរវាងម្ចាស់ជំនួយធំៗជាច្រើនដែលជាហេតុបង្កឲ្យមានឱកាសសម្រាប់គម្រោងនានាដើម្បីបង្កើតគំនិតផ្តួចផ្តើម។ ក្នុងករណី E2L គម្រោងនេះបានប្រើប្រាស់អភិក្រមតែមួយគត់ដើម្បីអភិវឌ្ឍវិស័យអប់រំរួមទាំងការប្រើប្រាស់វិធីសាស្ត្រជំនួយតាមសាលាដែលត្រូវបានជំរុញដោយភាគីពាក់ព័ន្ធ។ តាមរយៈបណ្ណាល័យសតវត្សរ៍ទី២១ មានការអន្តរាគមន៍អក្ខរកម្មថ្នាក់ដំបូងដែលរួមបញ្ចូលទាំងប្រអប់ឧបករណ៍អក្ខរកម្ម (ហិបអំណាន) ប្រព័ន្ធឆ្លើយតបរហ័សដើម្បីធានាថា កុមារទាំងអស់កំពុងអានជាមួយជំនាញ រួមមានការសិក្សាតាមរយៈទូរសព្ទឆ្លាតវៃ និងអប់រំបំណិនជីវិត។

## សកម្មភាពសំខាន់ៗ

- លើកកម្ពស់ភាពងាយស្រួលទទួលការអប់រំតាមរយៈអាហារូបករណ៍សម្រាប់កុមារក្រីក្រ និងសេវាសុខភាពសម្រាប់កុមារដែលកំពុងប្រឈមនឹងបញ្ហារាងកាយ។
- លើកកម្ពស់គុណភាពអប់រំតាមរយៈការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រី ដែលផ្តោតលើសមាសភាគទាំង៦នៃក្របខ័ណ្ឌសាលាកុមារមេត្រី។
- ដោះស្រាយកង្វះខាតគ្រូតាមរយៈការឧបត្ថម្ភគាំទ្រដល់គរុសិស្ស និងជ្រើសរើសគ្រូសហគមន៍ដែលស្ថិតនៅក្នុងមូលដ្ឋាន។
- លើកកម្ពស់អំណានថ្នាក់ដំបូងតាមរយៈការប្រើប្រាស់សៀវភៅស្តង់ដាអំណាន សម្ភារអំណាន បណ្ណាល័យសតវត្សរ៍ទី២១ និងសម្ភារបច្ចេកវិទ្យា (ថេបប្លេត ទូរទស្សន៍ឆ្លាត និងកុំព្យូទ័រ)។
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដល់គណៈគ្រប់គ្រងសាលារៀនដែលទាក់ទងនឹងកម្មវិធីអំណោយសាលារៀន។
- លើកកម្ពស់ការចូលរួមពីមាតាបិតា និងសហគមន៍តាមរយៈគណៈកម្មការទ្រទ្រង់សាលារៀន និងគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ( **CEFAC)**។
- បង្កើនការផ្លាស់ប្តូរ និងបន្តឱ្យមាននៅកម្រិតសាលាមធ្យមសិក្សា។



*ពង្រីកបណ្ណាល័យសតវត្សរ៍ទី ២១: បណ្ណាល័យថ្មីនិងស្អាតដែលប្រើគោលការណ៍រចនាទំនើបត្រូវបានដាក់បញ្ចូលក្នុងសាលារៀនជាង១០ ចាប់តាំងពីការចាប់ផ្តើម។*

## គោលបំណងចម្បង

គោលបំណង និងទិសដៅគម្រោងគឺសង្កត់ធ្ងន់ទៅលើក្របខ័ណ្ឌគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួង។ក្នុងន័យនេះ សាលាត្រូវអភិវឌ្ឍន៍ផែនការចម្រុះលក្ខណៈទាំង៦នៃគោលនយោបាយ និងការបញ្ចូលបច្ចេកទេសផ្តោតលើវិធីសាស្ត្រគុណភាព និងការគ្រប់គ្រងការអប់រំ។ ក្របខ័ណ្ឌគោលបំណងផ្លូវការរបស់គម្រោងមានដូចខាងក្រោម៖

**គោលបំណងគម្រោង:** ដើម្បីអភិវឌ្ឍន៍គំរូសាលាកុមារមេត្រីដែលពិតជាមានលក្ខណៈល្អនៅក្នុងផ្នែកជាច្រើន រួមមាន៖ គុណភាពអប់រំ កម្មវិធីបញ្ចូលគ្នា និងការចូលរួមពីភាគីពាក់ព័ន្ធក្នុងស្រុក។

**គោលបំណងទី១៖** បង្កលក្ខណៈងាយស្រួលទទួលការអប់រំ (ជាពិសេស កុមារី និងកុមារងាយរងគ្រោះ) លើកកម្ពស់តំបន់គោលដៅ។

**គោលបំណងទី២៖** ប្រសិទ្ធភាពការអប់រំ (ឧ.គុណភាពអប់រំ) លើកកម្ពស់តាមរយៈការអភិវឌ្ឍ និងអនុវត្តវិធីសាស្ត្រសាលាកុមារមេត្រី ដើម្បីឆ្លើយតបនឹងតម្រូវការកុមារងាយរងគ្រោះ ជាពិសេស កុមារី។

**គោលបំណងទី៣៖** សមត្ថភាពអំណានរបស់កុមារកាន់តែប្រសើរឡើងផ្អែកលើទិន្នន័យមូលដ្ឋានថ្នាក់ដំបូង (ថ្នាក់ទី១-៣)។

**គោលបំណងទី៤៖** បង្កើនសមត្ថភាពគ្រប់គ្រងសាលារៀន ដើម្បីគ្រប់គ្រងជំនួយអភិវឌ្ឍន៍បង្កើនវិធីពង្រឹងលក្ខណៈងាយស្រួលទទួលការអប់រំ និងគុណភាព ក៏ដូចជាការចូលរួមរបស់សហគមន៍។

## រូបភាពសកម្មភាព



***ការបង្កើនភាពពាក់ព័ន្ធនៃការអប់រំ:*** *គម្រោង E2L ដាក់អាទិភាពខ្ពស់លើការអប់រំជំនាញជីវិតមានប្រសិទ្ធភាព ដែលរួមមានជំនាញវិជ្ជាជីវៈមុនៗ ដូចជា៖ ការដាំដុះបន្លែ ការកាត់សក់ និងវិជ្ជាជីវៈផ្សេងៗទៀត។ ការលើកកម្ពស់សេវាកម្មអប់រំតាមរបៀបលើកកម្ពស់ភាពពាក់ព័ន្ធផ្នែកអប់រំ និងបំណងប្រាថ្នារបស់ឪពុកម្តាយដើម្បីចុះឈ្មោះកូនៗរបស់ពួកគាត់នៅក្នុងសាលារៀន។*



***ពិនិត្យតាមដានផលប៉ះពាល់នៃការរៀនសូត្រក្នុងការអាន:*** *គម្រោង E2L គ្រប់គ្រងការវាយតម្លៃអំពីការអានរបស់កុមារថ្នាក់ដំបូងនៅលើមូលដ្ឋានទៀងទាត់មួយ ហើយក៏បានរកឃើញថាមានភាពប្រសើរឡើងយ៉ាងខ្លាំងលើសមត្ថភាពអានរបស់កុមារចាប់តាំងពីគម្រោងចាប់ផ្តើម។ ការធ្វើតេស្ត EGRA ត្រូវបានគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នដោយប្រើឧបករណ៍អេឡិចត្រូនិចដើម្បីធានានូវកម្រិតជឿជាក់ខ្ពស់។*

# គម្រោង ងាយស្រួលរៀន (E2L)

*"ការរៀបចំគម្រោងដោយប្រើសកម្មភាពចម្រុះដើម្បីធានានូវផលជះរយៈពេលយូរក្នុងការអប់រំ"*

## ការពង្រីកកម្មវិធីទៅកម្រិតអនុវិទ្យាល័យ

ចាប់តាំងពីឆ្នាំ២០១៧មក គម្រោងងាយស្រួលរៀនបានរៀបចំពង្រីកកម្មវិធីសំខាន់ៗទៅកម្រិតអនុវិទ្យាល័យ (ថ្នាក់ទី៧ ដល់ទី៩)។ សាលារៀនពីរដែលទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈគឺស្ថិតនៅក្នុងតំបន់ជិតសាលាបឋមសិក្សា ត្រូវបានគាំទ្រដោយគម្រោងងាយស្រួលរៀនផងដែរ។ យុទ្ធសាស្ត្រនេះនឹងធានាថា សិស្សានុសិស្សនៅសាលាបឋមសិក្សាគម្រោងដែលកំពុងបញ្ចប់ថ្នាក់ទី៦ នឹងអាចផ្លាស់ប្តូរទៅសាលារៀនមធ្យមសិក្សាដែលមានសេវាអប់រំផងដែរត្រូវបានកំណត់ជាកម្រិត និងមានគុណភាពល្អ។ ការវិនិយោគនៅតាមសាលាមធ្យមសិក្សា រួមមាន៖ ការផ្តល់អាហារូបករណ៍ ការលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ ការបង្រៀនអំពីប្រព័ន្ធបច្ចេកវិទ្យា ICT និងលើកកម្ពស់ការអប់រំជីវិតដែលធ្វើឱ្យការអប់រំនៅមូលដ្ឋានកាន់តែមានទំនាក់ទំនងគ្នាទៅនឹងបរិបទក្នុងមូលដ្ឋាន។ នេះរាប់បញ្ចូលទាំងការបង្រៀនកម្មវិធីបំណិនជីវិតក្នុងជំនាញទាក់ទងនឹងសង្គម។ (ឧ.ការទប់ស្កាត់ការរំលោភបំពានគ្រឿងញៀន) បំណិនជីវិតសេដ្ឋកិច្ច (ឧ.ជំនាញទីផ្សារ ផ្សារប្រតិដ្ឋជាដើម) និងជំនាញវិជ្ជាជីវៈមូលដ្ឋាន (ឧ.ការដាំដុះបន្លែកាត់សក់ជាដើម។ល។)។



← ***កន្លែងពិសោធន៍ ICT ថ្មីសម្រាប់សាលាអនុវិទ្យាល័យគោលដៅ:*** *E2L បានផ្តល់នូវបន្ទប់ពិសោធន៍កុំព្យូទ័រពីរដើម្បីកំណត់ទិសដៅសាលារៀនដែលប្រើបច្ចេកវិទ្យា **Thin Client**។ បច្ចេកវិទ្យានេះមិនមានការផ្លាស់ប្តូរផ្នែកណាមួយដែលបន្ថយភាពមិនប្រក្រតីនៃម៉ាស៊ីន ហើយប្រើតែ១ភាគ ១០ នៃថាមពលដែលកុំព្យូទ័រធម្មតាប្រើប៉ុណ្ណោះ។ នេះបញ្ជាក់ថាការចំណាយលើថាមពលនឹងមិនលើកទឹកចិត្តឱ្យបើកបន្ទប់ពិសោធន៍ចំហចោលទៀងទាត់ទេ។ ការចុះពិនិត្យតាមដានជាទៀងទាត់របស់សាលារៀនបានរកឃើញការប្រើប្រាស់របស់សិស្សចំពោះបន្ទប់ពិសោធន៍ និងកម្រិតជំនាញក្នុងការប្រើប្រាស់ ICT ដ៏រឹងមាំក្នុងចំនោមសិស្សជាច្រើនមានអត្រាខ្ពស់។*





← ***ការអប់រំបំណិនជីវិតនៅតាមសាលាមធ្យមសិក្សា:*** *គម្រោង **E2L** បានណែនាំកម្មវិធីសិក្សាជំនាញបំណិនជីវិតទៅក្នុងសាលារៀនគោលដៅដែលផ្តល់ឱ្យសិស្សនូវជម្រើសមួយចំនួននៅក្នុងជំនាញជាក់ស្តែងដែលពួកគេចង់សិក្សា។ ផ្សារប្រតិដ្ឋត្រូវបានរៀបចំឡើងដើម្បីបង្កឱកាសសិស្សអាចលក់ផលិតផលដែលពួកគាត់ផលិតនៅក្នុងថ្នាក់បំណិនជីវិត (ឧ.បន្លែ ផលិតផលដេរត្បាញជាដើម)។ ក្នុងកំឡុងពេលពិសោធន៍ទាំងនេះសិស្សានុសិស្សចេះប្រើដូចជា៖ ជំនាញទីផ្សារដើម្បីកំណត់តម្លៃធ្វើឱ្យមានការផ្លាស់ប្តូរ និងកំណត់ពីចំណូល និងចំណាយ។*

***ការរៀនសូត្រចល័ត:*** *សាលារៀន **E2L** ផ្តល់ឱ្យក្មេងគ្រប់វ័យនូវឱកាសដើម្បីចូលរួមដោយខ្លួនឯងដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច។ ថេបប្លេតដែលមានកម្មវិធីកុំព្យូទ័រភាសាខ្មែរត្រូវបានផ្តល់ជូនដល់សាលារៀន ដើម្បីឱ្យកុមារគ្រប់រូបអាចរៀនតាមល្បឿនរបស់ខ្លួន និងតាមរបៀបដែលចាប់អារម្មណ៍ និងទាក់ទាញ។* →



# គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (QLE Expansion)

*“ការលើកកម្ពស់បរិស្ថានសិក្សាដើម្បីការលូតលាស់កុមារ ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការ Save the Children និងទីភ្នាក់ងារណ័រវេដើម្បីសហប្រតិបត្តិការអភិវឌ្ឍ (NORAD) |
| **អ្នកទទួលផលផ្ទាល់** | សិស្សចំនួន ២២.០០០នាក់ |
| **ថវិកាបានទទួល ឆ្នាំ២០១៨** | ១២៦.៥០០ ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ៥,៧៥ ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | ៣ ខេត្ត (កំពង់ចាម ត្បូងឃ្មុំ និងព្រះវិហារ) |
| **ស្រុកគ្របដណ្តប់** | ១៦ ស្រុក |
| **បឋមសិក្សាគោលដៅ** | ៤៤ សាលារៀន |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ១ មករា ២០១៦ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣១ ធ្នូ ២០១៨ |

## បច្ចុប្បន្នភាពគម្រោង

នេះជាឆ្នាំទី៣នៃការបញ្ចប់ការអនុវត្តគម្រោង QLE Expansion នៅក្នុងខេត្តគោលដៅទាំង៣គឺៈ កំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រះវិហារ ដោយពេញលេញ រួមទាំងគម្រោង និងវដ្តអភិវឌ្ឍសាលារៀន។ គម្រោងនេះផ្តោតលើ QLE (បរិស្ថានសិក្សាប្រកបដោយគុណភាព) ដែលបានរៀបចំដោយអង្គការសង្គ្រោះកុមារ(SC) មានគោលការណ៍សំខាន់ៗ៤គឺៈ ១). កម្មវិធីអប់រំសមស្របតាមតម្រូវការផ្លូវអារម្មណ៍ និងផ្លូវចិត្តរបស់កុមារ ២). កម្មវិធីអប់រំត្រូវបានការពារសុខមាលភាពរាងកាយរបស់កុមារ ៣).កម្មវិធីអប់រំលើកទឹកចិត្ត និងគាំទ្រការចូលរួមយ៉ាងសកម្មពីសិស្សតាមរយៈការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឲ្យប្រសើរឡើងដល់ការសិក្សារបស់សិស្សទាំងអស់ និង ៤).កម្មវិធីអប់រំអាណាព្យាបាល និងសហគមន៍។ ក្របខ័ណ្ឌគម្រោង QLE ព្យាយាមលើកកម្ពស់វិធីសាស្រ្តសរុបចំពោះការអភិវឌ្ឍការអប់រំ និងចែករំលែកវិធីដូចគ្នាទៅក្នុងទស្សនៈល្អៗ និងគោលនយោបាយរបស់សាលាកុមារមេត្រី។

ការប្រើប្រាស់ក្របខ័ណ្ឌខាងលើ គម្រោង QLE បានគាំទ្រសកម្មភាពនានានៅក្នុងផ្នែកជាច្រើនដើម្បីលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយគុណភាពដល់កុមារទាំងនៅផ្ទះ និងនៅសាលារៀន។ គម្រោងក៏បានផ្តោតសំខាន់លើការលើកកម្ពស់អំណានថ្នាក់ដំបូង និងបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយសាលាដើម្បីបង្កើត“**កន្លែងអាន**” និងសកម្មភាពជាច្រើនទៀតសម្រាប់កុមារ។ វិធីសាស្រ្តនេះធ្វើឱ្យកម្មវិធីអង្គការ SC គេស្គាល់ថាជាកម្មវិធីលើកកម្ពស់អក្ខរកម្ម។

ពេលគម្រោងបញ្ចប់វដ្ត អង្គការ ខេប បានចរចាជាមួយងអង្គការ SC ដើម្បីបន្តគម្រោង១ឆ្នាំទៀតដោយផ្តោតលើផលជះគម្រោងប្រកបដោយនិរន្តរភាពបន្ទាប់ពីអនុវត្ត៣ឆ្នាំ។ កាលបរិច្ឆេទអនុវត្តបន្តនឹងចាប់ផ្តើមក្នុងខែមករា ឆ្នាំ២០១៩ខាងមុខនេះ។

### សកម្មភាពសំខាន់ៗ

- រៀបចំជារចនាសម្ព័ន្ធការងារ (យន្តការការងារ) សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ការិយាល័យអប់រំ យុវជន និងកីឡាស្រុក។
- បង្កើតឱ្យមានគ្រូបង្គោលដើម្បីជួយបំប៉នដល់គ្រូតាមសាលារៀនគោលដៅ និងចុះជួយដល់សាលារៀនជាប្រចាំ។
- ការបំប៉នសមត្ថភាពគ្រូដោយផ្តោតលើគណិទ្យាវិទ្យា ភាសាខ្មែរ បំណិនជីវិត និងគោលការណ៍ទាំងបួនរបស់គម្រោង QLE Exp.។
- បានបង្កើតក្រុមប្រឹក្សាភិបាលសាលារៀន ដើម្បីជួយដល់សាលាគោលដៅទាំងបីខេត្ត។
- បង្កើតគណៈកម្មាធិការថ្នាក់រៀនជួយដល់គ្រូដើម្បីជួយដល់ការបង្រៀននិងរៀន។

### គោលបំណង

គម្រោងមានគោលបំណងពង្រីក (១) ការទទួលបានការអប់រំ/ការចូលរៀនសម្រាប់កុមារដែលពុំបានទទួលសេវាអប់រំ (២) បង្កើនគុណភាពសិក្សារបស់កុមារ ជាពិសេសកុមារជួបការលំបាក និង (៣) គាំទ្រដល់ក្រសួងអប់រំ/មន្ទីរអប់រំ/ការិយាល័យអប់រំស្រុក (រួមទាំងសាលារៀន) ដើម្បីកំណត់បញ្ហា និងដំណោះស្រាយសម្រាប់ពង្រីកការទទួលបានការអប់រំ/ការចូលរៀននៅតាមតំបន់ជនបទ និងដាច់ស្រយាល និងសម្រាប់ការកែលម្អគុណភាពសិក្សារបស់កុមារ៕

## រូបភាពសកម្មភាព



*កិច្ចប្រជុំគណៈកម្មការក្រុមប្រឹក្សាសាលាពិភាក្សាអំពីតម្រូវការគាំទ្រសាលារៀន។*



*សិស្សដាំកូនឈើ និងរៀបចំសួនច្បារក្នុងបរិវេណឱ្យមានសម្រស់ស្រស់ស្អាត។*



*ការធ្វើតេស្តសិស្សដើម្បីវាយតម្លៃលើផលជះរបស់គម្រោងចំពោះការសិក្សាសិស្ស។*



*ការរៀបចំបន្ទប់សង្គ្រោះបឋមនៅសាលារៀនគោលដៅដើម្បីផ្តល់សេវាថែទាំសុខភាពសិស្ស។*

## ផលជះរបស់គម្រោង

នៅពេលគម្រោងបិទបញ្ចប់នៅឆ្នាំនេះ បានសម្រេចលទ្ធផលសំខាន់ៗជាច្រើនធ្វើឱ្យសេវាអប់រំមានលក្ខណៈប្រសើរឡើងច្រើននៅបឋមសិក្សាទាំង៤៤សាលា ដែលទទួលបានការគាំទ្រពីគម្រោង។ លទ្ធផលគម្រោងទាំងអស់នោះ រួមមានៈ

- **ផលជះលើការសិក្សាៈ** នៅពេលសាលាវិស្សមកាលនៅក្នុងខែសីហា ឆ្នាំ២០១៨នេះ គម្រោងបានរៀបចំការធ្វើតេស្តកម្មវិធីសិក្សាលើភាសាខ្មែរ និងគណិតវិទ្យា ដើម្បីវាយតម្លៃផលជះលើការសិក្សា។ នៅក្នុងលក្ខខណ្ឌពិន្ទុមធ្យមរួម លទ្ធផលសិក្សាបង្ហាញអំពីការធ្វើឱ្យប្រសើរឡើងនូវពិន្ទុចុងគ្រា បើប្រៀបធៀបទៅនឹងពិន្ទុមូលដ្ឋានដែលបានចាប់ផ្តើមនៅពេលវដ្តអភិវឌ្ឍន៍គម្រោង។
- **សុខភាពអប់រំៈ** គម្រោងបានបង្កើតបន្ទប់សង្គ្រោះបឋមនៅសាលាគោលដៅទាំង៩ រួមទាំងគាំពារ និងព្យាបាលជម្ងឺកម្រិតស្រាល និងជំនួយបឋម និងដើម្បីបង្កើនភាពទាក់ទាញសេវាអប់រំដល់ឪពុកម្តាយ។
- **បង្កើតកន្លែងអានៈ** គម្រោងបានបង្កើត “**កន្លែងអាន**” នៅក្នុងសហគមន៍មូលដ្ឋានទាំង៤០សាលាដើម្បីបង្កើនកម្រិតអក្ខរកម្ម និងពង្រឹងជំនាញអាន។ បន្ទាប់ពីអនុវត្តគម្រោងរយៈពេល៣ឆ្នាំរួចមក ជាទូទៅ មន្ត្រីកម្មវិធីបានរកឃើញកម្រិតខ្ពស់នៃការប្រើប្រាស់កន្លែងអាន និងការគាំទ្រយ៉ាងពេញទំហឹងពីមន្ត្រីអប់រំនៅមូលដ្ឋាន និងឪពុកម្តាយ។
- **ការអភិវឌ្ឍឯកសារបណ្តុះបណ្តាលដើម្បីសម្របសម្រួលការឆ្លើយតបរបស់គម្រោងៈ** ដើម្បីធានានូវសកម្មភាពបន្តជោគជ័យទៀតបាន ទីប្រឹក្សាគម្រោងបានចងក្រងឯកសារអំពីកម្មវិធីបណ្តុះបណ្តាលដើម្បីសម្រួលកន្លែងអាន បង្កើនការបង្រៀនអំណាន និងលើកកម្ពស់ការបង្រៀនគណិតវិទ្យា។
- **ការពង្រឹងសមត្ថភាពអប់រំ និងការកសាងស្ថាប័នៈ** គម្រោងទទួលបានជោគជ័យក្នុងការពង្រឹងគណៈកម្មការអភិបាលកិច្ចសាលារៀន ដោយមានការចូលរួមយ៉ាងសកម្មពីសហគមន៍ដើម្បីបង្កើនសេវាកម្មសាលារៀន។ នេះរួមបញ្ចូលការបង្កើតក្រុមប្រឹក្សាភិបាលនៅក្នុងសាលារៀនចំនួន៦ ការជួសជុលថ្នាក់រៀននៅសាលារៀនចំនួន៩ និងបង្កើតបន្ទប់សង្គ្រោះបឋមនៅសាលារៀនទាំង៩។

# គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀន តាមរយៈការគាំទ្រពីសហគមន៍ (REACH II/រីក ២)



*“ សហគមន៍រឹងមាំកសាងបាននូវសាលារៀនដ៏រឹងមាំ! ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការវីវើល (We World) |
| **អ្នកទទួលផលផ្ទាល់** | សិស្ស ១៩,២៨២នាក់ (ស្រី៩,៣១៥នាក់) |
| **ថវិកាបានទទួល ឆ្នាំ២០១៨** | ៣៩៨.៩០៩,៥១ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ២០,៦៨ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | ៤ខេត្ត (ស្វាយរៀង ព្រៃវែង កំពង់ឆ្នាំង និងពោធិ៍សាត់) |
| **ស្រុកគ្របដណ្តប់** | ១០ ស្រុក (៣ ក្នុងខ.ស្វាយរៀង ១ក្នុងខ.ព្រៃវែង ៤ ក្នុងខ.កំពង់ឆ្នាំ និង ២ក្នុងខ.ពោធិ៍សាត់ |
| **សាលាបឋមគោលដៅ** | ៥៥សាលា |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | កក្កដា ២០១៥ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | មិថុនា ២០១៨ |

## បច្ចុប្បន្នភាពគម្រោង

គម្រោងរីកដំណាក់កាលទី២ បានបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ហើយបានបន្តដោយគម្រោងស្ពានរយៈពេល៦ខែ ដែលបានចាប់ផ្តើមក្នុងខែកក្កដា ឆ្នាំ២០១៨។ គម្រោងរីកដំណាក់កាលទី១បានចាប់ផ្តើមនៅឆ្នាំ២០១២ ដោយជួយគាំទ្រដល់សាលារៀននៅក្នុងខេត្តស្វាយរៀង និងព្រៃវែង ដោយប្រើប្រាស់វិធីសាស្ត្រចម្រុះ។ បន្ទាប់ពីទទួលបានជោគជ័យលើគម្រោង៣ឆ្នាំដែលមានការពេញចិត្តយ៉ាងខ្លាំងពីមន្ត្រីអប់រំក្នុងមូលដ្ឋាន អង្គការ ខេប បានចរចាជាមួយអង្គការវីវើល រៀបចំគម្រោងបន្តថ្មី ហើយពង្រីកបន្ថែមដែលគេស្គាល់ថាជាគម្រោងរីក២។ គម្រោងរីក២បានបន្តការជួយគាំទ្រសាលាក្នុងខេត្តស្វាយរៀង ព្រៃវែង ហើយបន្ថែមខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់។ នៅពេលគម្រោងរីក២បានបញ្ចប់នៅខែមិថុនា អង្គការវីវើល និងអង្គការ ខេប បានចរចារៀបចំគម្រោងស្ពានដែលហៅថា រីក២,៥ ដែលបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៨ ជាមួយនឹងផែនការបន្តគម្រោងថ្មី២ឆ្នាំទៀត ដែលហៅថាគម្រោងរីក៣។ ការរៀបចំគម្រោងក្រោយនេះនឹងបន្តជួយគាំទ្រសកម្មភាពសាលា តែនឹងផ្តោតលើសកម្មភាពការការពារកុមារ។



***←កែលម្អបរិស្ថានសិក្សានៅមត្តេយ្យសិក្សា៖*** *គម្រោងរីក២បានធ្វើឱ្យមានបរិក្ខាសម្ភារបែបនៅក្នុងសាលា៥២ និងរៀបចំឱ្យមានថ្នាក់មត្តេយ្យដែលនៅកន្លែងខ្លះមិនមានថ្នាក់មត្តេយ្យ។*

## គោលបំណង

គម្រោងរីកដំណាក់កាលទី២ មានគោលដៅពង្រឹងអក្ខរកម្ម លេខនព្វន្ត និងចំណេះដឹងកម្មវិធីបំណិនជីវិតតាមរយៈយុទ្ធសាស្ត្រចម្រុះ ដែលលើកកម្ពស់បរិស្ថានសិក្សាទាំងនៅក្នុងសាលារៀន និងនៅតាមផ្ទះក្នុងខេត្តគោលដៅទាំងបួន។

គម្រោងរីកគឺជាគម្រោងធំមួយផ្សេងទៀតរបស់អង្គការ ខេប ដែលប្រើវិធីសាស្ត្រអភិវឌ្ឍន៍ចម្រុះដើម្បីបង្កើតទិដ្ឋភាពសិក្សារៀនសូត្រផ្សេងៗច្រើនដល់សិស្ស ដូចជា៖ បង្កើតភាពងាយស្រួលចូលសាលារៀន បរិស្ថានអប់រំ ការចូលរួមរបស់សហគមន៍។ល។ ដែលឈរលើគោលនយោបាយកម្មវិធីសាលាកុមារមេត្រី។

## សកម្មភាពសំខាន់ៗ

***គម្រោងរីក២ បន្តអន្តរាគមន៍លើសកម្មភាពសំខាន់ធំៗ៨ដូចខាងក្រោម៖***

- លើកកម្ពស់ការអភិវឌ្ឍកុមារតូចដោយជួយបង្កើត និងរៀបចំបរិស្ថានរៀនសូត្រនៅក្នុងសាលាចំនួន ៥៥ និងថ្នាក់មត្តេយ្យចំនួន៧៦។
- លើកកម្ពស់ភាពងាយស្រួលចូលសាលារៀនតាមរយៈការធ្វើផែនការអភិវឌ្ឍសាលា អាហារូបករណ៍ ធ្វើបច្ចុប្បន្នភាពផែនទីសិក្សា យុទ្ធនាការប្រមូលកុមារចូលសាលារៀន ការចុះសួរសុខទុក្ខតាមផ្ទះ ការបញ្ជូនកុមារទៅព្យាបាលនៅកន្លែងផ្តល់សេវាសុខភាព។
- លើកកម្ពស់សិទ្ធិកុមារ និងការការពារកុមារ ដោយផ្តល់ការកសាងសមត្ថភាពក្រុមប្រឹក្សាកុមារបំណិនជីវិត ដែលធ្វើឱ្យការអប់រំផ្សារភ្ជាប់នឹងតម្រូវការប្រចាំថ្ងៃ
- កសាងសមត្ថភាពដល់ថ្នាក់ដឹកនាំសាលារៀនអំពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន
- កែលម្អ និងជួសជុលសាលាបឋម សាលាមត្តេយ្យ និងបណ្ណាល័យនៅគ្រប់សាលារៀន
- លើកកម្ពស់អក្ខរកម្មថ្នាក់ដំបូងដោយប្រើប្រាស់កម្មវិធីស្តង់ដាអំណាន សម្ភារអំណាន ការសិក្សាតាមបច្ចេកវិទ្យា រៀបចំប្រព័ន្ធឆ្លើយតបរហ័ស ដើម្បីកំណត់និងជួយសិស្សដែលត្រូវការអប់រំពិសេស
- ពង្រឹងការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលា មាតាបិតា និងសហគមន៍តាមរយៈការបំប៉ន ការប្រជុំ និងផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធបញ្ចូលគំនិតក្នុងផែនការអភិវឌ្ឍ
- កសាងសមត្ថភាពគ្រូ ថ្នាក់ដឹកនាំសាលានូវវិធីសាស្ត្របង្រៀនថ្មីៗ ការប្រើប្រាស់សម្ភារៈសម្បូរបែប ការបញ្ចូលបច្ចេវិទ្យាក្នុងការបង្រៀន និងរដ្ឋបាល។



***← ជួសជុលកែលម្អបណ្ណាល័យ៖*** *គម្រោងបានជួសជុលកែលម្អបណ្ណាល័យជាច្រើនសាលាផ្តល់សៀវភៅអានជាច្រើន ផ្តល់ថែបប្លែតដែលជួយឱ្យមានការសិក្សាតាមអេឡិត្រូនិច។*

## ផលជះរបស់គម្រោង

ការវាយតម្លៃគម្រោងពីសំណាក់ស្ថាប័នឯករាជនៅខែមីនា និងមេសា ឆ្នាំ២០១៨ បានរកឃើញផលជះផលវិជ្ជមានខ្ពស់៖

- **បានអភិវឌ្ឍន៍ការអាន៖** គ្រូ មាតាបិតា និងសិស្សបានមានមតិថា សមត្ថភាពការអានរបស់សិស្សមានភាពប្រសើរឡើងច្រើន ដែលក្រសួងសហការជាមួយអង្គការបានបង្កើតប្រព័ន្ធវាយតម្លៃតាមដំណាក់ និងរៀបចំប្រព័ន្ធឆ្លើយតបរហ័សដើម្បីជួយដល់សិស្សរៀនយឺត។
- **ការប្រើប្រាស់បច្ចេកវិទ្យាមានការកើនឡើង៖** គ្រប់សាលាដែលទទួលបានថែបប្លែតសម្រាប់ឱ្យសិស្សរៀនដោយមានកម្មវិធីអំណាននៅក្នុងបណ្ណាល័យសម្រាប់ប្រើប្រាស់។ គ្រប់សាលារៀនដែលបានទទួលកុំព្យូទ័រ និងម៉ាស៊ីនព្រីនធ័របានប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពក្នុងការធ្វើរបាយការណ៍ និងតាមដានទិន្នន័យ។
- **ការបង្រៀនមានភាពប្រសើរឡើង៖** មន្ទីរ ការិយាល័យអប់រំ មាតាបិតា គ្រូ នាយក/នាយិកា បានបញ្ចេញយោបល់ថា វិធីសាស្ត្របង្រៀនមានភាពប្រសើរ។ គ្រូ នាយក/នាយិកាយល់ឃើញថា ការបំប៉នវិធីសាស្ត្រកុមារមេត្រី ការបង្កើតសម្ភារបង្រៀនគឺពិតជាបានជួយគាំទ្រឱ្យការបង្រៀនរបស់ពួកគាត់មានការផ្លាស់ប្តូរ។ មានការងារក្រុមច្រើន មានការប្រើសំណួរច្រើន អាកប្បកិរិយាមេត្រីទៅរកសិស្ស និងលទ្ធផលការសិក្សាប្រសើរជាងមុន។ មាតាបិតា និងគ្រូមានប្រសាសន៍ថា ពួកគាត់មានអារម្មណ៍ថា ”សិស្សឆ្លាត” ជាងពីមុន។
- **មានភាពជាម្ចាស់ចំពោះសាលារដ្ឋ៖** វិធីសាស្ត្ររបស់ខេបកសាងភាពជាម្ចាស់តាមរយៈឱ្យអ្នកពាក់ព័ន្ធដឹកនាំធ្វើផែនការ ដោយប្រើបញ្ជីសេវាកម្មដែលធ្វើឱ្យសាលារៀនមាននិរន្តរភាព តាមរយៈការពង្រឹងគំនិតដែលថា សាលាជារបស់សហគមន៍ជារបស់គ្រូ ជារបស់នាយក/នាយិកា។
- **បរិស្ថានសាលាមានការអភិវឌ្ឍប្រសើរ៖** គ្រប់អ្នកពាក់ព័ន្ធបានបញ្ចេញយោបល់ថា ក្នុងសាលាមានភាពស្រស់ស្អាតជាងមុន មានអនាម័យជាងមុន(មានកន្លែងលាងដៃ មានទឹកស្អាត មានផុងសម្រាម) ហើយលើសពីនោះទៀតនៅក្នុងថ្នាក់រៀនមានការរៀបចំស្អាតបែបកុមារមេត្រី (កែលម្អបរិក្ខាសម្រាប់មត្តេយ្យសិក្សា គ្រប់ថ្នាក់រៀនមានសម្ភារបង្រៀន)។



***ការធ្វើតេស្តអំណានថ្នាក់ដំបូង៖*** *ការវាយតម្លៃសិស្សម្នាក់ៗបានធ្វើឡើងដោយមានការទទួលខុសត្រូវតាមស្តង់ដាខ្ពស់នៅក្នុងគម្រោងលើការសិក្សារបស់សិស្ស។*

# គម្រោង គ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ (SML)

*“ការលើកកម្ពស់អភិបាលកិច្ចល្អនៅសាលារៀនតាមមូលដ្ឋាន ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការឆាលហ្វានកម្ពុជា |
| **អ្នកទទួលផលផ្ទាល់** | ៣.៦៥៧ (ស្រី១.៨៥៤នាក់) |
| **ថវិកាបានទទួល ឆ្នាំ២០១៨** | ៦៩.១២៧ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ១៨,៩០ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្របដណ្តប់** | ១ (ក្រចេះ) |
| **ស្រុកគ្របដណ្តប់** | ១ ស្រុក |
| **បឋមសិក្សាគោលដៅ** | ១១ សាលា |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | កក្កដា ២០១៥ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | មិថុនា ២០១៨ |

## គោលបំណង

គម្រោង **SML** មានគោលបំណងដូចខាងក្រោម: "ភាពស្និទ្ធស្នាលរបស់កុមារក្នុងសាលារៀនគោលដៅមានភាពប្រសើរឡើងដោយសារតែភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនៅក្នុងសាលាបឋមសិក្សាគោលដៅចំនួន១១"។ ***គោលដៅ សំខាន់ៗ រួមមាន៖***

១. បង្កើនជំនាញបច្ចេកទេសរបស់សមាជិកក្រុមការងារបណ្តុះបណ្តាល និងតាមដានត្រួតពិនិត្យថ្នាក់ស្រុក(**DTMT**) ក្នុងការផ្តល់ការគាំទ្រដល់នាយកសាលានៅក្នុងសាលាបឋមសិក្សាគោលដៅទាំង១១។

២. សមត្ថភាពរបស់អ្នកគ្រប់គ្រងសាលារៀនមានភាពប្រសើរឡើងតាមរយៈការគាំទ្រការកសាងសមត្ថភាព។

៣. កែលម្អបរិស្ថានសាលារៀនដែលមានលក្ខណៈអំណោយផលដល់កុមារតាមរយៈការពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងសាលារៀន និងជំនួយឥតសំណងដោយភាគីពាក់ព័ន្ធ។

៤. គណៈកម្មការទ្រទ្រង់សាលារៀនបង្ហាញពីការបង្កើនសមត្ថភាពផ្អែកលើបញ្ជីនៃលក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈស្តង់ដាដែលរួមមានការចូលរួម ការត្រួតពិនិត្យ និងការគ្រប់គ្រងធនធាន។

## បច្ចុប្បន្នភាពគម្រោង

គម្រោង **SML** បានបញ្ចប់ការអនុវត្តន៍រយៈពេល៣ឆ្នាំ ក្នុងឆ្នាំ២០១៨ និងបានផ្តោតសំខាន់លើការហ្វឹកហ្វឺនក្នុងការងារដើម្បីលើកកម្ពស់ជំនាញភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងល្អរវាងអ្នកគ្រប់គ្រងសាលារៀន និងក្រុមការងារបណ្តុះបណ្តាល និងតាមដានត្រួតពិនិត្យថ្នាក់ស្រុក ( **DTMTs)** ដើម្បីឱ្យពួកគេមានសមត្ថភាពក្នុងការគាំទ្រដល់អ្នកគ្រប់គ្រងសាលារៀន។ ទាំងនេះសំដៅទៅលើការអភិវឌ្ឍ និងការអនុវត្តផែនការកែលម្អសាលារៀនដែលប្រើជំនួយសាលារៀនដើម្បីធ្វើឱ្យសាលារៀនគោលដៅទាំងអស់មានភាពស្និទ្ធស្នាលជាមួយកុមារ។ គម្រោងនេះក៏បានផ្តល់នូវសិក្ខាសាលាបណ្តុះបណ្តាលបន្ថែមទៀត ដើម្បីគាំទ្រដល់សមាជិកគណៈកម្មការទ្រទ្រង់សាលារៀន ឱ្យពួកគេចូលរួមកាន់តែច្រើនក្នុងការអប់រំ និងផ្តល់ការទទួលខុសត្រូវបន្ថែមទៀតដល់ការបំពេញការងារនៅសាលារៀន។

កិច្ចប្រជុំឆ្លុះបញ្ចាំងជាទៀងទាត់ដែលត្រូវបានធ្វើឡើងដោយភាគីពាក់ព័ន្ធក្នុងអំឡុងឆ្នាំនេះផ្តោតលើវិស័យរីកចំរើនចំនួន៣គឺ: ១). ការគ្រប់គ្រង និងការរៀបចំសាលារៀនកាន់តែប្រសើរ ២). ការចូលរួមកាន់តែប្រសើរពីគណៈកម្មការទ្រទ្រង់សាលា និង ៣). ក្រុមប្រឹក្សាកុមារដែលឥឡូវនេះមានរចនាសម្ព័ន្ធប្រតិបត្តិការច្បាស់លាស់សម្រាប់ការចូលរួមក្នុងការគ្រប់គ្រងសាលារៀនដោយសិស្ស។ បច្ចុប្បន្ននេះ ការផ្លាស់ប្តូរទាំងនេះហាក់បីដូចជាកាន់តែរឹងមាំនៅក្នុងវប្បធម៌នៃសាលារៀននីមួយៗហើយមានក្តីសង្ឃឹមថា ផលប៉ះពាល់ទាំងនេះអាចត្រូវបានបន្តនៅពេលដែលគម្រោងនេះបានបញ្ចប់វដ្តរបស់ខ្លួន។

យ៉ាងណាក៏ដោយ ទំហំតូចនៃកញ្ចប់ថវិកាសាលាដែលបានផ្តល់ឱ្យ បើប្រៀបធៀបទៅនឹងតម្រូវការដ៏ធំនៅក្នុងសាលារៀនគោលដៅគឺជាបញ្ហាប្រឈមដ៏សំខាន់ក្នុងការអនុវត្តគម្រោង **SML**។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ គម្រោងបានតស៊ូមតិជាមួយម្ចាស់ជំនួយសម្រាប់អន្តរាគមន៍បន្ថែមទៀត និងការរៀបចំគម្រោងដែលមានការរួមបញ្ចូលគ្នាកាន់តែច្រើនដែលអនុវត្តយ៉ាងជិតស្និទ្ធតាមវិធីសាស្ត្រធម្មតារបស់អង្គការខេប ក្នុងការរៀបចំគម្រោងទាំងមូល។ ដូច្នេះ ការរៀបចំវដ្តគម្រោងថ្មីនេះកំពុងស្ថិតនៅក្នុងការពិចារណានឹងកសាងលើមូលដ្ឋានគ្រឹះដែលបានរៀបចំរួចហើយ។

## រូបភាពសកម្មភាព



<u>សេចក្តីបញ្ជាក់:</u> សិស្សម្នាក់បង្ហាញនូវអារម្មណ៍របស់នាងអំពីការរៀបចំបណ្ណាល័យថ្មី។ ការធ្វើផែនការកែលម្អសាលារៀន សិក្ខាសាលាបណ្តុះបណ្តាលអ្នកគ្រប់គ្រងសាលា និងសមាជិក **DTMT** ស្តីពីការដឹកនាំ និងជំនាញគ្រប់គ្រងការបង្រៀន អ្នកគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសមាជិករបស់គណៈកម្មការទ្រទ្រង់សាលារៀនចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាទៅកាន់ខេត្តស្វាយរៀង។

## សកម្មភាពសំខាន់ៗ

- ផ្តល់វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសទាក់ទងនឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់សមាជិក **DTMT** ស្រុកឆ្លូង។
- គាំទ្រការត្រួតពិនិត្យផ្នែកបច្ចេកទេសដល់អ្នកគ្រប់គ្រងសាលាដោយសមាជិក **DTMT**។
- ប្រើប្រាស់សមាជិក **DTMT** ដើម្បីផ្តល់ការគាំទ្រដល់អ្នកគ្រប់គ្រងសាលាដោយផ្អែកលើការណែនាំអំពីការកសាងសមត្ថភាពដែលផ្តល់ដោយគម្រោង។
- អនុវត្តកិច្ចប្រជុំបច្ចេកទេសថ្នាក់កម្រងជាមួយគ្រូដែលដឹកនាំដោយអ្នកគ្រប់គ្រងសាលា និងសមាជិក **DTMT** ដែលផ្តោតលើជំនាញបង្រៀន និងការផលិតសម្ភារសិក្សា។
- បង្កើតផែនការកែលម្អសាលារៀនក្នុងលក្ខណៈរួមមួយជាមួយជំនួយឥតសំណងដើម្បីគាំទ្រដល់ការវិវឌ្ឍន៍ឆ្ពោះទៅរកបរិស្ថានសាលារៀនដែលប្រសើរជាងមុន។
- ផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាពដល់សមាជិក **SSC** ស្តីពីតួនាទី និងភារកិច្ចរបស់ពួកគេលើគោលនយោបាយអប់រំសំខាន់ៗ (ឧ. **EFA**) ការតស៊ូមតិនិងការចូលរួមរបស់សហគមន៍។
- អនុវត្តការវាយតំលៃ **SSC** នៅចំណុចផ្សេងៗគ្នា (មុនពេលអនុវត្ត អំឡុងពេលអនុវត្ត និងក្រោយពេលអនុវត្ត) អំឡុងពេលគម្រោងប្រតិបត្តិការ។
- អនុវត្តការវាយតម្លៃតាមសាលារៀនដោយប្រើបញ្ជីត្រួតពិនិត្យអេឡិចត្រូនិចដើម្បីវាយតំលៃការអនុវត្ត **CFS**។

# គម្រោង វិធីសាស្រ្តសរុបដើម្បីពង្រឹងអំណាន សម្រាប់កុមារ( ត្រាក់/TRAC III)

*“ការបង្កើតវិធីសាស្រ្តថ្មីៗសម្រាប់ពង្រឹងអំណានសម្រាប់កុមារ ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិ Phoenix |
| អ្នកទទួលផលផ្ទាល់ | ៤.៧៤៩នាក់ (កុមារី ២.២៥៩នាក់) |
| ថវិកាបានទទួល ឆ្នាំ២០១៨ | ១៦០.១៥៨ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផល | ៣៣,៧២ដុល្លាអាមេរិកក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | កំពង់ចាម និងត្បូងឃ្មុំ |
| ស្រុកគ្របដណ្តប់ | ៥ស្រុក (៣ស្រុកនៅត្បូងឃ្មុំ ២ស្រុកនៅកំពង់ចាម) |
| បឋមសិក្សាគោលដៅ | ១២ សាលា (៦សាលាក្នុងឆ្នាំទី១ និង ១២សាលានៅឆ្នាំទី២ និង ទី៣) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ កក្កដា ២០១៧ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០២០ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង **TRACIII** បានបញ្ចប់អន្តរាគមន៍ឆ្នាំទី១របស់ខ្លួនយ៉ាងជោគជ័យ។ គម្រោងបានប្រតិបត្តិការចំនួន៦សាលាគោលដៅនៅឆ្នាំ២០១៨ ហើយកំពុងបន្ត៦សាលាបន្ថែមទៀតនៅឆ្នាំទី២នេះ ឆ្នាំសិក្សា២០១៨-១៩។ អង្គការ ខេប បានបង្កើតគម្រោង **TRACIII** ឡើងដើម្បីពង្រឹងអំណានសម្រាប់កុមារថ្នាក់ដំបូងតាមរយៈប្រព័ន្ធអន្តរាគមន៍មួយផ្តល់វិធីសាស្រ្តសរុបដើម្បីពង្រឹងអំណាន។ វិធីសាស្រ្តនេះមិនត្រឹមតែសកម្មភាពក្នុងថ្នាក់រៀនប៉ុណ្ណោះទេ មានទាំងបរិស្ថានរៀនសូត្ររបស់កុមារ រួមទាំងពង្រឹងសេវាបណ្ណាល័យ សកម្មភាពសិស្សជួយសិស្ស និងមាតាបិតាជួយនៅផ្ទះផងដែរ។

ឈរលើចំណុចដៅទាំង៩ដែលតាក់តែងឡើងដើម្បីវាស់ភាពជោគជ័យនៃកម្មវិធីរហូតដល់ពេលនេះ គម្រោងទទួលបានជោគជ័យចំនួន៦ចំណុច ឬមួយភាគបីនៃសូចនាករដែលបានកំណត់។ មានសូចនាករពីរបីប៉ុណ្ណោះដែលមិនទាន់សម្រេចបាន គឺសូចនាករវាស់ពីការជួយពីឪពុកម្តាយ និងមួយចំនួនទៀតមិនទាន់បានបញ្ចូលទិន្នន័យ និងវិភាគពីលទ្ធផល។



**← បណ្ណាល័យសតវត្សរ៍ទី២១** គឺជាយុទ្ធសាស្រ្តសំខាន់មួយរបស់ TRACIII ដែលផ្តល់ផលដល់សិស្សចម្រុះមានទាំងការលេងថែបប្លែត និងជាកន្លែងខ្ចីសម្ភារៈរបស់មាតាបិតាផង។ ↓



**គោលបំណង** គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ ( **TRACIII**) មានបំណងបង្កើនកម្រិតការអានរបស់កុមារដែលពួកគេចាំបាច់នឹងទទួលបាននូវជំនាញអានតាមរយៈវិធីសាស្រ្តមួយដែលសំដៅលើបរិស្ថានរៀនសូត្ររបស់កុមារ បរិស្ថានថ្នាក់រៀនទាំង ស្រុង និងមានការវាយតម្លៃទៀងទាត់ព្រមទាំងមានការចូលរួមបង្ហាត់បង្រៀនពីឪពុកម្តាយនៅផ្ទះ។

## រូបភាពសកម្មភាព



**← សេវារៀនសូត្រតាមឧបករណ៍អេឡិចត្រូនិច**ក្នុងបណ្ណាល័យដែលផ្តល់ឱកាសឱ្យកុមារពង្រឹងជំនាញអានរបស់ពួកគាត់ទៅតាមលក្ខណៈដែលគាត់រីករាយ។



**← ល្បែងសិក្សាពង្រឹងអំណាន**: សាលារៀននីមួយៗក្នុងគម្រោង TRAC III ទទួលបានល្បែងសិក្សាចម្រុះយ៉ាងទាក់ទាញទាក់ទងនឹងកម្មវិធីសិក្សាជាតិ សម្ភារៈទាំងនោះគឺមានទាំងក្នុងថ្នាក់រៀន និងបណ្ណាល័យសម្រាប់ស្វ័យសិក្សា និងពង្រឹងបន្ថែមកម្មវិធីកុមារជួយកុមារ។

## ផលជះរបស់គម្រោង

- **លទ្ធផលរៀនសូត្រចុងក្រោយ**: ប្រសិទ្ធភាពអានកុមារមានការកើនឡើងគួរឱ្យកត់សម្គាល់ដោយប្រៀបធៀបរវាងសាលាអន្តរាគមន៍ និងសាលាពុំមានអន្តរាគមន៍ក្រោយពីការធ្វើតេស្តចុងគ្រា (**EGRA**) របស់គម្រោងនៅចុងគ្រា។
- **លទ្ធផលរៀនសូត្រជាដំណាក់**: មានការរំលួសសិស្សធ្លាក់មធ្យមភាគតាមដំណាក់កាលនីមួយៗ ៥០% ជាងពីដំណាក់កាលទី១ទៅដំណាក់កាលមួយនៃសៀវភៅស្តង់ដាអំណាន (ថ្នាក់ទី១ ដល់ទី៣)។
- **លទ្ធផលអ្នកពាក់ព័ន្ធនៅកម្រិតសាលា:** គ្រូបង្រៀកអំណាន បណ្ណារក្សមានការចូលរួមបំពេញតួនាទីយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីអន្តរាគមន៍ពីគម្រោង។
- **ការបង្កើតបណ្ណាល័យសតវត្សរ៍ទី២១**: គ្រប់សាលាគោលដៅបានរៀបចំបណ្ណាល័យសតវត្សរ៍ទី២១ និងបានបំពាក់គ្រឿងសង្ហារឹម សម្ភារៈ សៀវភៅរឿងសម្បូរបែបដោយមានសេវាប្រើប្រាស់ល្អ បើកទ្វារគ្រប់វេណសិក្សា។
- **ការសិក្សាតាមឧបករណ៍អេឡិចត្រូនិច:** នៅគ្រប់សាលាគោលដៅបានផ្តល់ឱកាសឱ្យកុមារបានសិក្សាបន្ថែមក្នុងថែបប្លែតដែលបំពាក់ដោយកម្មវិធីជាច្រើនដើម្បីពង្រឹងអំណាន។
- **ប្រព័ន្ធឆ្លើយតបរហ័ស:** អន្តរាគមន៍ជួយកុមារដើម្បីប្រសិទ្ធភាពអាន មានដំណើរការល្អ ដូចជា ការធ្វើតេស្តទៀងទាត់ កុមារជួយកុមារ ល្បែងសិក្សា ការលេងថែបប្លែត ការជួយពីឪពុកម្តាយតាមរយៈការផ្ញើប័ណ្ណពីគ្រូបង្រៀក។

# គម្រោង លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER)

*“កុមារាកុមារីមានសិទ្ធិស្មើគ្នាដើម្បីទទួលបានការអប់រំដោយសេរី និងគ្មានអំពើហិង្សា ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | សហគមន៍អឺរ៉ុប អង្គការ VVOB |
| **អ្នកទទួលផលផ្ទាល់** | ស្រី ៤.៨០០នាក់ និងប្រុស ៤.៨០០ នាក់ទាំង៤០សាលា |
| **ថវិកាបានទទួល ឆ្នាំ២០១៨** | ១៧.៧៥៤ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ១,៨៥ដុល្លាអាមេរិកក្នុង១នាក់ |
| **ខេត្តគ្រប់ដណ្តប់** | បាត់ដំបង |
| **ស្រុកគ្រប់ដណ្តប់** | ក្រុងបាត់ដំបង |
| **មធ្យមសិក្សាគោលដៅ** | ២០សាលា |
| **បឋមសិក្សាគោលដៅ** | ២០សាលា |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ១ កក្កដា ២០១៧ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣០ មិថុនា ២០២០ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង**TIGER** បានចាប់ផ្តើមពីខែមករា ឆ្នាំ២០១៨ ហើយអង្គការខេបគឺជាអ្នកចូលរួមបំពេញសកម្មភាពរយៈពេល៣ឆ្នាំ។ កម្មវិធីនេះដឹកនាំសកម្មភាពដោយ **VVOB** អង្គការប៊ែលហ្ស៊ិក និងមានអង្គការផ្សេងទៀតចូលរួមជាដៃគូដូចជាអង្គការពុទ្ធិកុមារ និងអង្គការ **GADC**។ ក្រុមទីប្រឹក្សាថ្នាក់ជាតិបានបង្កើតឡើងនៅឆ្នាំ២០១៨ និងបានរួមគ្នាអភិវឌ្ឍន៍គោលការណ៍ណែនាំស្តីពីការការពារទប់ស្កាត់អំពើហិង្សាក្នុងសាលារៀន។ គោលការណ៍ណែនាំនេះនឹងជួយសម្របសម្រួល ឆ្លើយតបគ្រប់រូបភាពរើសអើងក្នុងសាលារៀនដែលនាំឱ្យមានសុវត្ថិភាពឆ្លើយតបទៅនឹងការសិក្សាបែបកុមារមេត្រីសម្រាប់កុមារទាំងអស់។

សកម្មភាពចម្បងៗដែលបង្កើតឡើងប្រចាំឆ្នាំ រួមមាន៖

- ពិធីសម្ពោធព្រឹត្តិការណ៍កម្មវិធី **TIGER**
- ផលិតបណ្ណផ្ទត់ បណ្ណព័ត៌មានចល័ត ប៉ុស្ទ័រ និងស្ទីកឃ័របិត (**VVOB)**
- ផលិត (គោលការណ៍ណែនាំយេនឌ័រ) ដែលមានការចូលរួមបំពេញការងារពីបណ្តុំអង្គការចម្រុះដែលមានអង្គការ ខេប អង្គការ **PKO** អង្គការ **GADC** និងអង្គការ **VVOB** ប៊ែលហ្ស៊ិក (ដំណាក់កាលបញ្ចប់)
- ផលិតសាច់រឿងអប់រំខ្លីៗបែបជីវចលរូបគំនូរកំប្លែង (កំពុងដំណើរការ)
- រៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុដោយអង្គការ **GADC**។

## សកម្មភាពសំខាន់ៗ

- បានរៀបចំព្រឹត្តការណ៍ កិច្ចប្រជុំដែលបង្ហាញអំពីការចាប់ផ្តើម (កម្មវិធីលើកកម្ពស់ការបង្រៀននិងរៀន ដែលឆ្លើយតបសមភាពយេនឌ័រ) ដែលចាត់ចែងសកម្មភាពពីក្រុមការងារថ្នាក់ជាតិ រាប់បញ្ចូលអ្នកតំណាងជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានសហការគ្នា និងផ្លាស់ប្តូរបទពិសោធន៍ ជាកម្មវិធីសាកល្បង និងធ្វើយុទ្ធនាការទប់ស្កាត់ការរើសអើងយេនឌ័រឆ្លើយតបអប់រំបរិយាប័ន្នក្នុងពេលអនាគត។
- បង្កើតក្រុមសម្របសម្រួល ពេលចាប់ផ្តើមផលិតគោលការណ៍ណែនាំ (ស្តីពីកម្មវិធីលើកកម្ពស់ការបង្រៀននិងរៀន ដែលឆ្លើយតបអប់រំបរិយាប័ន្ន/សមភាពយេនឌ័រ) ក្នុងចំណោមបណ្តុំអង្គការចម្រុះចំនួន៤។
- បង្កើតសាច់រឿងអប់រំខ្លីៗបែបកំប្លែង រូបគំនូរជីវចលស្តីពីការទប់ស្កាត់អំពើហិង្សាឆ្លើយតបការអប់រំបរិយាប័ន្ន
- ផលិតគោលការណ៍ណែនាំ (ស្តីពីកម្មវិធីលើកកម្ពស់ការបង្រៀននិងរៀន ដែលឆ្លើយតបការអប់រំបរិយាប័ន្ន)៖ ក).មានភាពសមស្របទៅនឹងបរិបទប្រទេសកម្ពុជា ខ).មានតម្លាភាពអាចជះឥទ្ធិពលល្អមាននិរន្តរភាព គ).លើកកម្ពស់ក្រុមការងារល្អដែលធ្វើការក្នុងសាលាគោលដៅជាមួយគ្នា និង ឃ).លើកកម្ពស់សហគមន៍និងភ្ជាប់ទំនាក់ទំនងល្អរវាងភាគីទាំងពីរពេលអនុវត្តសកម្មភាពជាមួយគ្នា។
- ផលិតគោលការណ៍ណែនាំ (ស្តីពីកម្មវិធីលើកកម្ពស់ការបង្រៀននិងរៀន ដែលឆ្លើយតបអប់រំបរិយាប័ន្ន) ដែលមាន៤ជំពូក និង ១៧មេរៀន។

## គោលបំណង

**ទត្ថុបំណងរួម:** ធានាថាសិស្សបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិត្រូវបានការពារពីអំពើហិង្សាផ្នែកយេនឌ័រនៅក្នុងសាលារៀន និងជំរុញលទ្ធភាពឱ្យកុមារបានចូលរួមដោយសមធម៌ក្នុងគ្រប់សកម្មភាពនៃជីវិតសាលារៀននិងនៅផ្ទះ។

**ទត្ថុបំណងជាក់លាក់:** ផ្លាស់ប្តូរវិទ្យាស្ថានគរុកោសល្យ និងសាលាចំនួន៤០ក្នុងខេត្តបាត់ដំបងឱ្យក្លាយជាមណ្ឌលគំរូដែលឆ្លើយតបយ៉ាងប្រសើលើបញ្ហាយេនឌ័រ។

**ទំហំគម្រោង:** សិស្សស្រី ៤.៨០០នាក់ និងសិស្សប្រុស ៤.៨០០នាក់នៅបឋម និងអនុវិទ្យាល័យទាំង៤០សាលានឹងទទួលផលក្នុងអំឡុងពេលអនុវត្តគម្រោង។

## រូបភាពសំខាន់ៗ





*ពិធីបើកសម្ពោធគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន ក្នុងខែកុម្ភៈ ឆ្នាំ២០១៨*



*សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការបង្កើតឯកសារណែនាំយេនឌ័រនៅក្រុងភ្នំពេញ។*



*វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងសាលាដែលឆ្លើយតបនឹងសមភាពយេនឌ័រ ក្នុងក្រុងបាត់ដំបង។*

# គម្រោង សហសាលាកម្ពុជា (USC)

*"រៀនដើម្បីចេះអាន អានដើម្បីមានចំណេះដឹង"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | មូលនិធិ Kinchan |
| **អ្នកទទួលផលផ្ទាល់** | ៤.៤១២នាក់ (ស្រី២.១៧៤នាក់) |
| **ថវិកាបានទទួល ឆ្នាំ២០១៨** | ១៥៩.៦៧៣,៨៣ ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ៣៩,១៩ ដុល្លាអាមេរិក/១នាក់ |
| **ខេត្តគ្រប់ដណ្តប់** | ៣ខេត្ត (កំពង់ចាម រតនៈគិរី និងសៀមរាប) |
| **ស្រុកគ្រប់ដណ្តប់** | ៤ ស្រុក (កំពង់សៀម វ៉ារិន ក្រឡាញ់ និងអូរយ៉ាដាវ) |
| **បឋមសិក្សាគោលដៅ** | ១២សាលាបឋម និង១សាលាមត្តេយ្យ |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ សីហា ២០១៧ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | មិនកំណត់រយៈពេល |

## បច្ចុប្បន្នភាពគម្រោង

គម្រោងសហសាលាកម្ពុជាគឺជាគម្រោងថ្មីមួយរបស់អង្គការ ខេប ដែលផ្តោតលើការងារអប់រំទាំងមត្តេយ្យសិក្សា និងបឋមសិក្សា។ គម្រោងបានចាប់ផ្តើមតាំងពីឆ្នាំ២០១៧ ដោយមានការគាំទ្រថវិកាពីមូលនិធិ Kinchan ជាមួយការគាំទ្រតែសាលាមត្តេយ្យគត់ ប៉ុន្តែនៅឆ្នាំ២០១៨នេះ គម្រោងបានចាប់ផ្តើមគាំទ្រសាលាបឋមសិក្សាផងដែរ ដើម្បីធានាថាកុមារដែលរៀននៅមត្តេយ្យសិក្សាអាចបន្តការសិក្សានៅបឋមសិក្សាប្រកបដោយគុណភាព។ គម្រោងសហសាលាកម្ពុជាគឺជាគម្រោងថ្មីមួយរបស់អង្គការ ខេប និងមានសក្តានុពលដ៏អស្ចារ្យសម្រាប់ការពង្រីកគោលដៅ។ គម្រោងបានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលហៅថាសមាគមគ្រួសារយើង ដែលទទួលខុសត្រូវលើការបង្កើតសាលាមត្តេយ្យសិក្សាក្នុងតំបន់ជនបទដាច់ស្រយាលជាមួយសហគមន៍ដែលគ្មានសាលាមត្តេយ្យសិក្សា។ ជារួម សាលាមត្តេយ្យ១២ត្រូវបានបង្កើតរហូតដល់បច្ចុប្បន្ននៅក្នុងខេត្ត៣ (១សាលានៅឃុំហាន់ជ័យ ខេត្តកំពង់ចាមគាំទ្រដោយអង្គការ ខេប)។ ក្នុងឆ្នាំសិក្សាថ្មីនេះ អង្គការ ខេបបានព្រមព្រៀងជាមួយសមាគមគ្រួសារយើងដើម្បីគាំទ្រសាលាមត្តេយ្យ និងបឋមសិក្សាក្នុងគោលដៅតែមួយក្នុងគោលបំណងកែលម្អសកម្មភាពអំណានដំបូង អាហារូបករណ៍ កែលម្អការគ្រប់គ្រងសាលារៀន ការចូលរួមរបស់សហគមន៍ និងក្រុមប្រឹក្សាកុមារជាដើម។

## សកម្មភាពសំខាន់ៗ

- បណ្តុះបណ្តាលអ្នកពាក់ពន្ធ័សាលារៀនពីការរៀបចំផែនទីសិក្សា
- ផ្តល់អាហារូបករណ៍ដល់កុមារងាយរងគ្រោះ
- កែលម្អសេវាបណ្ណាល័យស្របជាមួយកម្មវិធីអំណានថ្នាក់ដំបូង
- ផ្តល់ការបណ្តុះបណ្តាលនាយកសាលា/គ្រូពីវិធីសាស្រ្តបង្រៀនកុមារមេត្រី
- រៀបចំសកម្មភាពបំណិនជីវិតក្នុងសាលារៀន
- ផ្តល់សម្ភារបង្រៀនអំណាន និងគណិតវិទ្យា
- ផ្តល់ការបណ្តុះបណ្តាលគ្រូសហគមន៍ចំពោះសាលាខ្វះគ្រូបង្រៀន
- ផ្តល់ការបណ្តុះបណ្តាលការប្រើប្រាស់ស្តង់ដាអំណាន
- រៀបចំប្រព័ន្ធឆ្លើយតបរហ័សសម្រាប់ជួយសិស្សរៀនយឺត
- បញ្ជ្រាបសិទ្ធិកុមារនៅតាមសាលារៀន
- ជួយសាលារៀនរៀបចំផែនការអភិវឌ្ឍន៍សាលារៀន
- បណ្តុះបណ្តាលនាយកសាលាស្តីពីការកែលម្អសាលារៀន
- ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍
- បណ្តុះបណ្តាលគណៈកម្មការទ្រទ្រង់សាលារៀន
- គាំទ្រសកម្មភាពក្រុមប្រឹក្សាកុមារក្នុងសាលារៀន
- គាំទ្រសកម្មភាពមត្តេយ្យសិក្សារួមមាន សម្ភារៈសិក្សា អាហារពេលព្រឹក។ល។

## គោលបំណង

គម្រោង USC មានគោលបំណងអភិវឌ្ឍគំរូកម្មវិធីសាលាកុមារមេត្រីដែលមាន៦សមាសភាគ និងផ្តោតរួមទាំងគុណភាពអប់រំ ការអប់រំបញ្ចូលគ្នា និងមានការចូលរួមពីអ្នកពាក់ព័ន្ធសាលារៀន (ឧ. ការចូលរួមរបស់មាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋាន) ក្នុងគោលបំណងដើម្បីធានាឱ្យមានការផ្លាស់ប្តូរយ៉ាងល្អនូវការសិក្សាពីកម្រិតសាលាមត្តេយ្យសិក្សាឆ្លងទៅសាលាបឋមសិក្សា។

## រូបភាពសកម្មភាព



***←តេស្តគុណភាពខ្ពស់៖*** *បុគ្គលិកអង្គការខេបកំពង់ធ្វើតេស្តសិស្សថ្នាក់ទី១ ដែលសាលារៀនគាំទ្រដោយសហសាលាកម្ពុជាជាមួយការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចដើម្បីធានាគុណភាព និងសុក្រិតភាពទិន្នន័យ។*

***សួនកុមារ៖*** *កុមារនៅសាលាមត្តេយ្យហាន់ជ័យកំពុងរីករាយលេងជាមួយសួនកុមារ។↓*





***ពង្រឹងការចូលរួមរបស់សហគមន៍៖*** *ក្រុមការងារគម្រោងប្រជុំជា មួយសមាជិកសហគមន៍នៅមត្តេយ្យហាន់ជ័យដើម្បីពិភាក្សាពីការចុះឈ្មោះចូលរៀន និងជួយគាំទ្រសាលារៀន។*

***ការពង្រឹងភាពជាម្ចាស់ការរបស់សិស្ស៖*** *ក្រុមការងារគម្រោងជួបប្រជុំជាមួយក្រុមប្រឹក្សាកុមារដើម្បីវាយតម្លៃពីការចូលរួមរបស់ពួកគេ។*





***↑ ពង្រឹងការចូលរួមរបស់សហគមន៍៖*** *ក្រុមការងារគម្រោងដឹកនាំការពិភាក្សាជាមួយនាយក និងសមាជិកសហគមន៍ ដើម្បីកំណត់បញ្ហាការអប់រំ និងវិធីដែលគម្រោងជួយពួកគាត់សម្រេចតាមតម្រូវការរបស់ពួកគាត់។*

# ការបង្ហាញផ្នែកហិរញ្ញវត្ថុ

## សាច់ប្រាក់ និងការចំណាយ

| សេចក្តីពណ៌នា | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|
| ចំណូលថវិកាសរុបក្នុងគម្រោងប្រចាំឆ្នាំ២០១៨ | ៣.៥៥៨.១០៦,២៣ |
| សមតុល្យចុងគ្រាពីឆ្នាំ២០១៧ | ១.៤៣០.៦៨៦,៧៤ |
| ចំណូលការប្រាក់ | ៤៦៥,១៤ |
| ទ្រព្យដែលអាចប្រើប្រាស់ក្នុងឆ្នាំ ២០១៨ | ៤.៩៨៩.២៥៨,១១ |
| សរុបថវិកាចំណាយប្រចាំឆ្នាំ ២០១៨ | ៣.១១៧.៧០៩,០៤ |
| អត្រាប្រើប្រាស់ថវិកា | ៨៨% |

## និន្នាការទទួលថវិកា




## តើថវិកាជំនួយត្រូវយកទៅប្រើប្រាស់ដូចម្តេច?




## លំហូរចំណូលឆ្នាំ ២០១៧

| ម្ចាស់ជំនួយ | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | ២.៦៤៩.១៧៦,៣៣ |
| អង្គការឆាលហ្វាន (ChildFund) | ៦០២.៥២៨,៧៥ |
| អង្គការវីវើល (WeWorld) | ៣៨២.៣៨០,៤១ |
| អង្គការអប់រំពិភពលោក (WE) | ៣៣៦.៨៨២,៧៣ |
| អង្គការមូលនិធិ Phoenix | ៣០៣.២៧៩,១១ |
| មូលនិធិ Franks Family | ២២៤.៣៦០,៨១ |
| អង្គការ Classroom of Hope | ១៤៤.៤៧០,២៥ |
| អង្គការ Save the Children | ១៣៦.៦៣៥,៩៧ |
| អង្គការមូលនិធិអាស៊ី (TAF) | ៧៨.១៤៨,៧២ |
| មូលនិធិ Kinchan | ៥៣.៩៥៨,៦១ |
| សហគមន៍អឺរ៉ុប-អង្គការ VVOB | ៤៣.១០៥,៣៥ |
| RTI-USAID | ១២.៦៨១,៥១ |
| ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា | ១២.១៨៤,៦១ |
| អង្គការ Aid et Action | ៩.៤៦៤,៩៥ |
| ប្រាក់ចំណូលថ្មីទទួលបានក្នុងឆ្នាំ២០១៨ | ៤.៩៨៩.២៥៨,១១ |

### សេចក្តីថ្លែងអំណរគុណ!

ជូនសមុខឲ្យកុមារ គ្រូបង្រៀន ឪពុកម្តាយ និងក្រុមអ្នកទទួលផលទាំងនោះមកពីកម្មវិធីរបស់យើង អង្គការ ខេប សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់សម្រាប់ការផ្តត់ផ្គង់របស់ពួកគេក្នុងឆ្នាំនេះ និងឆ្នាំមុនៗកន្លងមក។ ការផ្គត់ផ្គង់ហិរញ្ញវត្ថុ បានធ្វើឲ្យអង្គការ ខេប ផ្តល់នូវសេវាកម្មជូនអ្នកទទួលផលប្រកបដោយអត្ថន័យគ្រប់គ្រាន់។

សូមអរគុណ!

# រចនាសម្ព័ន្ធអង្គការ ខេប ក្នុងឆ្នាំ២០១៨

## ឧបសម្ព័ន្ធ ទី១




**AEOs** មន្ត្រីប្រមូលកុមារ និងទំនាក់ទំនងមាតាបិតា
**AGPO** មន្ត្រីកម្មវិធីប្រមូលសិស្សរៀន និងអភិបាលកិច្ច
**AS** អ្នកជំនួយការ
**BfC** គម្រោងសៀវភៅសម្រាប់កម្ពុជា
**CCO** មន្ត្រីប្រឹក្សាអាជីព
**DPO** មន្ត្រីកម្មវិធីថ្នាក់ស្រុក
**DTOs** មន្ត្រីបច្ចេកទេសថ្នាក់ស្រុក
**EQO** មន្ត្រីកម្មវិធីគុណភាពអប់រំ
**E2L** គម្រោង ងាយស្រួលរៀន
**EQPO** មន្ត្រីកម្មវិធីគុណភាពអប់រំ
**FAO** មន្ត្រីហិរញ្ញវត្ថុ និងរដ្ឋបាល
**FO** មន្ត្រីហិរញ្ញវត្ថុ
**GES** មន្ត្រីគុណភាពអប់រំទូទៅ
**ICT in ES** មន្ត្រីជំនាញព័ត៌មានវិទ្យាសម្រាប់ការអប់រំ
**ICTPO** មន្ត្រីកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំ
**IEP** កម្មវិធីអប់រំបញ្ចូលគ្នា
**KLS** គ្រូបង្រៀនភាសាខ្មែរ
**M&EO** មន្ត្រីកម្មវិធីផ្នែកតាមដាន និងវាយតម្លៃ (MIS)
**M&ES/RT** មន្ត្រីជំនាញតាមដាន និងវាយតម្លៃ/គ្រូបណ្តុះបណ្តាលអំណាន
**NAS** ទីប្រឹក្សាគម្រោង NGS (ទំនាក់ទំនងព័ត៌មានវិទ្យាសម្រាប់ការអប់រំ)
**NGS** គម្រោង សាលារៀនជំនាន់ថ្មី
**NIO** មន្ត្រីអប់រំ ICT NGS
**NOM** ប្រធានប្រតិបត្តិការគម្រោង សាលារៀនជំនាន់ថ្មី
**QGOs** មន្ត្រីកម្មវិធីផ្នែកគុណភាព និងអភិបាលកិច្ច
**PA** អ្នកជំនួយការកម្មវិធី
**PC** មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត
**PED/DCD** នាយកដ្ឋានបឋមសិក្សា/នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
**PO** មន្ត្រីកម្មវិធី
**QLE Exp.** គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (ពង្រីក)
**REACH II** គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ II
**RT** គ្រូបណ្តុះបណ្តាលអំណាន
**RTL** ប្រធានដឹកនាំក្រុមស្រាវជ្រាវ
**SCO** មន្ត្រីទំនាក់ទំនងជាន់ខ្ពស់
**SA** អ្នកសម្របសម្រួលសាលា (2)
**SAC** មន្ត្រីប្រឹក្សាសាលារៀន
**SCOs** មន្ត្រីសហគមន៍ជាន់ខ្ពស់ (CIAI)
**SEA** ជំនួយការអប់រំវិទ្យាសាស្ត្រ
**SETL** ប្រធានក្រុមអប់រំវិទ្យាសាស្ត្រ
**SGM** អ្នកប្រឹក្សាអភិបាលកិច្ចសាលារៀន (2)
**SML** គម្រោងគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ
**TIGER** គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន
**TL** ប្រធានក្រុម
**TRAC III** វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ
**USC** គម្រោងសហសាលាកម្ពុជា

**ផ្នែកដឹកនាំ**
ព្រួញមុខពីរ = ទំនាក់ទំនងជាមួយទីប្រឹក្សា អ្នកសម្របសម្រួលអំណាន និងប្រ.សស.ផ្នែកបច្ចេកវិទ្យាអប់រំ។
ប្រអប់ដាច់ៗ = ស្វ័យយ័តភាព។ គណៈកម្មការគ្រប់គ្រងមូលនិធិសុខភាពមានស្វ័យយ័តភាពពេញលេញ។
**POs**** កម្មវិធីអប់រំបញ្ចូលគ្នា/**IEP** មាន៖ គម្រោងអប់រំកុមារី **(GEI)** គម្រោង **STEM4WOMEN** គម្រោង **ACCESS** និង **CTSP**។ “**POs**” បង្ហាញអំពីមន្ត្រីទាំងអស់នៅក្នុងកម្មវិធី **IEP**។
*សូមបញ្ជាក់ថា លំដាប់ថ្នាក់ក្នុងរចនាសម្ព័ន្ធខាងក្រោមផ្នែកដឹកនាំ ប្រធានផ្នែកនីមួយៗមិនត្រូវបានបញ្ចូលទៅក្នុងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស/រដ្ឋបាល ដែលបានកំណត់ហើយនៅក្នុងបញ្ជីឈ្មោះ។